**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economic

# សារណាបញ្ចប់ការសិក្សា

## ប្រៀបធៀប

## បទល្មើសរំលោភសេពសន្ថវៈ និងបទល្មើសប្រទូស្តកេរខ្មាស

ស្រាវជ្រាវចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **កញ្ញា យឹម មុន្នីរ័ត្ន**

**លោក ខ្សៃ សៀងអ៊័ង**

ណែនាំដោយ

**បណ្ឌិត អ៊ុង រដ្ឋា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៩(អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **យឹម មុន្នីរ័ត្ន** និងខ្ញុំបាទឈ្មោះ **ឡៃ សៀវអ៊ែ** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ផ្នែកនីតិសាស្ត្រ ជំនាន់ទី២៩ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា ២០២០-២០២៤។

យើងខ្ញុំសូមសម្តែង និងគារវៈកិច្ចគោរពដឹងគុណដ៏ខ្ពង់ខ្ពស់ជូនចំពោះអ្នកមានគុណដែលបានផ្តល់កំណើត និងបានខិតខំពុះពារឧបសគ្គក្នុងការចិញ្ចឹមបីបាច់ ថែរក្សា អប់រំ ទូន្មាន ប្រៀនប្រដៅ និងបានផ្គត់ផ្គង់កូនគ្រប់សព្វបែបយ៉ាងទាំងសម្ភារៈសម្រាប់ប្រើប្រាស់រៀនសូត្រ និងស្មារតីដល់កូន ជាពិសេស លោកទាំងពីរបានខិតខំជំរុញឱ្យកូនបានសិក្សារៀនសូត្ររហូតមកដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រ។ គុណូបការៈដែល លោកទាំងពីរបានផ្តល់ និងលះបង់នេះ វាជាវត្ថុដ៏មានតម្លៃបំផុតដែលមិនអាចកាត់ថ្លៃបាន និងមិនអាចរកអ្វីមកប្រៀបផ្ទឹមពុំបានឡើយ ហើយគ្មានថ្ងៃណាដែលកូនបានតបស្នងសងគុណលោកវិញអស់ឡើយ។

យើងខ្ញុំសូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅផងដែរចំពោះឯកឧត្តមសាកលវិទ្យាធិការ និងព្រមទាំង សាកលវិទ្យាធិការរង ព្រឹទ្ធបុរសរង សាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ ដែលបានជួយតម្រង់ទិសដៅនៅក្នុងការសិក្សារៀនសូត្ររហូតមកដល់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ។

ជាពិសេស **បណ្ឌិត អ៊ឹង រដ្ឋា** ដែលបានដឹកនាំ ចង្អុលបង្ហាញ និងសម្របសម្រួល ដំបូន្មាន និងអនុសាសន៍ល្អៗ ព្រមទាំងពន្យល់ពីវិធីសាស្ត្រក្នុងការស្រាវជ្រាវឯកសារ និងទិន្នន័យនានាដែលពាក់ព័ន្ធនឹងប្រធានបទខាងលើនេះ។

ជាចុងបញ្ចប់យើងខ្ញុំសូមបួងសួង ដល់វត្ថុសាកសិទ្ធទាំងអស់ក្នុងលោកសូមជួយតាមថែរក្សាលោកទាំងអស់ឱ្យជួបប្រទះតែសេចក្តីសុខនិងសុខភាពល្អអាយុយឺនយូរដើម្បីបន្តដឹកនាំ និងផ្តល់ចំណេះដឹងបន្តទៅដល់កុលបុត្រកុលធីតាខ្មែរជំនាន់ក្រោយទៀត។

យើងខ្ញុំទាំងពីរនាក់ គឺជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី ២៩ ដែលបានសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចចាប់តាំងពីឆ្នាំ ២០២០ រហូតដល់ឆ្នាំ ២០២៤។ បន្ទាប់ពីបានសិក្សាអស់រយៈពេល ៤ ឆ្នាំ កន្លងមកនេះយើងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើនពីសាស្ត្រាចារ្យ ទាំងឡាយដែលបានខិតខំប្រឹងប្រែងបង្ហាត់បង្រៀនយ៉ាងយកចិត្តទុកដាក់ដល់យើងខ្ញុំ។ ហេតុដូច្នេះហើយ ដើម្បីធ្វើការវាយតម្លៃ និងវាស់ស្ទង់ទៅលើចំណេះដឹងរបស់ពួកយើងខ្ញុំដែលបានសិក្សា

កន្លងមកក្នុងរយៈពេល ៤ឆ្នាំមក នេះយើងខ្ញុំសូមលើកយកនូវប្រធានបទមួយដែលមានចំណងជើងថា «ប្រៀបធៀបបទល្មើសរំលោភសេពសន្ថវៈ និងបទល្មើសប្រទូស្តកេរខ្មាស» មកធ្វើការសិក្សាស្រាវជ្រាវដើម្បីធ្វើជាសារណាក្នុងការបញ្ចប់ការសិក្សា។

មូលហេតុដែលយើងខ្ញុំសម្រេចចិត្ត លើកយកប្រធានបទនេះមកសរសេរសារណា គឺដើម្បីឱ្យមិត្តនិស្សិត និងមិត្តអ្នកអានដែលមានបំណងធ្វើការស្វែងយល់អំពីបទល្មើសទាំងពីរនេះ ដែលមានការចាប់អារម្មណ៍ក្នុងមួយរយៈពេលប៉ុន្មានឆ្នាំក្រោយមកនេះ។ តាមរយៈស្នាដៃនៃសារណារបស់យើងខ្ញុំនេះ យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា អត្ថបទសារណាមួយនេះនឹងចូលរួមជាពិសេស ក្នុងការផ្សព្វផ្សាយ និងជាជំនួយដល់ស្មារតីផ្នែកច្បាប់ព្រមទាំងសម្រាប់បុគ្គលទូទៅមិនចំពោះតែអ្នកច្បាប់ ជាពិសេសសម្រាប់ សិស្សនិស្សិតណាចង់ដឹង និងចង់សិក្សាស្វែង យល់អំពីបទល្មើសដែលកើតឡើងក្នុងរឿងព្រហ្មទណ្ឌ។

ដោយសារតែពេលវេលាក្នុងការសិក្សាស្រាវជ្រាវ និងសរសេរសារណាបញ្ចប់ការសិក្សាមានរយៈពេលខ្លី ហើយម្យ៉ាងវិញទៀតដោយសារតែចំណេះដឹងពួកយើងខ្ញុំនូវមានកម្រិត យើងខ្ញុំជឿជាក់ថាកំហុសដែលកើតមានឡើងដោយ  អចេតនាមួយចំនួន ដែលក្នុងនោះមានដូចជា កំហុសអក្ខរាវិរុទ្ធ ខ្លឹមសារអត្ថន័យ និងភាពខ្វះចន្លោះ មិនគ្រប់ជ្រុងជ្រោយតាមខ្លឹមសារច្បាប់នឹងកើតមានក្នុងសារណានេះជាក់ជាពុំខាន។ យើងខ្ញុំរីករាយនឹងទទួលយកនូវមតិរិះគន់ក្នុងន័យស្ថាបនា ដើម្បីកែលំអនូវកំហុសខុសឆ្គងពីសំណាក់លោក លោកស្រីសាស្ត្រាចារ្យ ក៏ដូចជា មិត្ត និស្សិតទាំងឡាយ ដើម្បីបំពេញនូវរាល់កំហុសឆ្គង និងចំណុចខ្វះខាតទាំងឡាយដោយក្តីសោមនស្សរីករាយ ដោយមេត្រីភាពព្រមទាំង សូមអរគុណ និងអរព្រះគុណ។

# អារម្ភកថា

ការសិក្សានៅថ្នាក់បរិញ្ញាបត្រដែលមានរយៈពេល ៤(បួន) ឆ្នាំនៅ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចបានកន្លងផុតទៅយ៉ាងឆាប់រហ័ស ដោយការសិក្សាក្នុងរយៈពេលបួនឆ្នាំមកនេះបាន ផ្តល់នូវ ចំណេះដឹងថ្មីៗបន្ថែមយ៉ាងច្រើនដល់យើងខ្ញុំ ក្រោមការបង្ហាត់បង្រៀនយ៉ាងល្អិតល្អន់ និងយកចិត្ត ទុកដាក់ពីសំណាក់លោកគ្រូ អ្នកគ្រូ ដែលជាសាស្ត្រាចារ្យនៃសាកលវិទ្យាល័យ ពួកគាត់បានចំណាយ ពេលដ៏មានតម្លៃ ក្នុងការជួយ បណ្តុះបណ្តាលនូវធនធានមនុស្ស ដើម្បីជំរុញឱ្យប្រទេសជាតិមានការអភិវឌ្ឍ និងមានភាពរីកចម្រើនបន្ថែមទៀត។

តាមរយៈកម្មវិធីសិក្សា របស់សាកលវិទ្យាល័យ នៅឆ្នាំបញ្ចប់ការសិក្សាបរិញ្ញាបត្រ គឺតម្រូវឱ្យនិស្សិតធ្វើ ការជ្រើសរើសជម្រើសនៃការប្រឡងបញ្ចប់ ឬជ្រើសរើសនូវជម្រើសនៃការសរសេរសារណា ឬរបាយការណ៍កម្ម សិក្សាដើម្បីធ្វើការការពារបញ្ចប់នូវការ សិក្សារបស់ខ្លួន។ យើងខ្ញុំទាំងពីរអ្នកជ្រើសរើសជម្រើស នៃការសរសេរ សារណា ដើម្បីបង្ហាញពីលទ្ធផលនៃការសិក្សា ក៏ដូចជាការយល់ដឹង អំពីការសិក្សា និងការបង្ហាញ ត្រួស ត្រាយផ្លូវពីសំណាក់លោកគ្រូ អ្នកគ្រូដែលជា សាស្ត្រាចារ្យលើរយៈពេលនៃការសិក្សាបួនឆ្នាំកន្លងមក ហើយ ក៏ជាឱកាសនៃការចងក្រងជាឯកសារបង្ហាញពីស្នាដៃពាក់ព័ន្ធនឹងប្រធានបទស្តីពី«ប្រៀបធៀបបទល្មើស រំលោភសេពសន្ថវៈ និងបទល្មើសប្រទូស្តកេរខ្មាស» ទុកជាស្នាដៃ និងជាការយល់ដឹងខ្លះៗទាក់ទងនឹង បទ ល្មើសទាំងពីរនេះ ជូនដល់សាកលវិទ្យាល័យ ជាពិសេសនោះ គឺមិត្តនិស្សិតសម្រាប់ជាចំណេះដឹងក៏ដូចជាការ ស្វែងយល់បន្ថែម។

យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថាសារណាមួយនេះ និងផ្តល់ជាឯកសារស្រាវជ្រាវ ដែលនឹងផ្តល់នូវ ផលប្រយោជន៍ ជាមូលដ្ឋានមួយដែលជម្រុញដល់ការយល់ដឹងមួយផ្នែកដល់អ្នកសិក្សាគ្រប់មជ្ឈដ្ឋាន និង ជាឯកសារដែលមានតម្លៃមួយ ទាក់ទងទៅនឹងបញ្ហា និងហេតុដែលនាំឱ្យមានបទល្មើស ការប្រព្រឹត្តទៅនៃ សកម្មភាពរបស់ជនល្មើស បណ្តាលមានផលប៉ះពាល់ជាច្រើនដល់ខ្លួនឯង គ្រួសារ មនុស្សជុំវិញខ្លួន ក៏ដូច ជាសង្គមជាតិយើងទាំងមូល។

ទន្ទឹមនឹងនេះដែរ យើងខ្ញុំក៏សូមអភ័យទោសនូវរាល់កំហុសខុសឆ្គងដែលកើតមានឡើងដោយ អចេតនាត្រង់កន្លែងណាមួយដូចជា អក្ខរាវិរុទ្ធ ការប្រើប្រាស់នូវពាក្យពេចន៍ រួមទាំងការខ្វះខាតទាក់ទងនឹង អត្ថន័យនៃការបកស្រាយត្រង់ខ្លឹមសារកន្លែងណាមួយក្តីនៅក្នុងសារណានេះ យើងខ្ញុំរីករាយទទួលយកនូវ ការរិះគន់ កែលម្អក្នុងន័យដើម្បីស្ថាបនាពីសំណាក់លោកគ្រូ អ្នកគ្រូ រួមទាំងមិត្តនិស្សិត ដើម្បីធ្វើឱ្យឯក សារសារណានេះ និងស្នាដៃផ្សេងៗក្រោយៗទៀតមានភាពល្អប្រសើរ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** .......... ១

## ជំពូកទី១

## បទល្មើសរំលោភសេពសន្ថវៈ

**១.១ និយមន័យនៃបទល្មើសរំលោភសេពសន្ថវៈ** .......... ៤
**១.២.ធាតុផ្សំនៃបទល្មើសរំលោភសេពសន្ថវៈ** .......... ៤
១.២.១ ធាតុផ្សំនីត្យានុកូល .......... ៥
១.២.២.ធាតុផ្សំសត្យានុម័ត .......... ៦
១.២.២.១.ការប្រើហិង្សា .......... ៧
១.២.២.២.ការបង្ខិតបង្ខំ ឬ ការគំរាមកំហែង .......... ៧
១.២.២.៣.ការឆ្មក់ឱកាស .......... ៨
១.២.២.៤.អំពើបញ្ចូលអង្គជាត .......... ៩
១.២.២.៥ អវត្តមាននៃការព្រមព្រៀង .......... ១០
១.២.៣.ធាតុផ្សំអត្តនោម័ត .......... ១៣
១.២.៣.១ ចេតនាក្នុងប្រព្រឹត្ត .......... ១៤
**១.៣. ទោស និងស្ថានទម្ងន់ទោសដែលត្រូវអនុវត្ត** .......... ១៦
១.៣.១ និយមន័យនៃទោស .......... ១៦
១.៣.២ ទោសធម្មតា .......... ១៧
១.៣.៣ ស្ថានទម្ងន់ទោស .......... ១៧
១.៣.៤.ទោសបន្ថែម .......... ២០
១.៣.៥.ការប៉ុនប៉ងប្រព្រឹត្តបទល្មើស .......... ២១

## ជំពូកទី២

## បទល្មើសប្រទូស្តកេរខ្មាស

**២.១.និយមន័យនៃបទល្មើសប្រទូស្តកេរខ្មាស** .......... ២៣
២.១.១.ច្បាប់ព្រហ្មទណ្ឌអន្តរកាល .......... ២៣

២.១.២.ក្រមព្រហ្មទណ្ឌបច្ចុប្បន្ន.............................................................២៣
**២.២.ធាតុផ្សំនៃបទល្មើសប្រទូស្តកេរខ្មាស** ............................................................២៣
២.២.១.ធាតុផ្សំនីត្យានុកូល ............................................................២៥
២.២.២.ធាតុផ្សំសត្យានុម័ត ............................................................២៥
២.២.២.១.អំពើរបស់ជនល្មើស ............................................................២៦
២.២.២.២.អវត្តមានការព្រមព្រៀងពីជនរងគ្រោះ............................................................២៩
២.២.៣.ធាតុផ្សំអត្តនោម័ត ............................................................៣០
២.២.៣.១.ចេតនាក្នុងប្រព្រឹត្ត ............................................................៣១
២.២.៣.២.អចេតនាក្នុងការប្រព្រឹត្ត............................................................៣១
**២.៣.ទោសដែលត្រូវអនុវត្ត**............................................................៣២
២.៣.១.មូលទោសនៃបទប្រទូស្តកេរខ្មាស............................................................៣២
២.៣.២.ស្ថានទម្ងន់ទោស ............................................................៣៣
២.៣.៣.ការប៉ុនប៉ងនៅក្នុងបទប្រទូស្តកេរខ្មាស ............................................................៣៩
២.៣.៤.ទោសបន្ថែមនៃបទប្រទូស្តកេរខ្មាស ............................................................៤០

## ជំពូកទី ៣

## ប្រៀបធៀបបទល្មើសរំលោភសេពសន្ថវៈ និងបទល្មើសប្រទូស្តកេរខ្មាស

**៣.១. លក្ខណៈដូចគ្នានៃបទល្មើសទាំងពីរ**............................................................៤២
៣.១.១.ធាតុផ្សំនីត្យានុកូល ............................................................៤២
៣.១.១.១.ការបែងចែកក្នុងគន្លី ............................................................៤២
៣.១.១.២.ការបែងចែកក្នុងជំពូក............................................................៤២
៣.១.១.៣.ទោសបន្ថែម ............................................................៤៣
៣.១.២.ប្រធាននៃបទល្មើស ............................................................៤៤
៣.១.២.១.ជនរងគ្រោះ............................................................៤៤
៣.១.២.២.ជនល្មើស............................................................៤៤
៣.១.៣.ព្យសនកម្ម............................................................៤៤
**៣.២.លក្ខណៈខុសគ្នានៃបទល្មើសទាំងពីរ**............................................................៤៤
៣.២.១.ធាតុនីត្យានុកូលនៃបទល្មើស ............................................................៤៥

៣.២.១.១.និយមន័យនៃបទល្មើសទាំងពីរ........................................................................................៤៥
៣.២.១.២.ការផ្តន្ទាទោស........................................................................................................៤៦
៣.២.១.៣.ស្ថានទម្ងន់ទោសនៃបទល្មើសទាំងពីរ....................................................................៤៦
៣.២.២.ធាតុសត្យានុម័តនៃបទល្មើសទាំងពីរ........................................................................៤៨
៣.២.២.១.រូបភាពនៃអំពើ........................................................................................................៤៨
៣.២.៣.ធាតុអត្តនោម័តនៃបទល្មើសទាំងពីរ........................................................................៥០
៣.២.៣.១.ចេតនាក្នុងការប្រព្រឹត្ត..............................................................................................៥០
៣.២.៤.ចំណាត់ថ្នាក់នៃបទល្មើសទាំងពីរ............................................................................ ៥១
៣.២.៤.១.ចំណាត់ថ្នាក់បទល្មើសនៃបទរំលោភសេពសន្ថវៈ....................................................៥២
៣.២.៤.២.ចំណាត់ថ្នាក់បទល្មើសនៃបទប្រទូស្តកេរខ្មាស.........................................................៥២
៣.២.៥.ការប៉ុនប៉ងប្រព្រឹត្តបទល្មើស......................................................................................... ៥៣
៣.២.៦.តារាងនៃការប្រៀបធៀប..............................................................................................៥៤
**៣.២.ករណីសិក្សា**...............................................................................................................៦០
**សេចក្តីសន្និដ្ឋាន**.......................................................................................................................... ៦៣
**អនុសាសន៍**...................................................................................................................................៦៤
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃការសិក្សាស្រាវជ្រាវ

នៅក្នុងសង្គមជាតិនីមួយៗ នៅក្នុងសកលលោកយើងនេះជាពិសេសនោះ គឺព្រះរាជាណាចក្រកម្ពុជាយើងតែងតែមានការប្រែប្រួល និងផ្លាស់ប្តូរទៅតាមឥរិយាបទនៃសង្គមពីមួយជំនាន់ទៅមួយជំនាន់ ហើយជីវភាពនៃការរស់នៅមនុស្សនៅក្នុងសង្គម ក៏តែងតែផ្សារភ្ជាប់នូវទំនាក់ទំនងជាមួយគ្នាយ៉ាងជិតស្និតថែមទៀតផង។ ទន្ទឹមនឹងគ្នានេះផងដែរយើង ក៏តែងតែឃើញមនុស្សមួយចំនួនបានធ្វើការបំពានទៅនឹងវិធាននៃច្បាប់ទាំងនេះជាញឹកញាប់ដែលធ្វើឱ្យច្បាប់ក៏ត្រូវមានការប្រែប្រួលទៅបានសង្គមទាំងនោះផងដែរ។

ដើម្បីឆ្លើយតបទៅនឹងការបំពានទាំងនោះទើបប្រទេសកម្ពុជាយើងបានរៀបរៀង និងចងក្រងនូវច្បាប់ ព្រហ្មទណ្ឌឡើងក្នុងគោលបំណងដើម្បីរៀបចំសង្គមឱ្យមានសណ្តាប់ធ្នាប់ និងកាត់បន្ថយនូវការបំពានទាំងនោះដែលជាញឹកញាប់យើងតែងតែឃើញមាននូវការបំពានទៅកាន់បូរណភាពនៃរូបរាងកាយរបស់បុគ្គលដទៃកើតមានឡើង ដោយជាក់ស្តែងដូចជាអំពើនៃការរំលោភបំពានទៅកាន់ខាងផ្លូវភេទជាដើម។ បន្ថែមពីលើនេះទៅទៀតចំពោះ អំពើរំលោភសេពសន្ថវៈវិញយើងតែងតែឃើញកើតមានឡើងនៅក្នុងសង្គមរបស់យើង ដែលបានធ្វើឱ្យប៉ះពាល់ទៅកាន់សង្គមយ៉ាងធ្ងន់ធ្ងរ និងជាពិសេសធ្វើឱ្យប៉ះពាល់ទៅដល់កុមារដែលជាសសរទ្រូង និងធនធានថ្មីសម្រាប់សង្គមជាតិទាំងមូល។ អំពើរំលោភសេពសន្ថវៈនេះបាន ប៉ះពាល់ដល់បូរណភាពនៃរាងកាយ ផ្លូវចិត្ត និងសេចក្តីថ្លៃថ្នូររបស់បុគ្គលដែលជាជនរងគ្រោះ ធ្វើឱ្យខូចខាតយ៉ាងធ្ងន់ធ្ងរដល់កេរ្តិ៍ឈ្មោះ និងកិត្តិយសរបស់ជនរងគ្រោះហើយទង្វើនេះ ត្រូវបានប្រទេសភាគច្រើនចាត់ទុកអំពើនេះថាមានចរិតលក្ខណៈគួរឱ្យស្អប់ខ្ពើមយ៉ាងឃោរឃៅ ពីព្រោះការរំលោភបំពាន និងការបៀតបៀនផ្លូវភេទនេះត្រូវបានការពារ និងយកចិត្តទុកដាក់ចំពោះសេរីភាពក៏ដូចជាស្វ័យភាពនៃសិទ្ធិជាពលរដ្ឋ ដោយផ្អែកលើមាត្រា៥ នៃសេចក្តីប្រកាសជាសាកលស្តីពី សិទ្ធិមនុស្សបានកំណត់ពីបូរណភាពបុគ្គល គឺគ្មានជនណាម្នាក់ត្រូវទទួលទារុណកម្ម ឬ ទណ្ឌកម្ម និងប្រព្រឹត្តសកម្មភាពកាចសាហាវ និងថោកទាប។

បន្ថែមពីលើនេះទៅទៀតយើង ក៏ឃើញមាននូវការបំពានផ្លូវភេទដទៃថែមទៀតផងដែរតាមរយៈអំពើនៃការប្រទូស្តកេរខ្មាសជាដើមដែលបានធ្វើឱ្យមានការប៉ះពាល់ទៅដល់សណ្តាប់ធ្នាប់សង្គម និងជាពិសេសបានធ្វើឱ្យប៉ះពាល់ដល់សីលធម៌សង្គមថែមទៀត។ ដោយអំពើបំពានខាងលើទាំងនេះជាអំពើដែលបំពានទៅកាន់ផ្លូវភេទដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌដូចគ្នាពិតមែនក៏ប៉ុន្តែពុំមែនមានលក្ខណៈដូចគ្នាទាំងស្រុងនោះឡើយ។

## ២.ចំណោទបញ្ហានៃការដោះស្រាយ

ការសិក្សាទៅលើបទល្មើសទាំងពីរនេះ មានសារៈសំខាន់ខ្លាំងណាស់ដើម្បីជាពុទ្ធិបន្ថែមក្នុងការយល់ដឹងកាន់តែច្បាស់ពីអំពើបំពានខាងផ្លូវភេទផ្សេងៗ ដែលយើងតែងតែឃើញកើតមានឡើងនៅក្នុងសង្គមរបស់យើងជា ញឹកញាប់ លើសពីនេះទៅទៀតក៏អាចជាជំនួយបន្ថែមក្នុងការបែងចែងឱ្យដាច់ពីបទល្មើសរំលោភសេពសន្ថវៈ និងបទល្មើសប្រទូស្តកេរខ្មាសដើម្បីមិនឱ្យមានការយល់ច្រឡំរវាងបទល្មើសទាំងពីរនេះទៀត។ ដើម្បីដោះស្រាយបញ្ហាទាំងនេះបានយើងគួរតែយល់អំពីចំណោទនៃបញ្ហាដែលមាននៅក្នុងនោះឱ្យបានកាន់តែច្បាស់ជាមុនសិន។

តើបទល្មើសរំលោភសេពសន្ថវៈ និងបទល្មើសប្រទូស្តកេរខ្មាសនេះមានលក្ខណៈយ៉ាងដូចម្តេច? តើនៅក្នុងបទល្មើសទាំងពីរនេះមាននូវធាតុផ្សំអ្វីខ្លះ? ហើយថាតើនៅក្នុងបទល្មើសទាំងពីរនេះមាននូវលក្ខណៈដូចគ្នា និងលក្ខណៈខុសពីគ្នាបែបណាខ្លះ?

## ៣.គោលបំណងនៃការស្រាវជ្រាវ

ដើម្បីជាការឆ្លើយតបទៅនឹងចំណោទបញ្ហាខាងលើ ការស្រាវជ្រាវនៃប្រធានបទមួយនេះ គឺធ្វើឡើងក្នុងគោលបំណងដើម្បីធ្វើការចែករំលែក និងធ្វើការសិក្សាឱ្យកាន់តែស៊ីជម្រៅបន្ថែមទៅទៀតទៅលើបទល្មើសរំលោភសេពសន្ថវៈ និងបទល្មើសប្រទូស្តកេរខ្មាស។ ម្យ៉ាងវិញទៀតយើងនឹងធ្វើការសិក្សាទៅលើការប្រៀបធៀបអំពីលក្ខណៈប្រហាក់ប្រហែលមួយចំនួន និងលក្ខណៈខុសគ្នារវាងបទល្មើសទាំងពីរដើម្បីឱ្យយល់កាន់តែច្បាស់ទៅលើប្រធានបទយើងខ្ញុំ។ មិនតែប៉ុណ្ណោះការស្រាវជ្រាវប្រធានបទនេះ ក៏ដើម្បីចែករំលែកអំពីបទល្មើសទាំងពីរនេះឱ្យកាន់តែមានភាពទូលំទូលាយដើម្បីកាត់បន្ថយនូវការរំលោភបំពានខាងផ្លូវភេទបន្តទៀត ដើម្បីជាចំណែកមួយក្នុងការលើកកម្ពស់សីលធម៌សង្គមឱ្យកាន់តែប្រសើរឡើង។

## ៤.ទំហំនិងដែនកំណត់នៃការស្រាវជ្រាវ

ដើម្បីដោះស្រាយនូវបញ្ហាចោទខាងលើ យើងខ្ញុំសូមអនុញ្ញាតលើកយកបទល្មើសតែពីរប៉ុណ្ណោះដើម្បីយកមកធ្វើការសិក្សាដែលនោះរួមមានបទល្មើសរំលោភសេពសន្ថវៈ និងបទល្មើសប្រទូស្តកេរខ្មាសដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាដែលត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ប៉ុណ្ណោះ ដើម្បីយកមកធ្វើជាជំនួយក្នុងការសិក្សាឱ្យកាន់តែលម្អិតនៅលើប្រធានបទនេះ។ ចំពោះបញ្ញត្តច្បាប់ពិសេសផ្សេងៗ ទៀតដែលមានបញ្ញត្តទាក់ទងនឹងបទល្មើសទាំងពីរនេះយើងខ្ញុំក៏បានរំលេចឡើងផងដែរដើម្បីជាជំនួយក្នុងការសិក្សាបន្ថែមទៀត។

## ៥.សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ការស្រាវជ្រាវនេះមាននូវសារៈប្រយោជន៍ណាស់ចំពោះនិស្សិត និងអ្នកច្បាប់ផ្សេងទៀតយកទៅធ្វើការសិក្សាស្វែងយល់បន្ថែម ដើម្បីជាជំនួយស្មារតីក្នុងការសិក្សាដែលទាក់ទងទៅនឹងបទល្មើសរំលោភសេពសន្ថវៈ និងបទល្មើសប្រទូស្តកេរខ្មាស ជាពិសេសចំពោះការសិក្សាដែលទាក់ទងទៅនឹងការប្រៀបធៀបរវាងបទល្មើសទាំងពីរនេះ។ បន្ថែមពីលើនេះទៅទៀតការស្រាវជ្រាវនេះនឹងចូលរួមជាចំណែកមួយ នៅក្នុងការផ្សព្វផ្សាយច្បាប់ឱ្យកាន់តែស៊ីជម្រៅទៅកាន់សាធារណៈជនបានយល់បន្ថែមទាក់ទងទៅនឹងវិធាននៃច្បាប់។

## ៦.វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

ដើម្បីសិក្សាស្រាវជ្រាវឱ្យកាន់តែលម្អិតទៅលើប្រធានបទនេះ យើងខ្ញុំទាំងពីរបានព្យាយាមស្វែងរកនូវប្រភពនៃឯកសារច្បាប់នានាដើម្បីជាជំនួយក្នុងការបកស្រាយឱ្យកាន់តែស៊ីជម្រៅបន្ថែមទៀត។ ដែលឯកសារទាំងនោះយើងខ្ញុំបានដកស្រង់ចេញពីប្រភពមួយចំនួនរួមមាន ឯកសារច្បាប់ វិធានបទដ្ឋានគតិយុត្ត ក៏ដូចជាសៀវភៅជំនួយស្មារតី ផ្សេងៗ ទៀតដែលត្រូវបានបោះពុម្ពផ្សាយដើម្បីធ្វើការសិក្សាជាដើម។ យើងខ្ញុំបានធ្វើការពិភាក្សាគ្នាហើយព្រមទាំងសម្រិតសម្រាំង និងធ្វើការវិភាគដើម្បីជ្រើសរើសយកនូវចំណុចនៃខ្លឹមសារសំខាន់ៗយកមកបញ្ចូលទៅក្នុងកិច្ចការសិក្សាស្រាវជ្រាវ នៃប្រធានបទយើងខ្ញុំដែលធ្វើឱ្យសារណាយើងលេចឡើងដោយមានូវប្រភពយ៉ាងច្បាស់លាស់។

## ៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីផ្តល់ភាពងាយស្រួលក្នុងការសិក្សាលើប្រធានបទនេះ យើងបានធ្វើការបែងចែកប្រធានបទនេះទៅជា៣ជំពូកធំៗ ដោយនៅក្នុង **ជំពូកទី១** យើងនឹងបកស្រាយទាក់ទងទៅនឹងបទល្មើសនៃបទរំលោភសេពសន្ថវៈ រីឯនៅក្នុង **ជំពូកទី២** យើងនឹងធ្វើការបកស្រាយទាក់ទងទៅលើបទល្មើសប្រទូស្តកេរខ្មាស និងនៅក្នុង **ជំពូកទី៣** យើងនឹងធ្វើការសិក្សាទៅលើការប្រៀបធៀបរវាងបទល្មើសទាំងពីរនេះតែម្តង។

# ជំពូកទី១

# បទល្មើស

# រំលោភសេពសន្ថវៈ

# ជំពូកទី១

# បទល្មើសរំលោភសេពសន្ថវៈ

## ១.១ និយមន័យនៃបទល្មើសរំលោភសេពសន្ថវៈ

បទរំលោភសេពសន្ថវៈ យើងអាចពិនិត្យទៅលើទិដ្ឋភាពផ្សេងៗ នៃនិយមន័យដែលមានកំណត់កន្លងមកដូចជាមានចែងនៅក្នុងច្បាប់ផ្អែកតាមក្រមព្រហ្មទណ្ឌឆ្នាំ២០០៩។ យើងអាចពិចារណាបានយ៉ាងច្បាស់ពីទស្សនៈពាក់ព័ន្ធនឹងបទល្មើសរំលោភសេពសន្ថវៈ។

តាមរយៈវចនានុក្រម បានផ្តល់នូវន័យ ពាក្យរំលោភ មានន័យថាបំពានដោយសេចក្តីលោភបំពានទាំងអំណាច បង្រ្កបលើប្រព្រឹត្តល្មើស។[1] **សេព** មានពហុន័យភាពច្រើនប៉ុន្តែមានន័យមួយដែលទាក់ទងទៅនឹងការបំពានផ្លូវភេទ គឺសេពមានន័យថា រួមបវេណី។[2] **សន្ថវៈ** សំដៅដល់ដំណើរជិតដិត និងគ្នាការស្និទ្ធជិតនឹងគ្នា។[3] ការរួមសុខទុក្ខ ការធ្វើមេថុនសេវនកិច្ច ដូចនេះបានន័យថាអំពើ **រំលោភសេពសន្ថវៈ** គឺបានកំណត់អំពីន័យរបស់ពាក្យសេពសន្ថវៈ គឺជាសទិសន័យនឹងពាក្យ សេពមេថុនធម្មដែលមានន័យថាជាការរួមបវេណី។

តាមរយៈវាក្យស័ព្ទគតិយុត្ត ការឱ្យនិយមន័យលើបទល្មើសនេះតាមការវិវត្ត នៃសម័យកាលខុសៗពីគ្នា។ ក្រមព្រហ្មទណ្ឌចាស់ ឆ្នាំ១៩៣៤ ត្រង់ មាត្រា៤៤៣ បានប្រើពាក្យដូចគ្នា និងក្រមព្រហ្មទណ្ឌខេមរៈទាំងពីរខាងលើថា«អំពើកំហែងចាប់ចង»។[4]

ក្រមព្រហ្មទណ្ឌ២០០៩ បានកំណត់ន័យបទរំលោភសេពសន្ថវៈគឺគ្រប់អំពើបញ្ចូលអង្គជាតិតាមបែបណាក៏ដោយ ឬការបញ្ចូលឧបករណ៍ណាមួយទៅក្នុងអង្គជាតដែលប្រព្រឹត្តទៅលើអ្នកដទៃទោះបីភេទដូចគ្នា ឬមិនដូចគ្នាក៏ដោយ ដោយការប្រើហិង្សា ការបង្ខិតបង្ខំ ការគំរាមគំហែងឬដោយការឆ្មក់ឱកាស។[5]

## ១.២.ធាតុផ្សំនៃបទល្មើសរំលោភសេពសន្ថវៈ

យោងតាមគោលការណ៍នៃនីតិព្រហ្មទណ្ឌ ដើម្បីចាត់ទុកថាអំពើណាមួយជាបទល្មើសបាន តម្រូវឱ្យមានការបំពេញនូវលក្ខខណ្ឌនៃធាតុផ្សំទាំងបី គឺធាតុផ្សំនីត្យានុកូល ឬ ធាតុច្បាប់  ធាតុសត្យានុម័ត ឬ ធាតុ

[1] វចនានុក្រមសម្តេចសង្ឃរាជ ជួន ណាត

[2] វចនានុក្រមសម្តេចសង្ឃរាជ ជួន ណាត

[3] វចនានុក្រមសម្តេចសង្ឃរាជ ជួន ណាត

[4] នីតិព្រហ្មទណ្ឌពិសេស សាស្ត្រាចារ្យ កើត រិទ្ធ ឆ្នាំ២០១៥

[5]ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ មាត្រា២៣៩

សម្ភារ និងធាតុអត្តនោម័ត ឬធាតុផ្លូវចិត្ត ពោលគឺនៅក្នុងបណ្តាលធាតុទាំងបីនេះ បើមានបាត់នូវវត្តមានធាតុណាមួយនោះគេពុំអាចធ្វើការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌបានទេ។ ចំពោះធាតុផ្សំទាំងបីនេះត្រូវបាននីតិករបញ្ចូលបន្សំទៅក្នុងការ ចងក្រងនូវមាត្រា ស្តីពីបទល្មើសព្រហ្មទណ្ឌដែលធ្វើឱ្យខ្លឹមសារទាំងឡាយនៅក្នុងមាត្រាច្បាប់អាចឱ្យយើងទាញចេញមកបំបែកវាជាធាតុផ្សំទាំងបី។[6]

### ១.២.១ ធាតុផ្សំនីត្យានុកូល

ធាតុនីត្យានុកូលបានសេចក្តីថា ការកំណត់អំពើណាមួយជាបទល្មើសបាន លុះត្រាតែមានចែងក្នុងច្បាប់បើច្បាប់ពុំបានចែងទេនោះមិនអាចកំណត់ថាអំពើនោះជាបទល្មើសបានឡើយ។ ជាគោលការណ៍បទល្មើសបទរំលោភសេពសន្ថវៈមានចែងនៅក្នុង មាត្រា២៣៩ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ត្រង់កថាខណ្ឌទី១ បានឱ្យសញ្ញាណជាធាតុនីត្យានុកូលស្រប និងមាត្រា៣ នៃក្រមថ្មី។ ចំពោះ នីតិភាពនៃការរួមភេទ ត្រូវបានកំណត់ចាប់ពីអាយុ១៥ (ដប់ប្រាំឆ្នាំ) ឡើងទៅ។ មានន័យថាច្បាប់ទទួលស្គាល់នូវលទ្ធភាពដែលបុគ្គលអាចសម្តែងឆន្ទៈខាងផ្លូវភេទចាប់ពីអាយុ ១៥ ឆ្នាំឡើងទៅ។ នៅពេលដែលបុគ្គលដែលមានអាយុ១៥ឆ្នាំ ហើយ គេអាចបង្ហាញអំពីឆន្ទៈយល់ព្រមក្នុងការរួមភេទជាមួយភាគីម្ខាងទៀតបានដែលឆន្ទៈនេះជាឆន្ទៈដែលមានសុពលានុភាពគតិយុត្ត។[7] បន្ថែមពីលើនេះទៀត កាលបើបុគ្គលនោះពុំទាន់មានអាយុគ្រប់១៥ឆ្នាំទេ ការយល់ព្រម ឬ ការសម្តែងឆន្ទៈយល់ព្រមក្នុងរឿងរួមបវេណីដោយពុំមានការទទួលស្គាល់ឡើយថាជាការព្រមព្រៀង បានន័យថាជាឆន្ទៈអសុពលានុភាពគតិយុត្តដែលអំពើនេះជាបទល្មើសព្រហ្មទណ្ឌ។ បទរំលោភសេពសន្ថវៈត្រូវបានគេយល់នៅក្នុងក្រមព្រហ្មខេមរៈ ឆ្នាំ១៩០៩ ត្រង់មាត្រា ២២៥ មាត្រា២២៦ មាត្រា២២៧ ដោយប្រើពាក្យថា«**កំហែងចាប់ចង់**» និងក្រមព្រហ្មទណ្ឌខេមរៈឆ្នាំ១៩២៩ ត្រង់មាត្រា៤២៣ មាត្រា ៤៤៣ មាត្រា៤៤៦ក៏ប្រើពាក្យ«**កំហែងចាប់ចង់**»។

ចំណែកក្រមព្រហ្មទណ្ឌចាស់ ឆ្នាំ១៩៣៤ត្រង់ មាត្រា៤៤៣ បានប្រើពាក្យដូចគ្នា និងក្រមព្រហ្មទណ្ឌខេមរៈទាំងពីរខាងលើថា «**អំពើកំហែងចាប់ចង់**»។ រីឯក្រមព្រហ្មទណ្ឌចាស់ឆ្នាំ១៩៥៦ ត្រង់ មាត្រា៤៤៣ គឺជាបទល្មើស «កំហែងរួមបវេណីដល់ទីជម្រៅ» ហើយបញ្ញត្តិនេះមានន័យមិនខុសពីបញ្ញត្តិព្រហ្មទណ្ឌក្នុង ឆ្នាំ ១៩៣៤ ប៉ុន្មានទេ គឺចារីជាប្រុស ជនរងគ្រោះជាស្រីហើយធាតុសម្ភារជាការបញ្ចូលអង្គជាត។ ចំណែកច្បាប់ព្រហ្មទណ្ឌសម័យអន្តរកាល ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២ ចែងនៅត្រង់មាត្រា៣៣ថាជា « **បទរំលោភសេពសន្ថវៈ**» ជនណាក៏ដោយដែលរំលោភសេពសន្ថវៈ ឬប៉ុនប៉ងរំលោភសេពសន្ថវៈលើជនម្នាក់ទៀត ទោះជា

[6] http://www.pheakdeylaw.com/kh/publication/45

[7] សុពលានុភាពគតិយុត្ត មានន័យថា សុពល និងអានុភាព

ភេទដូចគ្នា ឬមិនដូចគ្នាក៏ដោយត្រូវមានទោសពីបទរំលោភសេពសន្ថវៈ ហើយផ្តន្ទាទោសដាក់ពន្ធនាគារជាបទឧក្រិដ្ឋ ពី៥ (ប្រាំ)ឆ្នាំ ទៅ១០ (ដប់)ឆ្នាំ។ បទរំលោភសេពសន្ថវៈ គឺជាអំពើបញ្ចូលអង្គជាតដោយឃោរឃៅ ដោយបង្ខំ ឬ ដោយមិនដឹងខ្លួនជាមុន។[8] មួយវិញទៀតនៅក្នុងបរិបទនៃច្បាប់ព្រហ្មទណ្ឌសម័យអន្តរកាលនេះ យើងសង្កេតឃើញថាមានភាពជឿនលឿនជាងបញ្ញត្តច្បាប់ មុនៗត្រង់ថាមានការបើកទូលាយនៃវិសាលភាព បទល្មើសរំលោភសេពសន្ថវៈដោយពុំកម្រិតភេទទេ គឺចារីអាចជាស្រី ឬជាប្រុស ហើយជនរងគ្រោះក៏អាចជាមានភេទដូចគ្នា ឬផ្ទុយគ្នា។ មិនតែប៉ុណ្ណោះ ក្រៅពីមធ្យោបាយចាប់បង្ខំ គំរាមគំហែង ក្នុងបញ្ញត្តិនេះក៏មានការបញ្ជាក់ពីការមិនដឹងខ្លួនជាមុនរបស់ជនរងគ្រោះផងដែរដែលនេះ គឺជាចំណុចបន្ថែមពីការមិនព្រមព្រៀង។ មាត្រាក្រោយនេះត្រូវបានកែប្រែដោយច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋដែលប្រកាសអោយប្រើដោយ ព្រះមហាក្សត្រក្នុងព្រះរាជក្រមចុះថ្ងៃទី៧ ខែមករា ឆ្នាំ២០០២ ត្រង់មាត្រា៥ គឺបានប្រើពាក្យថា«បទរំលោភសេពសន្ថវៈ»ផងដែរ។

### ១.២.២.ធាតុផ្សំសត្យានុម័ត

ធាតុសត្យានុម័ត ឬធាតុសម្ភារ គឺជាអំពើ ឬដំណើរការនៃការប្រព្រឹត្តបទល្មើសដែលស្តែងចេញមកខាងក្រៅនៃចារី ឬអាចកំណត់ថាជាធាតុនៃបទល្មើសដែលយើងអាចមើលឃើញខាងក្រៅបាន។ ធាតុនេះជាធាតុផ្សំមួយដែលបង្កើតឲ្យមានជាភស្តុតាងដល់ជាប្រយោជន៍ក្នុងការដាក់បន្ទុក។ ជាងនេះទៀតធាតុនេះក៏ជាធាតុមួយដែលជាបច្ច័យដែលញ៉ាំងឱ្យគេអាចកំណត់បាននូវធាតុខាងក្នុងដែលយើង ស្គាល់ថាជាធាតុអត្តនោម័តនោះផងដែរ។ ដើម្បីអាចបំពេញនូវធាតុសត្យានុម័តនេះគឺតម្រូវឱ្យបំពេញនូវធាតុផ្សំសំខាន់ តូចៗចំនួន ៣ (បី) ទៀតទី១**ហេតុ**គឺជាហេតុដែលនាំឲ្យមានព្យសនកម្ម គឺជាបទល្មើស ទី២**ព្យសនកម្ម** គឺជាផលវិបាកនានាដែលកើតមានដោយសារបទល្មើស និងទី៣**ទំនាក់ទំនងហេតុនិងផល** គឺតម្រូវឲ្យបទល្មើសជាហេតុដែលនាំឲ្យមានព្យសនកម្មហើយព្យសនកម្មដាច់ខាតជាវិបាកដែលកើតមានដោយសាតែបទល្មើសនោះ។ ធាតុតូចៗទាំង៣(បី)នេះប្រសិនបើអវត្តមាននូវធាតុណាមួយនាំឱ្យធាតុសត្យានុម័តពុំបានបំពេញឡើយ ហើយនាំឱ្យមានបទល្មើសខ្វះធាតុផ្សំពុំអាចធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌបានឡើយ។

បើយើងពិនិត្យទៅលើពាក្យពេចន៍ មាត្រា២៣៩ នៃក្រមព្រហ្មទណ្ឌ២០០៩ យើងអាចសិក្សាបានយ៉ាងលម្អិតលើធាតុសត្យានុម័តនៃបទរំលោភសេពសន្ថវៈជាចំណុច ដូចជា៖

[8] នីតិព្រហ្មទណ្ឌពិសេស សាស្ត្រចារ្យ កើត រិទ្ធ ឆ្នាំ២០១៥

### ១.២.២.១.ការប្រើហិង្សា

ការប្រព្រឹត្តអំពើបញ្ចូលអង្គជាត ឬបញ្ចូលឧបករណ៍ណាមួយដោយការប្រើប្រាស់នូវអំពើហិង្សា គឺជាការប្រើហិង្សាផ្នែករូបរាងកាយទៅលើជនរងគ្រោះ។ ចំពោះពាក្យថាហិង្សាមានភាពទូលំទូលាយជាងពាក្យវាយតប់ ទាត់ ធាក់ ពោលហិង្សា គឺជាការបៀតបៀនទៅលើរូបរាងកាយរបស់អ្នកដទៃដោយចេតនាតាមគ្រប់មធ្យោបាយទុច្ចរិតដែលបណ្តាលឲ្យមានព្យសនកម្មជាផ្លូវកាយ ឬផ្លូវចិត្តមានរបួស ឬគ្មានរបួស។ ភាពដាច់ខាតនៃហិង្សា គឺត្រូវតែប្រព្រឹត្តទៅលើជនដែលរងគ្រោះ ដូចជាការវាយ តប់ ទាត់លើជនរងគ្រោះជាដើម។[9] តែនៅក្នុងករណីមួយចំនួនរូបរាងកាយរបស់ជនរងគ្រោះពុំត្រូវបានទទួលរងហិង្សាដោយផ្ទាល់ក៏ដោយក៏ចាត់ទុកថាជាការប្រព្រឹត្តហិង្សាដែរ ដូចជាការដេញវាយតែជនរងគ្រោះគេច ឬ ការបាញ់បញ្ឆិតត្រចៀកជនរងគ្រោះជាដើម។

ហេតុនេះព្រោះតែបំណងរបស់ចារី គឺការប្រើហិង្សាលើជនរងគ្រោះហើយព្យសនកម្មកើតមានចំពោះជនរងគ្រោះផងដែរ គឺព្យសនកម្មខាងផ្លូវចិត្តដែលធ្វើឱ្យជនរងគ្រោះមានការភិតភ័យតក់ស្លុតជាដើម។ គួរកត់ចំណាំផងដែរថាករណីនេះអំពើហិង្សា គឺកើតមាននូវសកម្មភាពរួចទៅហើយដែលខុសគ្នាពីការគំរាមថានឹងប្រើហិង្សា ប៉ុន្តែពុំទាន់កើតមាននូវសកម្មភាពណាមួយឡើយដោយគ្រាន់តែគំរាមហើយ ម្យ៉ាងសកម្មភាពដែលបញ្ជាក់ពីការប៉ុនប៉ងហិង្សាក៏ពុំទាន់បានបញ្ចេញមកនៅឡើយដែរ។ រីឯករណីដែលមានការប្រើប្រាស់លើវត្ថុផ្សេងៗមានដូចជាការច្រាន ឬបុកទម្លុះទ្វារបន្ទប់ជនរងគ្រោះ បោកសម្ភាររបស់ជនរងគ្រោះពុំមែនជាកម្មវត្ថុនៃការប្រព្រឹត្តហិង្សានោះទេតែក្នុងករណីខ្លះអាច ជាការគំរាមកំហែងដូចជាករណីដែលចារីមានចេតនាបោកកែវ ឬចូដើម្បីបង្កើតស្ថានភាពមួយក្នុងគោលបំណងដើម្បីឱ្យជនរងគ្រោះភ័យខ្លាច។

### ១.២.២.២.ការបង្ខិតបង្ខំ ឬ ការគំរាមកំហែង

ជាទូទៅសញ្ញាណនៃការបង្ខិតបង្ខំ គឺជាអំពើផ្នែកផ្លូវកាយមួយ ដែលបង្កើតជាស្ថានភាពដាក់សម្ពាធដល់ជនរងគ្រោះទាំងផ្លូវកាយនិងផ្លូវចិត្តដើម្បីឱ្យខ្លួនជាចារីប្រព្រឹត្តនូវសកម្មភាពបញ្ចូលអង្គជាត ឬឧបករណ៍ណាមួយទៅលើជនរងគ្រោះបាន។ ការបង្ខិតបង្ខំអាចក្រោមរូបភាពជាច្រើនក្នុងនោះការគំរាម ការគំហែងការប្រើហិង្សាក៏ជារូបភាពនៃការបង្ខិតបង្ខំផងដែរ។ ដូច្នេះ ការបង្ខិតបង្ខំមានវិសាភាពនៃន័យដែលវាជាវាក្យសព្ទមួយ ញ៉ាំងឱ្យយើងងាយយល់ពីទុច្ចរិតភាពនៃចារីបានយ៉ាងច្បាស់ ព្រមទាំងសង្កត់ន័យយ៉ាងជាក់លាក់សម្រាប់ការកំណត់នូវធាតុផ្សំសត្យានុម័តនៃបទរំលោភសេពសន្ថវៈ។

[9] នីតិព្រហ្មទណ្ឌពិសេស សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០១៣-២០១៤

ចំពោះការគំរាមកំហែង គឺជារូបភាពមួយនៃការបង្ខិតបង្ខំដែលវា គឺជាអំពើសត្យានុម័តសម្តែងចេញលើផ្លូវកាយ និងផ្លូវចិត្តរបស់ជនរងគ្រោះ ដែលចារីបង្កើតឱ្យមានស្ថានភាពមួយគំរាម ឬ កំហែងក្នុងចេតនាធ្វើឱ្យជនរងគ្រោះភ័យខ្លាច។ ដូចសេចក្តីបញ្ជាក់ក្នុងវចនានុក្រមខ្មែរថា គំរាមកំហែងគឺជាការធ្វើឱ្យខ្លាច។ ដូចនេះខ្លាច គឺជាកម្មវត្ថុនៃការគំរាមកំហែង ហើយការគំរាមកំហែង អាចធ្វើឡើងក្នុងសភាពជាអំពើដូចជា៖

- ការគំរាមកំហែងថានឹងទុកចោលកណ្តាលព្រៃស្ងាត់តែម្នាក់ឯង
- ការគំរាមកំហែងនឹងប្រព្រឹត្តអំពើហិង្សាដោយចារី ឬដោយជនសមគំនិតណាមួយ
- ការគំរាមកំហែងថានឹងប្តឹងទៅតុលាការក្នុងរឿងណាមួយ
- ការគំរាមកំហែងថានឹងចាប់ ឬធ្វើបាបឪពុកម្តាយ សាច់ញាតិបងប្អូនដែលជាសមាជិកក្នុងគ្រួសារ
- ការគំរាមកំហែងថានឹងបកអាក្រាតនូវរឿង ឬរូបភាពអាក្រក់របស់យើង។[10]

រាល់ការគំរាមទាំងអស់នេះ គ្រាន់តែជាលក្ខខណ្ឌនៃការដាក់សម្ពាធដល់ជនរងគ្រោះប៉ុណ្ណោះ ក៏ប៉ុន្តែការប្រព្រឹត្តអំពើជាក់ស្តែងពុំទាន់មានកើតឡើងនោះឡើយ។ យ៉ាងណាមិញការគំរាមកំហែងថាវាយលើជនរងគ្រោះប្រសិនបើជនរងគ្រោះមិនព្រមជាមួយខ្លួននោះចារី និងប្រព្រឹត្តនៅសកម្មភាពដូចដែលបានគំរាមកំហែង ហើយការគំរាមនេះអាចកើតមានឡើងជាសកម្មភាពជាក់ស្តែង។

**១.២.២.៣.ការឆ្មក់ឱកាស**

ការឆ្មក់ឱកាស គឺជាករណីមួយដែលបានកំណត់ក្នុងក្រមព្រហ្មទណ្ឌ២០០៩ ដែលបានយោងចេញអំពីវាក្យសព្ទ ដោយមិនដឹងខ្លួនជាមុនដែលមានកំណត់ក្នុងបទដ្ឋានគតិយុត្តព្រហ្មទណ្ឌចាស់ គឺច្បាប់ព្រហ្មទណ្ឌអន្តរកាល និងច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។ ការបញ្ចូលអង្គជាត ឬ ឧបករណ៍ផ្សេងៗដោយការឆ្មក់ឱកាស សំដៅទៅលើអំពើដែលធ្វើឡើងដោយមិនឱ្យជនរងគ្រោះដឹងខ្លួនថាមានគេចង់ប្រព្រឹត្តអំពើមិនគប្បីមកលើជនរងគ្រោះឡើយ។ អំពើរបៀបនេះអាចប្រព្រឹត្តនៅពេលដែលជនរងគ្រោះ៖

- កំពុងដេកលក់ដោយស្មានថាជាប្តីរបស់ខ្លួន
- ត្រូវថ្នាំសណ្តំ
- ប្រើប្រាស់ថ្នាំ ឬស្រវឹងស្រាហួតដល់មិនដឹងខ្លួន
- ជាជនវិកលចរិតជាដើម។

[10] នីតិព្រហ្មទណ្ឌពិសេស សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ី ណាត

**១.២.២.៤.អំពើបញ្ចូលអង្គជាត**

នៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ យើងឃើញថាមានការប្រើពាក្យពេចន៍ថា គ្រប់អំពើបញ្ចូលអង្គជាតតាមបែបណាក៏ដោយ ជាពាក្យពេចន៍ដែលបើកលទ្ធភាពក្នុងការបកស្រាយឱ្យបានគ្រប់គ្រាន់ស្របតាមវិវត្តភាពនៃបទល្មើសតាមសម័យកាល។

នៅក្នុងឃ្លាគន្លឹះនេះ យើងឃើញពាក្យអង្គជាតជាពាក្យមួយដែលគប្បីឱ្យយើងផ្តល់នូវន័យនៃពាក្យនេះផងដែរ។ ពាក្យ អង្គជាត ដែលមានការច្រឡំថាអង្គជាតិហើយការសរសេរអង្គជាតជាអង្គជាតិនេះយើងឃើញក្នុងអត្ថបទច្បាប់ព្រហ្មទណ្ឌចាស់ៗដូចជាក្រមព្រហ្មទណ្ឌឆ្នាំ១៩៣៤ ក្រមព្រហ្មទណ្ឌ១៩៥៦ជាដើម។ យោងតាមវចនានុក្រមខ្មែរដែលបានបោះពុម្ពដោយពុទ្ធសាសនាបណ្ឌិត្យឆ្នាំ១៩៦៧ត្រង់មេពាក្យអង្គ ពាក្យថាអង្គជាតិ ខាងលើសរសេរអង្គជាត យ៉ាងដូច្នេះដោយគ្មានស្រៈ(ិ) នៅលើពាក្យជាតនោះឡើយ។ ហើយអង្គជាតនេះទៀតសោធសម្តេច ជួន ណាត សរសេរថា ជា លិង្គ ឬ យោនី (កេរខ្មាសប្រុសនិងស្រ្តី) ។ ដូចនេះក្រៅពីលិង្គ និងយោនីពុំអាចឱ្យអ្នកបកស្រាយពង្រីកវិសាលភាពនៃន័យចំពោះពាក្យអង្គជាត នេះបានឡើយ។ មានវិវាទមតិមួយចំនួនលើពាក្យអង្គជាត និងពាក្យកេរភេទ។ តើពាក្យទាំងពីរនេះមានអត្ថន័យដូចគ្នា ឬខុសគ្នា? ត្រង់នេះយើងអាចបកស្រាយខ្លះយល់ថាកេរភេទមានលក្ខណៈទូទៅជាងអង្គជាតដែលបានកំណត់តែលិង្គ និងយោនី។ ការលើកឡើងនេះសំអាងទៅលើយុត្តសាស្ត្រជាក់ស្តែងទាក់ទង នឹងបទល្មើសបង្ហាញកេរភេទដែលករណី នារីម្នាក់បង្ហាញសុដន់ និងរាងកាយរបស់ខ្លួន ដោយស្លៀកតែខោក្នុង ក៏ត្រូវបានគេចាត់ថាជាកេរភេទដែរ។[11] សុដន់ ពុំមែនជាប្រដាប់ភេទទេ ត្រង់នេះយើងអាចកំណត់នូវន័យនៃកេរភេទដោយសន្មតថាជា ផ្នែកកេរខ្មាស នៃផ្លូវភេទដែលអាចបណ្តាលឱ្យមានអារម្មណ៍អៀនខ្មាស់ផ្នែកផ្លូវភេទ។

**ឧទាហរណ៍ទី១៖** សុដន់ ជាផ្នែកដែលនារីតែងបិទបាំង ឬជាផ្នែកកំបាំងនៃភេទស្រី។ ការបញ្ចូលអង្គជាត គឺសម្តៅដល់ការធ្វើឱ្យចូលនូវអង្គជាតទៅភាគីម្ខាងទៀត។ ពាក្យថាចូល គឺមានន័យថាទៅពីខាងក្រៅចូលទៅកាន់ខាងក្នុង។[12] ត្រង់នេះបញ្ជាក់ពីជម្រៅនៃការបញ្ចូល។ ហេតុនេះនាំឱ្យយើងអាចទាញបានថាការបញ្ចូលអង្គជាត គឺជាការធ្វើឱ្យអង្គជាត របស់ចារីចូលក្នុងទៅជម្រៅរបស់ភាគីជនរងគ្រោះ។

**ឧទាហរណ៍ទី២៖** ការបញ្ចូលអង្គជាតរបស់ជនល្មើសទៅក្នុងវច្ចមគ្គរបស់ជនរងគ្រោះ។ ការបញ្ចូលនេះ គឺបានដល់ ជម្រៅក្នុងវច្ចមគ្គ។[13]

---

[11] https://ams.com.kh/central/detail/33867

[12] វចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត

[13] វច្ចមគ្គ មានន័យថារន្ធគូត

ចំពោះសេចក្តីថាតាមបែបណាក៏ដោយ គឺបានដល់គ្រប់កន្លែងទាំងឡាយនៅលើរាងកាយ នៃភាគីរងគ្រោះដោយវិធីបញ្ចូលគ្រប់បែបពោលគឺមិនមែនទាល់តែបញ្ចូលនូវអង្គជាតទៅក្នុងអង្គជាតនោះទេ។

**ឧទាហរណ៍៖** ការបញ្ចូលអង្គជាតរបស់ចារីទៅក្នុងមាត់នៃជនរងគ្រោះ ក៏រាប់ថាជាបទល្មើសរំលោភសេពសន្ថវៈបានដែរ។ ការបញ្ចូលអង្គជាតអាចជាប្រយោជន៍ក្នុងការបន្សល់ទុកនូវភស្តុតាងដាក់បន្ទុកបានផងដែរ ដោយការពិនិត្យ ទៅលើការកកើតនៃអវយវៈភេទ វច្ចមគ្គជាអាទិ៍ ក៏ដូចជាទឹកកាម ដែលបានបន្សល់ទុកនៅខាងក្នុងនោះ។ ជាទូទៅ ភស្តុតាងទាំងនេះអាចទទួលបានដោយការពិនិត្យ និងតម្រូវឱ្យមានការព្រមព្រៀងពីជនរងគ្រោះផងដោយគោរពលើគោលការណ៍បូរណភាពនៃរូបរាងកាយបុគ្គល។

**ការបញ្ចូលឧបករណ៍** ដោយផ្អែកទៅលើការបញ្ញត្តិនៅក្នុងក្រមព្រហ្មទណ្ឌ២០០៩ យើងឃើញមានការប្រើពាក្យថា អំពើបញ្ចូលឧបករណ៍ណាមួយដែលត្រង់នេះ គឺសំដៅដល់ឧបករណ៍ដែលប្រើប្រាស់បម្រើឱ្យសម្រេកនៃតណ្ហាក្នុងការរួមភេទ ដូចជាលិង្គសិប្បនិម្មិត យោនីសិប្បនិម្មិត ដំបង ដៃ ជាអាទិ៍។ ត្រង់ពាក្យថាឧបករណ៍ណាមួយមិនបានកំណត់ឱ្យបានជាក់លាក់ទេដែលនេះជាការទុកលទ្ធភាពដើម្បីធ្វើការបកស្រាយ និងកំណត់បទល្មើសតាមជាក់ស្តែង។ ប៉ុន្តែយើងអាចសន្និតបានថាជា ឧបករណ៍ដែលបម្រើឱ្យតម្រេកតណ្ហាកាម ព្រោះថាបើឧបករណ៍ទាំងនោះពុំប្រើក្នុងការសម្រេចនូវ តម្រេកកាមទេវាក៏ពុំមានអ្វីដែលទាក់ទងនឹងបទល្មើសរំលោភសេពសន្ថវៈនេះផងដែរ។

**ឧទាហរណ៍៖** ក្នុងករណីនេះមាន អាចមានរូបភាពដូចជា ជនល្មើសបានបញ្ចូលលិង្គសិប្បនិម្មិតទៅក្នុងអង្គជាត ឬវច្ចមគ្គនៃជនរងគ្រោះជាដើម។

ចំណុចនេះ យើងពុំឃើញមានកំណត់នៅក្នុងអត្ថបទច្បាប់ចាស់ៗនោះទេ។ ហេតុនេះ ការបញ្ចូលចំណុចនេះ ទៅក្នុងនិយមន័យនៃបទល្មើសរំលោភសេពសន្ថវៈគឺជាការវិវត្តទៅតាមហេតុការណ៍ជាក់ស្តែង។

### ១.២.២.៥ អវត្តមាននៃការព្រមព្រៀង

ការរួមបវេណី ដែលមិនមានការព្រមព្រៀងវា គឺជាបទល្មើសរំលោភសេពសន្ថវៈដែលមានបញ្ញត្តនៅក្នុងច្បាប់ព្រហ្មទណ្ឌជាធរមាន។ មួយវិញទៀតការអវត្តមាននៃការព្រមព្រៀងវានាំឱ្យឈានទៅដល់ស្ថានភាពនៃការប្រព្រឹត្ត បទល្មើសដោយមានសកម្មភាព ដូចជាការចាប់បង្ខំ ការប្រើនូវអំពើហិង្សា ឬ ការគំរាមកំហែងឬជាសញ្ញាណនៃការឆ្នក់ឱកាស ដែលសកម្មភាពទាំងនេះ ជនល្មើសបានធ្វើឡើងក្នុងការប្រព្រឹត្តឱ្យមាននូវអំពើរំលោភដូចខាងលើតាមរយៈ រូបភាព នៃការបញ្ចូលអង្គជាតតាមបែបណាក៏ដោយ ឬ ក៏អំពើបញ្ចូលឧបករណ៍ណាមួយទៅក្នុងអង្គជាតរបស់បុគ្គលដទៃ ។

### ក. សញ្ញានៃការព្រមព្រៀង

ចំពោះការព្រមព្រៀង យើងអាចឱ្យន័យបានថាជាការសុខចិត្តមិនទទឹងទាស់គំនិតជាមួយស្រុះស្រួលជាមួយ អនុលោមតាម។[14] ទាក់ទងទៅនឹងបរិបទនីតិសាធារណៈដែលជាពិសេស គឺនីតិព្រហ្មទណ្ឌ ការព្រមព្រៀង គឺពុំចាំបាច់ទាល់តែមានសំណើទេ។ ម្យ៉ាងវិញទៀតចំពោះការប្រព្រឹត្តសកម្មភាពបំពានផ្លូវភេទដែលកើតឡើង តែជនរងគ្រោះមិនបដិសេធ ហើយបានបង្ហាញនូវអប្បកិរិយាបែបបើកទូលាយយល់ព្រមតាមការប្រព្រឹត្តសកម្មភាពបំពានផ្លូវភេទដែរនេះជាសញ្ញាណនៃការព្រមព្រៀងផងដែរ។ ជាមួយគ្នានេះផងដែរដូចជាករណីដែលសហព័ទ្ធជាស្វាមីធ្វើការបង្ហាញចំណង់ផ្លូវភេទរបស់ខ្លួនទៅកាន់ភរិយាហើយភរិយា ក៏បង្ហាញសកម្មភាពដែរជាការអនុញ្ញាតឱ្យស្វាមីរួមសមគ្គសង្វាសនេះហើយជាសញ្ញាណនៃការព្រមព្រៀងដោយពុំចាំបាច់មានសំណើមក ភាគីម្ខាងទៀត។

ដោយឡែកនៅក្នុងនីតិឯកជនវិញ ការព្រមព្រៀងកើតឡើងបានលុះត្រាតែមានសំណើ ពោលគឺបើគ្មានអ្នកណាស្នើអ្វីមកកាន់ទេគឺមិនអាចកើតមានឡើងនូវការព្រមព្រៀងឡើយ។ មិនតែប៉ុណ្ណោះសម្រាប់សំណើដែលបានស្នើមកនោះត្រូវមានការបង្ហាញនូវស្វីការ ទើបការព្រមព្រៀងមានអត្ថិភាពកើតឡើង។[15] ជាក់ស្តែងការព្រមព្រៀងយើងអាចបែងចែកជា ៤ប្រភេទ ដែលនេះក៏ជាសញ្ញាណនៃការព្រមព្រៀង។

**ការព្រមព្រៀងតាមផ្លូវកាយ** ៖ ជាការសម្តែងការព្រមព្រៀង តាមអំពើដែលបានសម្តែងចេញមកដូចជា ការងក់ក្បាល ឬ ការបោយដៃ ការធ្វើសញ្ញាបញ្ជាក់ពីការព្រមព្រៀងផ្លូវភេទសម្រាតកាយចាំជាស្រេចជាដើម។

**ការព្រមព្រៀងតាមផ្លូវវាចា** ៖ ជាការពោលពាក្យអនុញ្ញាត ឬពាក្យដែលមានសេចក្តីបញ្ជាក់ពីការអនុញ្ញាត ដែលភាគីអាចយល់ថាជាសញ្ញានៃ ការអនុញ្ញាត ឬ ព្រមព្រៀង ឬ អ្នកដទៃឯទៀតអាចដឹងបានយ៉ាងទូទៅថា ជាពាក្យបញ្ជាក់ពីការយល់ព្រមរួមភេទ។

**ការព្រមព្រៀងដោយសកម្ម** ៖ ជាការព្រមព្រៀងដែលសម្តែងចេញដោយអំពើតាមផ្លូវកាយ (កាយ និង វាចា) ការព្រមព្រៀងដោយសកម្ម ជាការព្រមព្រៀង ដែលជាក់ស្តែងនិងច្បាស់លាស់ ងាយនឹងកំណត់បាន។ ប៉ុន្តែវាក៏អាចត្រូវលើកចោលបានដែរក្នុងស្ថានភាព បង្ខិតបង្ខំ គំរាមកំហែង រងនូវអំពើហិង្សាជាដើម ពោលគឺក្នុងស្ថានភាពដែលការបង្ហាញឆន្ទៈពុំមានសេរីភាពពេញលេញនោះទេ។

[14] វចនានុក្រមសម្តេចព្រះអង្គរាជ ជួន ណាត

[15] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា៣៣៦ និងមាត្រា៣៣៧

**ការព្រមព្រៀងដោយតុណ្ហី** ៖ ជាការព្រមព្រៀងដោយស្ងាត់ឥតតបត។ វាជាការព្រមព្រៀង ដែលពុំអាចកំណត់ពីភាពច្បាស់លាស់នៃការព្រមព្រៀងបានឡើយ។ ការព្រមព្រៀងបែបនេះអាចមានការទទួលស្គាល់ក្នុងករណីមួយចំនួននៅក្នុងនីតិឯកជន ដូចជា ការបន្តភតិសន្យា នៅពេលដែលពេលកំណត់ជួលបានផុត ភាគីទាំងសងខាងពុំបង្ហាញឆន្ទៈក្នុងការបញ្ចប់ភតិសន្យា នាំឱ្យភតិសន្យាត្រូវបានបន្តក្នុងរូបភាពជា ភតិសន្យាដែលពុំកំណត់រយៈពេល។[16] ដោយឡែកក្នុងនីតិសាធារណៈ ការយល់ថាតុណ្ហីភាព ជាការព្រមព្រៀងត្រូវបានរិះគន់យ៉ាងខ្លាំង ជាពិសេសក្នុងករណីរំលោភសេពសន្ថវៈនេះជាដើម។ ហេតុនេះក៏ព្រោះតែតុណ្ហីភាព នេះជាទង្វើអកម្ម ពិបាកយកធ្វើជាប្រយោជន៍នៅក្នុងការបង្ហាញភស្តុតាងណាស់ ហើយនៅពេលខ្លះជនរងគ្រោះស្ថិតក្នុងស្ថានភាពបង្ខំ ឬ គំរាមកំហែង។ ដូចជាករណីដែលជនរងគ្រោះឃើញចារី មានកាំភ្លើងជាប់ដៃ ហើយជនរងគ្រោះស្ថិតក្នុងស្ថានភាពដែលមិនអាចគេចខ្លួនបាន។ ដើម្បីការពារជីវិត ទោះបីចារីពុំបានសម្តែងនូវសកម្មភាពដែលបង្ខិតបង្ខំដោយផ្ទាល់ ក៏ដោយជនរងគ្រោះមានតែនៅស្ងៀមក្នុងលក្ខណៈតុណ្ហីភាពប៉ុណ្ណោះ។[17] ហេតុនេះការព្រមព្រៀងដោយតុណ្ហីភាព ជាទូទៅពុំត្រូវបានទទួលថាជាការព្រមព្រៀងទាំងស្រុងទេក្នុងនីតិព្រហ្មទណ្ឌដែលតម្រូវឱ្យមានភស្តុតាងយកមកបន្ថែមទៀតរួមបញ្ចូក់។

**ខ.សច្ចធារណ៍នៃការយល់ព្រមក្នុងទំនាក់ទំនងអាពាហ៍ពិពាហ៍**

ជាក់ស្តែងនៅក្នុងទំនាក់ទំនងអាពាហ៍ពិពាហ៍ គេអាចសន្មតដោយសច្ចធារណ៍ថាជាការព្រមព្រៀង។ ប៉ុន្តែដូចយើងបានដឹងពីអានុភាពនៃសច្ចធារណ៍ក្នុងនីតិព្រហ្មទណ្ឌរួចមកហើយថាមានលក្ខណៈដាច់ខាត គឺអាចលើកចោលបានដោយភស្តុតាងផ្ទុយ។ ក្នុងករណីមានរួមសង្វាសរវាងប្តីប្រពន្ធត្រូវបានគេសន្មតដោយសច្ចធារណ៍ប៉ុណ្ណោះថាជាការព្រមព្រៀង ដូចដែរយើងធ្លាប់បានឃើញនៅក្នុងនិយមន័យនៃអាពាហ៍ពិពាហ៍ក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ ដែលត្រូវបានបាននិរាករណ៍ដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីថា អាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាដ៏ឱឡារិកមួយធ្វើឡើងដោយបុរសម្នាក់និងស្ត្រីម្នាក់ដែលប្តេជ្ញាថាខ្លួននឹងរួមសមគ្គសង្វាសជាមួយគ្នា តាមបញ្ញត្តិច្បាប់ហើយដែលមិនអាចរំលាយទៅវិញបានតាមទំនើងចិត្តរបស់ខ្លួន។

ក្នុងនិយមន័យនេះ យើងសង្កេតឃើញពាក្យថា សមគ្គសង្វាស ដែលពាក្យសមគ្គ នេះមានន័យថាព្រមព្រៀងនាំឱ្យសមគ្គសង្វាសបានសេចក្តីថា រួមសង្វាសដោយព្រមព្រៀង។ តែទោះជាយ៉ាងណានិយមន័យនេះលែងមាននីត្យានុកូលភាពទៀតហើយ។ រីឯការលើកយកនិយមន័យនេះមកវែកញែក គឺគ្រាន់តែជាការធ្វើវិភាគបែបគតិយុត្តតែប៉ុណ្ណោះ។ តែបើយើងក្រឡេកមក មើលនិយមន័យនៃបទល្មើសរំលោភសេពសន្ថវៈ

[16] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នា ២០០៧ មាត្រា៦១៤

[17] តុណ្ហីភាព គឺជាភាពស្ងៀមស្ងាត់ក្នុងការបង្ហាញឆន្ទៈដោយយោងតាមសន្ទានុក្រម នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ដូចដែលបានបកស្រាយនៅខាងលើមកត្រង់ពាក្យថា អ្នកដទៃគឺសម្តៅ យកបុគ្គលដែលក្រៅពីខ្លួនឯង។ ហេតុនេះភរិយាក៏ជាអ្នកដទៃផងដែរ ព្រោះមានបុគ្គលភាពផ្សេងគ្នា។ ទន្ទឹមនឹងនេះផងដែរ ក្រមព្រហ្មទណ្ឌក៏ពុំបានបញ្ជាក់ពីអញ្ញត្រកម្មលើកលែងចំពោះបទល្មើសរំលោភសេពសន្ថវៈនេះ ក្នុងការប្រព្រឹត្តទៅលើអ្នកដែលនៅក្នុងគ្រួសារ ឬ ភរិយាទេ។ ដរាបណាគ្មានការកំណត់អញ្ញត្រកម្មនោះទេ ទង្វើនេះនៅតែជាបទល្មើសព្រហ្មទណ្ឌដដែល។ ម្យ៉ាងវិញទៀត ដោយយោងតាមស្មារតីនៃ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ២០០៥ មាត្រា៣៥ បានចែងថាអំពើហិង្សាក្នុងគ្រួសារទាំងឡាយណាដែលចូលជាបទល្មើសព្រហ្មទណ្ឌ ត្រូវផ្តន្ទាទោសដោយយោងតាមច្បាប់ព្រហ្មទណ្ឌជាធរមាន។ រួមជាមួយនេះដែរ មាត្រា៣ និងមាត្រា៧ នៃច្បាប់ដដែលទៀតបញ្ញត្តិថាអំពើរំលោភសេពសន្ថវៈពិសេសការប្រើអំពើហិង្សា សេពសន្ថវៈ គឺជាផ្នែកមួយនៃការឈ្លានពានផ្លូវភេទ ដែលត្រូវចាត់ទុកជាអំពើហិង្សាក្នុងគ្រួសារ។[18] ដូចនេះ យើងអាចនិយាយជារួមបានថាការរួមសង្វាសរវាងស្វាមី ភរិយា អាចសន្មតថាជាការព្រមព្រៀង តែបើសិនជាមានភស្តុតាងផ្ទុយណាមួយមកបញ្ជាក់ផ្សេងទៀត នោះយើងក៏អាចអនុវត្តនូវអានុភាព នៃបទល្មើសព្រហ្មទណ្ឌ ពីបទរំលោភសេពសន្ថវៈក្នុងករណីនេះដែរ។

### ១.២.៣.ធាតុផ្សំអត្តនោម័ត

ធាតុអត្តនោម័ត គឺជាផ្នែកខាងក្នុងនៃបទល្មើសដែលផ្ទុយទៅនឹងធាតុសត្យានុម័តដែលជាផ្នែកខាងក្រៅនៃបទល្មើស។ ប្រសិនយើងវិភាគតាមដំណាក់កាលនៃបទល្មើស យើងឃើញថាធាតុអត្តនោម័ត កើតមានមុនធាតុសត្យានុម័ត។ ប៉ុន្តែដោយសារនៅក្នុងដំណើរការនៃការស៊ើបអង្កេត គេអាចស្វែងយល់ពីធាតុអត្តនោម័ត តាមរយៈធាតុសត្យានុម័តទើបនាំឱ្យគេរៀបលំដាប់លំដោយនៃធាតុផ្សំអត្តនោម័តបន្ទាប់ពីធាតុផ្សំសត្យានុម័ត។

ធាតុផ្សំអត្តនោម័ត គឺជាផ្លូវចិត្តរបស់ជនល្មើសចំពោះអំពើបង្កគ្រោះថ្នាក់ដល់សង្គមដែលគេបានប្រព្រឹត្ត និងចំពោះបច្ច័យដែលកើតឡើងពីអំពើនោះ។ ហើយធាតុផ្សំអត្តនោម័តនៃបទល្មើសនេះ គឺជាកំហុស អាចជាកំហុសកើតពីកំហុសចេតនា ឬ កំហុសអចេតនាណាមួយដែលចារីបានប្រព្រឹត្តត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ។[19] ចំណុច២(ពីរ) ផ្សេងទៀតដែលគួរពិចារណាផងដែរក្នុងផ្នែកអត្តនោម័តនៃបទល្មើសនេះ គឺគំនិតផ្តួចផ្តើមនៅក្នុងការប្រព្រឹត្តនូវបទល្មើស និងកម្មវត្ថុនៃការប្រព្រឹត្តបទល្មើស។

[18] នីតិព្រហ្មទណ្ឌពិសេស សាស្រាចារ្យ កើត រិទ្ធ ឆ្នាំ ២០១៥

[19] នីតិព្រហ្មទណ្ឌទូទៅ សាស្ត្រាចារ្យ រុណ ពណ្ណារិទ្ធ លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០១២

- **គំនិតផ្តួចផ្តើមប្រព្រឹត្តបទល្មើស៖** សំដៅដល់ស្ថានភាពដែលជនល្មើសមានស្មារតី គ្រប់គ្រាន់ក្នុងការ ប្រព្រឹត្តបទល្មើសជាសត្យានុម័ត ដែលជំរុញដោយកត្តាខាងក្នុងចិត្ត មានន័យថាកត្តាខាងក្នុងនៃចិត្ត របស់ជនល្មើស បានជំរុញឱ្យកត្តាខាងក្រៅជាសត្យានុម័តប្រព្រឹត្តបទល្មើស ដើម្បីសម្រេចបាននូវគោលដៅប្រព្រឹត្តបទល្មើសដែលខ្លួនចង់បាន។[20]
- **កម្មវត្ថុនៃបទល្មើស៖** គឺជាមុខព្រួញ ឬ ទិសដៅដែលប្រធាននៃបទល្មើស គឺជនល្មើស ចង់បង្កព្យសនកម្មលើ។ កម្មវត្ថុនៃបទល្មើសមានពីរបើតាមទស្សនៈដែល បានលើកឡើង គឺទី១ កម្មវត្ថុនៃបទល្មើស គឺជាច្បាប់ព្រហ្មទណ្ឌ (ជនល្មើសចង់ បំពានច្បាប់ព្រហ្មទណ្ឌ) និងទី២ កម្មវត្ថុនៃបទល្មើស គឺជាអ្វីដែលច្បាប់ការពារ (ឧទាហរណ៍៖ ជនល្មើសសម្លាប់មនុស្ស ដែលជីវិតមនុស្ស គឺជាកម្មវត្ថុដែលច្បាប់ការពារដូចបានកំណត់ថាពលរដ្ឋគ្រប់រូបមានសិទ្ធិរស់រានមានជីវិតជាដើម) ។[21]

### ១.២.៣.១ ចេតនាក្នុងប្រព្រឹត្ត

ចេតនាប្រព្រឹត្តបទល្មើស សំដៅទៅលើឆន្ទៈរបស់ចារីឆ្ពោះទៅរកការប្រព្រឹត្តបទល្មើសដែលបានកំណត់ដោយច្បាប់ ជាទូទៅមានចេតនាប្រព្រឹត្តបទល្មើសកាលបើចារីស្វែងរកលទ្ធផលខុសច្បាប់នេះ។ ដែលកំហុសក្នុងបទរំលោភសេពសន្ថវៈទោះបីជាបញ្ញត្តិទៅក្នុង មាត្រា២៣៩ នៃក្រមព្រហ្មទណ្ឌពិតមែន ក៏ប៉ុន្តែពុំបានបញ្ជាក់នូវវាក្យសព្ទ «ចេតនា» នោះទេតែយើងអាចកំណត់បានថា នៅក្នុងបទល្មើសនេះមិនអាចជាបទល្មើសដែលជាកំហុសបានកើតឡើងមកនោះជាកំហុសដែលអចេតនានោះឡើយ ព្រោះសកម្មភាពនៃសត្យានុម័តបទល្មើសកើតឡើងពីឆន្ទៈដោយក្រុមនៃជនល្មើសក្នុងចេតនាភាព (ភាពចេតនា) ដើម្បីប្រព្រឹត្តអំពើទុច្ចរិតរបស់ខ្លួន។ បន្ថែមពីលើនេះទៅទៀតជនល្មើសពុំអាចលើកឡើងមកដោយដោះសារថា ខ្លួនដេកមមើ ឬ ស្ថិតក្នុងស្ថានភាពស្រវឹងបាត់បង់សតិណាមួយ ដែលមិនអាចម្ចាស់ការលើខ្លួនឯង ហើយក៏ប្រព្រឹតអំពើជ្រុលជ្រួសទៅរំលោភសេពសន្ថវៈ លើជនរងគ្រោះ ដើម្បីជាកិច្ចវេសមិនទទួលខុសព្រហ្មទណ្ឌណាមួយឡើយ។ អំពើដែលចារីបានប្រព្រឹត្តចេញមកខាងក្រៅបានបញ្ជាក់ពីចេតនាដែលចារីមានបំណងទុច្ចរិត ដែលមិនអាចប្រកែកបាននោះទេ។

#### ក. ចេតនាទុច្ចរិតទូទៅ

ចេតនាទុច្ចរិតទូទៅនៃការប្រព្រឹត្តបទល្មើសរំលោភសេពសន្ថវៈក៏មិនខុសពីរចេតនាទូទៅនៃការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌនានាដែរ គឺចារីមានចេតនាប្រព្រឹត្តអំពើដែលខ្លួនបានដឹងរួចហើយថាច្បាប់ព្រហ្ម

[20] នីតិព្រហ្មទណ្ឌទូទៅ សាស្រ្តាចារ្យ រុណ ពណ្ណារិទ្ធ លោកស្រីសាស្រ្តចារ្យ ចាំង ស៊ីណាត ឆ្នាំ២០១២
[21] នីតិព្រហ្មទូទៅសាស្រ្តាចារ្យ ហ៊ី សោភា

ទណ្ឌបានហាមឃាត់។ ចារីមិនអាចលើកឡើងថាខ្លួនមិនបាន ដឹងថាអំពើរំលោភសេពសន្ថវៈត្រូវបានហាមឃាត់ដោយច្បាប់នោះទេ ព្រោះតាមគោលការណ៍គ្មាននរណាដែលមិនស្គាល់ ឬមិនយល់ដឹងអំពីច្បាប់។[22]

**ខ. ចេតនាទុច្ចរិតពិសេស**

បន្ថែមពីលើចេតនាទុច្ចរិតទូទៅខាងលើអ្នកនីតិប្បញ្ញត្តអាចបន្ថែមនូវចេតនាទុច្ចរិតពិសេស សម្រាប់បទល្មើសណាមួយ។ អ្នកនីតិប្បញ្ញត្តពុំបានប្រើពាក្យចេតនាទុច្ចរិតពិសេសនៅក្នុងបញ្ញត្តិច្បាប់ឡើយ ក៏ប៉ុន្តែផ្តើមចេញពីអត្ថបទច្បាប់ដែលបានកំណត់បទល្មើសនីមួយៗ អាចឱ្យគេយល់ពីបំណងរបស់អ្នកនីតិប្បញ្ញត្តិដែលទាមទារឱ្យរកនូវភស្តុតាងអំពីចេតនាទុច្ចរិតពិសេសមួយរបស់ចារី ដើម្បីឱ្យមានធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់។ ចេតនាទុច្ចរិតពិសេសមានទស្សនៈ ២ តាមទស្សនៈវិស័យនៃអ្នកច្បាប់ ដែលមានការបកស្រាយដូចខាងក្រោម។[23]

**ខ.១. ចេតនាទុច្ចរិតពិសេស ជាមូលហេតុនៃការប្រព្រឹត្តបទល្មើស**

ចេតនាទុច្ចរិតពិសេសក្នុងការប្រព្រឹត្តនូវបទល្មើស រំលោភសេពសន្ថវៈគឺសំដៅ ទៅលើឆន្ទៈរបស់ជនល្មើសក្នុងការបញ្ចូលអង្គជាត ឬ ឧបករណ៍ផ្សេងៗ ប្រព្រឹត្តទៅលើជនរងគ្រោះ ដោយដឹងយ៉ាងប្រាកដនៅក្នុងចិត្តហើយថាជនរងគ្រោះពុំព្រមព្រៀងស្ម័គ្រចិត្ត ក្នុងការរួមសេវាកិច្ចជាមួយខ្លួន ហើយនេះក៏ជាមូលហេតុដែលធ្វើឱ្យដែលជនល្មើសស្វែងតាមគំរាមកំហែងដើម្បីឱ្យជនរងគ្រោះរួមមេថុនកិច្ចជាមួយខ្លួនជាដើម។

**ខ.២. ចេតនាទុច្ចរិតពិសេស ចង់បានលទ្ធផលជាក់លាក់មួយ**

ទស្សនៈនេះ ចេតនាទុច្ចរិតពិសេសរបស់ជនល្មើស គឺប្រាថ្នាឱ្យបានដល់នូវការសម្រេចនៃសកម្មភាពរំលោភសេពសន្ថវៈជាមួយនឹងជនរងគ្រោះដូចជាការបញ្ចូលអង្គជាត ឬ ឧបករណ៍ផ្សេងៗ ដែលប្រព្រឹត្តទៅលើជនរងគ្រោះបើទោះបីជាជនរងគ្រោះមិនស្ម័គ្រចិត្ត ក៏គេនៅតែប្រើប្រាស់វិធីផ្សេងទៀតដើម្បីធ្វើឱ្យសកម្មភាពរំលោភរបស់ខ្លួននោះបានសម្រេចនូវលទ្ធផល។

គំនិតផ្តួចផ្តើមប្រព្រឹត្តបទល្មើសរំលោភសេពសន្ថវៈ នៅក្នុងការប្រព្រឹត្តបទល្មើសរំលោភសេពសន្ថវៈកត្តាដែលជម្រុញឱ្យមាននូវចិត្តចង់ប្រព្រឹត្តនូវបទល្មើស គឺគ្មានអ្វីក្រៅពីតម្រេកចំណង់ផ្នែកផ្លូវកាមរបស់ជន

[22] នីតិព្រហ្មទណ្ឌទូទៅ សាស្រ្តាចារ្យ រុន ពណ្ណារិទ្ធ លោកស្រីសាស្រ្តាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០១២

[23] នីតិព្រហ្មទណ្ឌទូទៅ សាស្រ្តាចារ្យ រុន ពណ្ណារិទ្ធ លោកស្រីសាស្រ្តាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០១២

ល្មើសនោះទេ ពោលគឺ ជនល្មើសមានចិត្តត្រេកត្រអាលនេះចង់រួមសង្វាសជាមួយជនរងគ្រោះ។ នៅក្នុងដំណាក់កាលនៃឆន្ទៈទុក្ខចរិតយើងអាចបែងចែកជា២យ៉ាង៖

- **ឆន្ទៈប្រព្រឹត្តបទល្មើសកើតមានតាំងពីដំបូង៖** គឺមានន័យថាជនល្មើស មានចេតនាចង់ប្រព្រឹត្តបទល្មើស រំលោភសេពសន្ថវៈតាំងពីដំបូងមកម្ល៉េះរួចហើយខ្លួនក៏ចាប់ផ្តើមប្រព្រឹត្តបទល្មើសតែម្តង។

**ឧទាហរណ៍៖** ចារីក្រោយពីបានឃើញជនរងគ្រោះដើរតែឯងនៅក្បែរព្រៃត្រែងចារីបានកើតចិត្តចង់រំលោភសេពសន្ថវៈលើជនរងគ្រោះ ហើយក៏បានប្រព្រឹត្តតែម្តង។

- **ឆន្ទៈប្រព្រឹត្តបទល្មើសកើតឡើងបន្ទាប់ពីការបដិសេធរបស់ជនរងគ្រោះ៖** ជនល្មើសបានស្វែងរកការយល់ព្រមពីជនរងគ្រោះក្នុងការសេពសេវនកិច្ចជាមួយខ្លួន តែដោយជនរងគ្រោះនូវតែបដិសេធធ្វើឱ្យជនល្មើសកើតមាននូវឆន្ទៈនៅក្នុងការប្រព្រឹត្តបទល្មើស ហើយញ៉ាំងឱ្យកើតជាសកម្មភាពសត្យានុម័តនៃការប្រព្រឹត្តបទល្មើស។

**ឧទាហរណ៍៖** ចារីបានស្នើសុំភរិយាឱ្យរួមសមគ្គសង្វាសជាមួយខ្លួន តែភរិយាពុំព្រមនាំឱ្យចារីកើតកំហឹងហើយ បង្ខិតបង្ខំគំរាមកំហែងជនរងគ្រោះឱ្យរួមភេទជាមួយខ្លួន។

## ១.៣. ទោស និងស្ថានទម្ងន់ទោសដែលត្រូវអនុវត្ត

### ១.៣.១ និយមន័យនៃទោស

ទោស គឺជាទណ្ឌកម្មដែលត្រូវផ្តន្ទាទោសដោយសង្គមតាមរយៈច្បាប់ទៅលើជនណាដែលបានប្រព្រឹត្តបទល្មើស។ ទោសត្រូវបានកំណត់ឡើងនៅក្នុងគោលដៅការពារផលប្រយោជន៍សាធារណៈដែលជាផលប្រយោជន៍សាធារណៈ និងជាផលប្រយោជន៍របស់សង្គមទាំងមូល។ ដូច្នេះទោសមានការខុសប្លែកពីការជួសជុសការខូចខាតផ្នែករដ្ឋប្បវេណីដែលមានគោលដៅការពារត្រឹមតែផលប្រយោជន៍ជាឯកត្តជនរបស់ជនរងគ្រោះ។[24] ម្យ៉ាងវិញទៀត ទោសក៏មានភាពខុសប្លែកពីទណ្ឌកម្មផ្នែកវិន័យដែលមានគោលដៅ ការពារផលប្រយោជន៍របស់ក្រុមសមូហភាពណាមួយតែប៉ុណ្ណោះ មិនមែនការពារផលប្រយោជន៍របស់សង្គមទាំងមូលឡើយ។ បើផ្អែកតាមបទបញ្ញត្តិនៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ទោសចែកចេញជា ៣(បី)ប្រភេទគឺ មូលទោស ទោលបន្ថែម ទោសជំនួស។[25]

---

[24] នីតិព្រហ្មទណ្ឌទូទៅ សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០១២

[25] https://freshnewsasia.com/index.php/en/localnews/121740-2019-05-12-03-12-36.html

### ១.៣.២ ទោសធម្មតា

ដូចបានកំណត់ក្នុងក្រមព្រហ្មទណ្ឌ ចំពោះបទរំលោភសេពសន្ថវៈត្រូវបានគេបញ្ញត្តិផ្តន្ទាទោសតាម មាត្រា២៣៩ កថាខណ្ឌ២ ថាបទរំលោភសេពសន្ថវៈត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី៥ ឆ្នាំ ទៅ ១០ ឆ្នាំ។ កាលណាប្រសិនបើអំពើល្មើសមួយបានបំពេញគ្រប់ធាតុផ្សំ នៃបទល្មើសរំលោភសេពសន្ថវៈ ហើយនោះ អំពើល្មើសនោះ គឺត្រូវបានចោទប្រកាន់ក្នុងបទរំលោភសេពសន្ថវៈ ដែលត្រូវទទួលទណ្ឌកម្មផ្នែកព្រហ្មទណ្ឌ ជាការដាក់ពន្ធនាគារតាមស្ថានភាពនៃបទល្មើស ក្នុងដែនកំណត់នៃអតិបរមា និងអប្បបរមានៃទោស ពន្ធនាគារបានកំណត់នៅខាងលើ។

### ១.៣.៣ ស្ថានទម្ងន់ទោស

ស្ថានទម្ងន់ទោសនៃបទរំលោភសេពសន្ថវៈ គឺជាបទល្មើសដែលត្រូវបានច្បាប់កំណត់មកនូវ ទណ្ឌកម្មព្រហ្មទណ្ឌដែលមានលក្ខណៈធ្ងន់ធ្ងរជាងបទរំលោភសេពសន្ថវៈមានចែងក្នុង មាត្រា២៣៩ នៃ ក្រមព្រហ្មទណ្ឌ២០០៩ ដោយមូលហេតុថាវាជាប្រភេទបទល្មើសដែលមានចេតនាទុច្ចរិតដែលធ្ងន់ធ្ងរ និង បង្កឱ្យមានលក្ខណៈហានិភ័យដល់សណ្តាប់ធ្នាប់សាធារណៈសង្គមជាតិ។ ប្រសិនបើជនណាដែលបាន ប្រព្រឹត្តបទរំលោភសេពសន្ថវៈ និងមានប្រព្រឹត្តអំពើចូលក្នុងរូបភាពចំនួន ៥ ដូចខាងក្រោមជនល្មើសនឹង ទទួលនូវស្ថានទម្ងន់ទោសជាក់លាក់ដូចតទៅៈ

#### ក. ទម្ងន់ទោសដោយសារមធ្យោបាយប្រើប្រាស់ ឬទាក់ទងនឹងជនល្មើស

បទរំលោភសេពសន្ថវៈត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ១៥ (ដប់ប្រាំ)ឆ្នាំ កាល បើអំពើនេះប្រព្រឹត្តទៅលើៈ

១. ដោយការប្រើអាវុធ ឬគំរាមគំហែងនឹងអាវុធ

២.ដោយការប្រើគ្រឿងញៀន ឬ គ្រប់វិធីដែលនាំអោយជនរងគ្រោះបាត់បង់ ឬចុះខ្សោយលទ្ធភាពទប់ទល់

៣.ដោយបុគ្គលដែលមានអំណាចលើជនរងគ្រោះ

៤.ដោយបុគ្គលដែលរំលោភអំណាចដែលមុខងាររបស់ខ្លួនបានប្រគល់អោយ

ឧទាហរណ៏ៈ គ្រូបង្រៀន ឬ ចៅហ្វាយនាយដែលរំលោភសេពសន្ថវៈសិស្សរបស់ខ្លួន ឬអ្នកនៅ ក្រោមឱវាទរបស់ខ្លួន។

៥. ដោយបុគ្គលច្រើនរូបដែលប្រព្រឹត្តឡើងក្នុងឋានៈជាចារី សហចារី អ្នកផ្តើមគំនិតឬជាអ្នកសមគំនិត។[26]

[26] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ មាត្រា២៤០

### ខ. ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ

បទរំលោភសេពសន្ថវៈត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ១៥ (ដប់ប្រាំ)ឆ្នាំ កាលបើអំពើនេះប្រព្រឹត្តទៅ៖

១. បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុអាយុនៃបុគ្គលនោះ។

ឧទាហរណ៍៖ ក្មេងអាយុក្រោម១០ឆ្នាំ ចាស់អាយុ៧០ឆ្នាំ។

២. នារីមានគភ៌ កាលបើគភ៌ត្រូវបានគេឃើញជាក់ស្តែងឬកាលបើជនល្មើស បានដឹង។

បានន័យថាលុះត្រាតែស្ថានភាពផ្ទៃពោះរបស់ស្ត្រីរងគ្រោះ មានការលេចឡើងធំដែលអាចសន្មតយ៉ាងពិតប្រាកដថាជានារីមានគភ៌ ហើយជនល្មើសក៏នៅតែមានចេតនាក្នុងការរំលោភសេពសន្ថវៈទៅលើជនរងគ្រោះ។ ម្យ៉ាងវិញទៀតចំពោះករណីដែលជនល្មើសបានដឹងហើយថាស្ត្រីរងគ្រោះមានគភ៌ ហើយប៉ុន្តែស្ថានភាពគភ៌របស់ស្ត្រីរងគ្រោះពុំទាន់បានលេចឡើងជាក់ស្តែងក៏ជាស្ថានទម្ងន់ទោសដែរ។

៣. បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុនៃជំងឺ ឬពិការភាព កាលបើស្ថានភាពបុគ្គលនេះត្រូវបានគេឃើញជាក់ស្តែង ឬកាលបើជនល្មើសបានដឹង។[27]

ភាពទន់ខ្សោយពិសេសដោយមូលហេតុនៃជំងឺ គឺចង់សំដៅទៅលើស្ថានភាពមួយនៃជំងឺរបស់ជនរងគ្រោះដែលបានបណ្តោលឲ្យបាត់បង់ ឬ ថយចុះនូវសមត្ថភាពក្នុងការការពារខ្លួនដែលមិនអាចមាននូវលិទ្ធភាពដើម្បីទប់ទល់ទៅកាន់ស្ថានភាពដែលត្រូវបង្ខំជាដើម ដូចជំងឺស្លាប់មួយចំហៀងខ្លួនដែលបានធ្វើឱ្យជនរងគ្រោះបាត់បង់នូវសម្ថភាពដើម្បីការពារខ្លួន។ ក៏ប៉ុន្តែចំពោះការបង្ហាញអំពីការអះអាងរបស់ជនរងគ្រោះថាខ្លួនមានជំងឺដូចជាផ្តាសាយ ឈឺមាត់ ឈឺដៃ ជើងជាអាទិ៍នោះមិនត្រូវបានចាត់ទុកថាជាមូលហេតុនៃស្ថានទម្ងន់ទោសនៅក្នុងបទរំលោភសេពសន្ថវៈបាននោះទេ។

ជាមួយគ្នានេះដែលបើផ្អែកតាមស្មារតីនៃក្រមព្រហ្មទណ្ឌ២០០៩ បានកំណត់ថាការពិការភាពដែលជាស្ថានទម្ងន់ទោសនេះ ត្រូវតែជាការពិការភាពដែលធ្វើឲ្យជនរងគ្រោះថមថយនូវសមត្ថភាពក្នុងការការពារខ្លួន ដែកស្ថានភាពទាំងនោះត្រូវបានគេមើលឃើញជាក់ស្តែង និងត្រូវបានគេដឹងគ្រប់គ្នា ឬជនល្មើសនោះពិតជាបានដឹងអំពីស្ថានភាពពិការភាពថែមទៀតផង។

ក៏ប៉ុន្តែផ្ទុយទៅវិញ ប្រសិនបើក្នុងករណីដែលមានស្ថានភាពដូចជាដាច់ម្រាមដៃមួយ ឬម្រាមជើងដែលមិនមែនជាស្ថានភាពពិការភាពដែលធ្ងន់ធ្ងរដែលបាននាំឱ្យការរំលោភរបស់ចារីប្រព្រឹត្តទៅលើជនរង

[27] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ មាត្រា២៤១

គ្រោះ មិនអាចចាត់ទុកថាស្ថិតនៅស្ថានទម្ងន់ទោសបាននោះទេ ពីព្រោះថាចំពោះពិការភាពរបស់ជនរងគ្រោះមិនមែនជាកត្តាណាមួយដែលបានរាំងក្នុងការការពារខ្លួនបាននោះទេ។

**គ. ស្ថានទម្ងន់ទោសដោយសារការកាត់អវយវៈ ឬពិការភាព**

បទរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០(ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ)ឆ្នាំ បើបទល្មើសនេះនាំឱ្យមានការកាត់អវយវៈ ឬពិការភាពជាអចិន្ត្រៃយ៍ដល់ជនរងគ្រោះ។[28]

**ឧទាហរណ៍៖** ជនល្មើសបានធ្វើសកម្មភាពចាប់រំលោភនារីរងគ្រោះម្នាក់ ដោយបានចាប់សង្កត់ ដៃរបស់នាងទាំងសងខាងយ៉ាងខ្លាំង បណ្តាយឲ្យបាក់ដៃរបស់នាង។ តាមសេចក្តីព្រាងក្រមព្រហ្មទណ្ឌកម្រិតទណ្ឌកម្មដោយយោងទៅលើព្យសនកម្មដែលជនរងគ្រោះទទួលហើយនោះធ្វើឱ្យមាននូវស្ថានទម្ងន់ទោសដោយគិតគួរអំពីលក្ខណៈអចិន្ត្រៃយ៍នៃពិការភាព ឬការកាត់នូវអវៈយវដែលបណ្តាលមកពីអំពើល្មើសនោះ។

**ឃ. ស្ថានទម្ងន់ទោសដោយសារការធ្វើទារុណកម្ម ឬអំពើឃោរឃៅ**

បទរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០(ដប់) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំកាលបើបទល្មើសនេះប្រព្រឹត្តឡើងមុនពេល ឬក្រោយពេលប្រព្រឹត្តអំពើទារុណកម្ម ឬអំពើឃោរឃៅ។[29]

**ឧទាហរណ៍៖** ជនល្មើសបានប្រព្រឹត្តបទរំលោភសេពសន្ថវៈទៅលើជនរងគ្រោះហើយថែមទាំងបានធ្វើទារុណកម្មទៅលើជនរងគ្រោះយ៉ាងឃោរឃៅដោយធ្វើការចាប់បង្ខំជនរងគ្រោះ ព្រមទាំងចាប់ចងដៃចង់ជើងដើម្បីមិនឱ្យជនរងគ្រោះរើបំរាស់បាន ដែលនាំឲ្យជនរងគ្រោះទទួលរងនូវព្យសនកម្មដែលមានលក្ខណៈអចិន្ត្រៃយ៍នៃពីការភាព ឬ ការកាត់អវៈយវៈដែលបណ្តាលមកពីអំពើល្មើស។

**ង. ស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ**

បទរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០(សាមសិប)ឆ្នាំកាលបើបទល្មើសនេះបណ្តាលអោយជនរងគ្រោះស្លាប់ដោយគ្មានចេតនាសម្លាប់។[30]

**ឧទាហរណ៍៖** បន្ទាប់ពីការធ្វើសកម្មភាពរំលោភសេពសន្ថវៈដោយសហចារីប្រព្រឹត្តជាច្រើនដងដែលធ្វើឲ្យជនរងគ្រោះអស់កម្លាំងយ៉ាងខ្លាំង រួមផ្សំនឹងសុខភាពខ្សោយផងធ្វើឲ្យជនរងគ្រោះបាត់បង់ជីវិត។

[28] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ មាត្រា២៤២

[29] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ មាត្រា២៤៣

[30] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ មាត្រា២៤៤

### ១.៣.៤.ទោសបន្ថែម

ទោសបន្ថែម គឺជាទោសដែលត្រូវបានប្រកាសជាបន្ថែមទៅលើមូលទោស មុនពេលដែលក្រមព្រហ្មទណ្ឌចូលជាធរមាន ទោសបន្ថែមក៏មានវត្តមានរួចជាស្រេចទៅហើយនៅក្នុងនីតិព្រហ្មទណ្ឌកម្ពុជា ជាក់ស្តែងដូចជាមាត្រា៦៣ថ្មី ចំណុចទី៤ នៃច្បាប់ក្រមព្រហ្មទណ្ឌអន្តរកាលដែលចែងថាតុលាការអាចបញ្ជាឱ្យបិទផ្សាយសេចក្តីសម្រេចរបស់ខ្លួននៅទីកន្លែងទាំងឡាយដែលតុលាការនឹងបញ្ជាក់ដោយឱ្យជនជាប់ទោសទទួលបន្ទុកចេញនូវសោហ៊ុយហើយតុលាការអាចចុះផ្សាយសាលក្រមនេះក្នុងសារព័ត៌មានមួយឬច្រើនដែលឱ្យជនជាប់ទោសទទួលបន្ទុកចេញសោហ៊ុយរហូតដល់កម្រិតច្រើនបំផុត១០លានរៀល។ ក្រមព្រហ្មទណ្ឌបានរៀបរាប់ពីប្រភេទផ្សេងៗនៃទោសនៅត្រង់ មាត្រា៥៣ ហើយក៏បានកំណត់ពីលក្ខខណ្ឌនៃការប្រកាសទោសបន្ថែមព្រមទាំងអនុញ្ញាតឱ្យប្រកាសទោសបន្ថែមជំនួសមូលទោសទៀតផង។ ដោយយោងទៅតាម មាត្រា២៤៥ នៃទោសបន្ថែមលើបទល្មើសរំលោភសេពសន្ថវៈ គឺមានចំនួន ៨ ចំណុចក្នុងចំណោមទោសបន្ថែមទាំងអស់ចែងក្នុងមាត្រា៥៣ដែលមាន១៩ចំណុចដែលរួមមាន៖

១.ការដកសិទ្ធិខ្លះជាពលរដ្ឋជាស្ថាពរ ឬសម្រាប់រយៈពេល៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន។

២.ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាសបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬនៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះជាស្ថាពរ ឬសម្រាប់រយៈពេល៥(ប្រាំ) ឆ្នាំយ៉ាងច្រើន ។

៣.ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល១០ (ដប់)ឆ្នាំយ៉ាងច្រើន។ ការហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទ ។

៤.ការហាមឃាត់ចំពោះទណ្ឌិតដែលជាជនបរទេស ចំពោះការចូល ឬការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរឬសម្រាប់រយៈពេល៥ឆ្នាំយ៉ាងច្រើន។

៥.ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬសម្រាប់រយៈពេល៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន។

៦. ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល២ ( ពីរ) ខែយ៉ាងច្រើន ។

៧. ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន។

៨.ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍សម្រាប់រយៈពេល ៨(ប្រាំបី) ថ្ងៃ យ៉ាងច្រើន។[31]

[31] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ មាត្រា២៤៥

### ១.៣.៥.ការប៉ុនប៉ងប្រព្រឹត្តបទល្មើស

រីឯការប៉ុងប៉ងវិញ គឺមិនចាំបាច់ចែងជាក់លាក់ក៏បានដែរពីព្រោះចៅក្រមអាចយកមកប្រើនូវ គោលការណ៍ដែលមានចែងក្នុង មាត្រា២៧ ដែលបានចែងថាការប៉ុនប៉ងក្នុងបទឧក្រិដ្ឋ ឬ ក្នុងករណីដែលច្បាប់បានចែងទុកក្នុងបទមជ្ឈិមអាចត្រូវផ្តន្ទាទោស បានកាលណាលក្ខខណ្ឌ ត្រូវបានបំពេញដោយចារីបានចាប់ផ្តើមអនុវត្តបទល្មើសមានន័យថា ចារីបានប្រព្រឹត្តអំពើដែលមានគោលបំណងដោយផ្ទាល់ ដើម្បីប្រព្រឹត្តបទល្មើស និងចារីមិនបានបញ្ឈប់អំពើរបស់ខ្លួនទៅវិញដោយស្ម័គ្រចិត្ត តែត្រូវបានរាំងស្ទះ ឬអាក់ខានដោយឥទ្ធិពលនៃកាលៈទេសៈក្រៅឆន្ទៈរបស់ខ្លួន។ ចំពោះការប៉ុនប៉ងក្នុងបទលហុ គឺពុំត្រូវទទួលការផ្តន្ទាទោសនោះទេ។ ដូចបានឃើញក្នុងនិយមន័យនៃ ការប៉ុនប៉ងមកយើងអាចយល់បានថា ការប៉ុនប៉ង គឺជាការចាប់ផ្តើមប្រព្រឹត្តបទល្មើស ឬ ជាការចាប់លេចឡើងនូវធាតុសត្យានុម័តនៃបទល្មើសតាមរយៈសកម្មភាពរបស់ចារី ហើយចារីទៀតសោតក៏ពុំបានបញ្ឈប់នូវទង្វើទុច្ចរិតរបស់ខ្លួនដោយឆន្ទៈភ្ញាក់រលឹកខ្លួនឯងទេ តែត្រូវបានបញ្ឈប់ដោយឥទ្ធិពល ក្រៅឆន្ទៈដូចជាករណីដែលជនល្មើសទើបចាប់ផ្តើមប្រព្រឹត្តបទល្មើស ហើយត្រូវបានសមត្ថកិច្ចបង្រ្កាបតាំងពីពេលដំបូងនោះ។

ផ្ទុយទៅវិញចំពោះការដែលបានរៀបចំបម្រុងទុកជាមុន ប៉ុន្តែពុំទាន់បានចាប់ផ្តើមធ្វើនូវសកម្មភាពទាំងឡាយណា ដែលមានគោលបំណងដោយផ្ទាល់ក្នុងការប្រព្រឹត្តបទល្មើសទេនោះ គេមិនរាប់ថាជាការចាប់ផ្តើមអនុវត្តទេ ដូចករណីដែលជនល្មើសត្រៀមឧបករណ៍គាស់ទ្វារបម្រុងថានឹងទៅគាស់ទ្វារផ្ទះគេ តែជនល្មើសពុំទាន់មានសកម្មភាពអ្វីទេ បានន័យថា គឺគ្រាន់តែរៀបចំតែការលួចចូលទៅគាស់ផ្ទះនោះពុំទាន់បានធ្វើនៅឡើយទេ ហើយឧបករណ៍ទាំងនោះនៅក្នុងផ្ទះ ជនល្មើសនៅឡើយ ចំពោះបទលហុការប៉ុនប៉ងប្រព្រឹត្តបទនេះពុំមានទោសនោះទេ។[32]

ដោយឡែកចំពោះការប៉ុនប៉ងប្រព្រឹត្តបទរំលោភសេពសន្ថវៈយើងអាចសម្គាល់បានដោយនៅពេលដែលមានការរារាំងពីឥទ្ធិពលខាងក្រៅបញ្ឈប់នូវសកម្មភាពទុច្ចរិតនៃជនល្មើសនោះ គេអាចក្តាប់បាននូវភស្តុតាងដូចជាការឃើញជនល្មើសចាប់ផ្តើមក្នុងការប្រព្រឹត្តនូវសកម្មភាពណាមួយ ដែលបង្កនូវលទ្ធភាពក្នុងការបញ្ចូលអង្គជាត ឬ ឧបករណ៍ផ្សេងៗ ទៅលើជនរងគ្រោះ តួយ៉ាងជនល្មើសកំពុងតែនឹងពាក់នូវស្រោមអនាម័យ ជនល្មើសបានយកឧបករណ៍ដូចជាលិង្គសិប្បនិម្មិត ដំបង បម្រុងនឹងបញ្ចូលទៅលើជនរងគ្រោះ ឬ ការណ៍ដែលជនល្មើស បម្រុងបញ្ចូលអង្គជាត ឬ ឧបករណ៍ផ្សេងៗ តែពុំទាន់ដល់នូវទីជម្រៅនៅឡើយ ដូចជាការយកអង្គជាតទៅញល់ នៅលើអង្គជាតនៃជនរងគ្រោះជាអាទិ៍។ ក្នុងករណីប៉ុនប៉ងបទ

[32] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ មាត្រា២៧ កថាខណ្ឌទី៣

ល្មើសនេះទោះបីជាពុំទាន់បានសម្រេច តែព្យសនកម្មបានកើតមានឡើងហើយដូចជាព្យសនកម្មផ្លូវចិត្តនិង ខូចខាតសេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះ។

# ជំពូកទី២

# បទល្មើសប្រទូស្តកោខ្មោស

# ជំពូកទី២
# បទល្មើសប្រទូស្តកេរខ្មាស

ជាការពិតណាស់បទល្មើសនីមួយៗ គឺត្រូវបានកំណត់យ៉ាងច្បាស់នៅក្នុង ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។ លើសពីនេះទៅទៀតបទល្មើសមួយចំនួនក៏ត្រូវបានកំណត់នៅក្នុងច្បាប់ដោយឡែកផ្សេងៗគ្នា ដោយហេតុថានីតិព្រហ្មទណ្ឌពិសេសនៅព្រះរាជាណាចក្រកម្ពុជា ច្បាប់ដែលមានចែងអំពីបទល្មើសមានសភាពរាយប៉ាយនៅឡើយ ប៉ុន្តែច្បាប់ដែលសំខាន់បំផុតដែលយើងតែងតែឃើញគេយកធ្វើការសំអាងនៅក្នុងការសិក្សានោះ គឺក្រមព្រហ្មទណ្ឌ ដែលត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩។[33]

## ២.១.និយមន័យនៃបទល្មើសប្រទូស្តកេរខ្មាស

### ២.១.១.ច្បាប់ព្រហ្មទណ្ឌអន្តរកាល

នៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរកាល ត្រូវបានគេឱ្យនិយមន័យថាចំពោះអំពើបៀតបៀនដល់កេរ្តិ៍ខ្មាស់ជនណាដែលបៀតបៀនដល់កេរ្តិ៍ខ្មាស់ជនណាម្នាក់ទៀត ដែលមានភេទដូចគ្នា ឬមិនដូចគ្នា ដោយប្រព្រឹត្តិទៅលើជននោះតាមការស្ទាប អង្អែល ឬ អំពើផ្សេងទៀតដែលទាក់ទងទៅនឹងរឿងភេទ ប៉ុន្តែពុំបានដល់ទីជម្រៅ ត្រូវមានទោសពីបទបៀតបៀនកេរ្តិ៍ខ្មាស់។[34]

### ២.១.២.ក្រមព្រហ្មទណ្ឌបច្ចុប្បន្ន

បើយើងក្រឡេចមកមើលនៅក្នុងក្រមព្រហ្មទណ្ឌបច្ចុប្បន្នយើង វិញដោយបានឱ្យនិយមន័យចំពោះបទល្មើសប្រទូស្តកេរខ្មាសថាអំពើប្រទូស្តកេរខ្មាស គឺគ្រប់អំពើប៉ះពាល់ ស្ទាប់ អង្អែលកេរភេទ ឬផ្នែកភេទផ្សេងទៀតរបស់បុគ្គលដទៃ តែបុគ្គលនេះមិនស្ម័គ្រជងទេ ឬបង្ខំបុគ្គលដទៃអោយប្រព្រឹត្តិអំពើនេះមកលើខ្លួន ឬទៅលើតតិយបុគ្គលក្នុងគោលបំណងឱ្យរំជួល ឬរីករាយដល់ចំណង់ផ្លូវភេទរបស់ជនល្មើស។[35]

## ២.២.ធាតុផ្សំនៃបទល្មើសប្រទូស្តកេរខ្មាស

ក្រោយពីបានស្វែងយល់អំពីអត្ថន័យនៃអំពើប្រទូស្តកេរខ្មាសរួចមក នៅក្នុងចំណុចបន្ទាប់នោះយើងនឹងធ្វើស្វែងយល់បន្ថែមទៀតអំពីធាតុផ្សំនីមួយៗដែលមាននៅក្នុងបទប្រទូស្តកេរខ្មាសនេះ។ ជាការពិតណាស់នៅក្នុងបទល្មើសព្រហ្មទណ្ឌមួយគឺ មានធាតុផ្សំសំខាន់ៗ ៣(បី) ដែលដើរតួយ៉ាងសំខាន់នៅក្នុងការ

---

[33] នីតិព្រហ្មទណ្ឌពិសេស សាស្ត្រាចារ្យ នុន ពណ្ណារិទ្ធ លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០១៣-២០១៤

[34] ច្បាប់ព្រហ្មទណ្ឌអន្តរកាល មាត្រា៤២

[35] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ មាត្រា២៤៦ កថាខណ្ឌទី១

កំណត់អំពីបទល្មើសព្រហ្មទណ្ឌណាមួយ ហើយធាតុផ្សំទាំងបីយើងមិនអាចខ្វះនូវធាតុផ្សំណាមួយបាននោះទេ។ យើងគួរកត់សម្គាល់ផងដែរថានៅក្នុងនីតិព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាយើងគេបានធ្វើការបែងចែកធាតុផ្សំនៃបទល្មើសខុសៗពីគ្នា។ ប៉ុន្តែជាទូទៅយើងកំណត់បានថានៅក្នុងបទល្មើសមួយមានធាតុផ្សំចូលរួមចំនួន ៣(បី) ដែលជាធាតុផ្សំចម្បងក្នុងការបង្កើតឱ្យមានជាបទល្មើសព្រហ្មទណ្ឌមួយបាន។[36]

មុននឹងធ្វើការបកស្រាយធាតុផ្សំទាំងបីសំខាន់ៗនៃបទប្រទូស្តកេរខ្មាស យើងគួរគប្បីយល់ជាមុនសិនថាតើអ្វីទៅជាបទល្មើសព្រហ្មទណ្ឌជាមុនសិន ដើម្បីបង្ករភាពងាយស្រួលក្នុងការយល់បន្ថែមទៀត និងកាន់តែច្បាស់ចំពោះបទប្រទូស្តកេរខ្មាសដែលយើងធ្វើបកស្រាយនៅក្នុងផ្នែកនេះ។ តាមរយៈក្រមព្រហ្មទណ្ឌក៏បានបញ្ញត្តិផងដែរចំពោះអ្វីទៅដែលចាត់ទុកជាបទល្មើសដោយនៅក្នុងនោះគេបានឱ្យនិយមន័យថា ច្បាប់បញ្ញត្តិថាអំពើខ្លះៗរបស់រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលបង្ករចលាចលដល់សង្គម គឺជាបទល្មើស។[37] ដោយតាមរយៈន័យនេះយើងអាចកំណត់បានចំពោះបទល្មើសព្រហ្មទណ្ឌថាគឺ ជាអំពើទាំងឡាយណាដែលច្បាប់ព្រហ្មទណ្ឌមានកំណត់ទុកមុនយ៉ាងច្បាស់លាស់ថាអំពើនោះខុសទៅនឹងច្បាប់និងត្រូវបានផ្តន្ទាទោសដោយច្បាប់ព្រហ្មទណ្ឌជាធរមាន ហើយអំពើល្មើសទាំងនោះគឺជាកំហុសរបស់ចារីជាអ្នកប្រព្រឹត្តផ្ទាល់។ ក៏ប៉ុន្តែផ្ទុយមកវិញប្រសិនបើសិនច្បាប់មិនបានបញ្ញត្តិថាអំពើនោះជាបទល្មើសនោះទេ អំពើនោះមិនត្រូវបានចាត់ទុកថាជាបទល្មើសបាននោះឡើយ នេះបើយោងទៅតាមគោលការណ៍នីត្យានុកូលភាព។[38]

សរុបជារួមមកដើម្បីកំណត់អំពីបទល្មើសព្រហ្មទណ្ឌមួយបាន គឺលុះត្រាតែនៅក្នុងអំពើដែលចារីបានប្រព្រឹត្តនោះមាននូវធាតុផ្សំទាំង ៣(បី) សំខាន់ៗដែលច្បាប់ព្រហ្មទណ្ឌបានចែងកំណត់ទុកជាមុនរួចមកហើយនៃអំពើល្មើសនោះត្រូវបានបំពេញ ដោយមិនអាចខ្វះបាននូវធាតុផ្សំណាមួយបាននោះឡើយ ដូច្នេះទើបអាចចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌបាន និងត្រូវបានផ្តន្ទាទោស។ ពោលនេះគឺធាតុផ្សំសំខាន់ៗទាំង ៣(បី) នៃបទប្រទូស្តកេរខ្មាសទាំងនោះរួមមានដូចជាធាតុផ្សំនីត្យានុកូល ធាតុផ្សំសត្យានុម័ត និងធាតុផ្សំចុងក្រោយនោះ គឺជាធាតុផ្សំអត្តនោម័ត។

[36] នីតិព្រហ្មទណ្ឌ ទូទៅនៅខ្មែរ សាស្រាចារ្យ កៅ សីហា ទំព័១១៦

[37] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ មាត្រា២ វាក្យខណ្ឌទី១

[38] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ មាត្រា៣

### ២.២.១.ធាតុផ្សំនីត្យានុកូល

ធាតុផ្សំនីត្យានុកូល ឬ ជាទូទៅគេតែងតែហៅថាធាតុផ្សំច្បាប់មានន័យថា ទាល់តែមានច្បាប់ណាមួយចែងកំណត់ថាការប្រព្រឹត្តបែបណាខ្លះដែលគេហៅថាជាបទល្មើសទើបបានត្រូវផ្តន្ទាទោស។[39] នៅក្នុងន័យនេះ គឺចង់សំដៅដល់ការដែលត្រូវបានចែងទុកជាមុននៅក្នុងច្បាប់ណាមួយដែលបានចែងកំណត់ទៅលើស្ថានភាពនៃអំពើល្មើស ឬ ការប្រព្រឹត្តនៃអំពើល្មើសណាមួយថាសកម្មភាពដែលប្រព្រឹត្តនោះ ជាបទល្មើសហើយត្រូវផ្តន្ទាទោសលើសពីនេះទៅទៀតអំពើនោះត្រូវបានចែងទុកមុនរួចជាស្រេចនៅក្នុងច្បាប់។

ជាការពិតណាស់ជាក់ស្តែងអំពើប្រទូស្តកេរខ្មាស គឺត្រូវបានចែងនៅក្នុងក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ត្រង់ចំណុចគន្លឹទី២ បទល្មើសប្រឆាំង និងបុគ្គល មាត្រា២៤៦ បានចែងថា គ្រប់អំពើប៉ះពាល់ ស្ទាប់ អង្អែលកេរភេទ ឬផ្នែកភេទផ្សេងទៀតរបស់បុគ្គលដទៃ តែបុគ្គលនេះមិនស្ម័គ្រផងទេ ឬបង្ខំបុគ្គលដទៃឱ្យប្រព្រឹត្តអំពើនេះមកលើខ្លួន ឬទៅលើតតិយបុគ្គលក្នុងគោលបំណងអោយរំជួល ឬរីករាយដល់ចំណង់ផ្លូវភេទរបស់ជនល្មើស គឺជាអំពើប្រទូស្តកេរខ្មាស។

មិនតែប៉ុណ្ណោះបើយើងក្រឡេកមើលទៅលើច្បាប់ព្រហ្មទណ្ឌអន្តរកាលវិញ ក៏មានចែងផងដែរអំពើបទល្មើសមួយដែលមានលក្ខណៈប្រហាក់ប្រហែលទៅនឹងបទល្មើសនេះផងដែរ នោះគឺអំពើបៀតបៀនដល់កេរ្តិ៍ខ្មាស់ដែលមានចែងនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរកាលត្រង់ មាត្រា៤២។

និយាយជារួមមកបទប្រទូកេរខ្មាសនៅក្នុងក្រមព្រហ្មទណ្ឌបច្ចុប្បន្ន គឺមានលក្ខណៈស្រដៀងគ្នាទៅនឹង បទបៀតបៀនកេរ្តិ៍ខ្មាស់នៅក្នុងច្បាប់អន្តកាលថែមទៀតផង ដែលយើងធ្លាប់បានអនុវត្តកន្លងមកផងដែលត្រង់ មាត្រា៤២។ ប៉ុន្តែប្រសិនយើងធ្វើការប្រៀបធៀបរវាងបទល្មើសដែលបានចែងនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរកាល និងក្រមព្រហ្មទណ្ឌបច្ចុប្បន្នយើងឃើញថាការចែងនៅក្នុងក្រមព្រហ្មទណ្ឌបច្ចុប្បន្ន គឺមានលក្ខណៈកំណត់បានទូលំទូលាយជាង ហើយថែមទាំងបានគ្របដណ្តប់ទៅលើអំពើច្រើនជាងទៅនឹងបទល្មើសបៀតបៀនកេរ្តិ៍ខ្មាស នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

### ២.២.២.ធាតុផ្សំសត្យានុម័ត

ជាការពិតណាស់ធាតុផ្សំសត្យានុម័ត ឬ ហៅម៉្យាងទៀតថាធាតុផ្សំសម្ភារត្រង់ន័យនេះ គឺចង់សំដៅទៅដល់ការសម្តែងចេញមកខាងក្រៅនៃសកម្មភាពល្មើស ឬជាអំពើដែលមានលក្ខណៈសម្ភារដោយបង្កើតជាបទល្មើសចេញមកខាងក្រៅ ដែលមានចរិតលក្ខណៈដែលមានបង្កនូវគ្រោះថ្នាក់ ហើយអំពើទាំងនោះ

[39] នីតិព្រហ្មទណ្ឌ ទូទៅនៅខ្មែរ សាស្រាចារ្យ កៅ សីហា ទំព័១១៦

បានបង្ករព្យសនកម្មទៅកាន់សង្គម ឬ បុគ្គលដទៃទៀតហើយបង្កើតឱ្យមានរវាងទំនាក់ទំនងហេតុ និងផល រវាងអំពើនៃបទល្មើស និងព្យសនកម្ម។ ជាក់ស្តែងនៅក្នុងបទប្រទូស្តកេរខ្មាស ត្រង់មាត្រា២៤៦ នៃក្រមព្រហ្មទណ្ឌរបស់យើងក៏បានបង្ហាញផងដែរអំពីធាតុផ្សំសត្យានុម័តដែលគួរសម្គាល់គឺ អំពើរបស់ជនល្មើស និងអវត្តមាននៃការព្រមព្រៀងពីជនរងគ្រោះ។

**២.២.២.១.អំពើរបស់ជនល្មើស**

ធាតុសត្យានុម័តនៅក្នុងបទល្មើសប្រទូស្តកេរខ្មាសនៅក្នុងចំណុចនេះគឺ ចង់សំដៅទៅដល់សកម្មភាព ឬ កាយវិការទាំងឡាយណាដែលជនល្មើសបានប្រព្រឹត្តដោយមានបំណងទំនោរទៅកាន់រឿងផ្លូវភេទ។[40]

ជាការពិតណាស់នៅក្នុងបទប្រទូស្តកេរខ្មាសនៅក្នុងក្រមព្រហ្មទណ្ឌ ក៏បានចែងផងដែរអំពីសកម្មភាព និងកាយវិការទាំងឡាយណាដែលត្រូវចាប់ទុកថាជាអំពើប្រទូស្តកេរខ្មាស ពោលគឺសកម្មភាពទាំងនោះរួមមានដូចជា ការស្ទាប អង្អែល ទៅកាន់កេរភេទ ឬ ផ្នែកភេទផ្សេងទៀតរបស់បុគ្គលដទៃតែមិនបានដល់ទីជម្រៅនេះទេ ក្នុងន័យនេះបានសេចក្តីថាជនល្មើសគ្រាន់តែស្ទាប់ ឬ អង្អែលតែប៉ុណ្ណោះដោយមិនបានធ្វើសកម្មភាពដល់ទៅជម្រៅដូចជាការបញ្ចូលអង្គជាតិរបស់ជនល្មើសទៅកាន់បុគ្គលដទៃនោះឡើយ។ មិនតែប៉ុណ្ណោះការដែលចែងបែបនេះអាចនឹងធ្វើអោយមានការភាន់ច្រឡំទៅនឹងការដែលប៉ុនប៉ងរំលោភសេពសន្ថវៈផងដែរ ដោយនៅក្នុងអំពើនោះចារីមិនបានប្រព្រឹត្តអំពើរបស់ខ្លួនដល់ទីជម្រៅនោះទេ។[41] យើងឃើញថាសកម្មភាពនៃអំពើទាំងពីរនេះ គឺមាននូវលក្ខណៈប្រហាក់ប្រហែលគ្នាខ្លាំងមែនទែនសឹងតែមិនអាចធ្វើការបែងចែងដាច់ថាជា អំពើប្រទូស្តកេរខ្មាស ឬក៏ជាអំពើប៉ុនប៉ងរំលោភសេពសន្ថវៈនោះឡើយ ក៏ប៉ុន្តែមិនមែនមានន័យថាយើងមិនអាចធ្វើការកំណត់បាននោះទេ គឺយើងអាចធ្វើការសម្គាល់ពីភាពខុសប្លែកគ្នាបាននៃអំពើទាំងពីរនេះបាន តាមរយៈធាតុអត្តនោម័តនៃសភាពផ្លូវចិត្តខាងក្នុងរបស់ចារីថាតើចារីប្រព្រឹត្តអំពើនោះឡើងក្នុងគោលបំណងបែបណានោះយើងនឹងអាចធ្វើការបែងចែកបានអំពីបទល្មើសទាំងពីរនេះ។

គួរកត់សម្គាល់ផងដែរថាកេរភេទត្រង់ចំណុចនេះ គឺសំដៅដល់ប្រដាប់ភេទរបស់បុរស ឬនារី ដែលជាប្រដាប់បន្តពូជតាមបែបវិជ្ជសាស្ត្រ រីឯពាក្យ ផ្នែកភេទផ្សេងទៀត ក្នុងន័យនេះគឺចង់សំដៅដល់កន្លែងផ្សេងៗដូចជា សុដន់ គូទ មាត់ជាដើម។[42]

---

[40] នីតិព្រហ្មទណ្ឌពិសេស សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ លោកស្រីសាស្ត្រាចារ្យ ចាំ ស៊ីណាត ឆ្នាំ២០១៤-២០១៥

[41] នីតិព្រហ្មទណ្ឌពិសេស សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ លោកស្រីសាស្ត្រចារ្យ ចាំង ស៊ីណាត ឆ្នាំ២០១៤-២០២៥

[42] នីតិព្រហ្មទណ្ឌទូទៅនៅខ្មែរ សាស្ត្រាចារ្យ កៅ សីហា ទំព័រ៤៣

**ឧទាហរណ៍៖ នារី ក** បានធ្វើដំណើរនៅតាមដងផ្លូវនៅទីសាធារណៈសំដៅទៅចំណត់រថយន្តក្រុងក្នុងគោលបំណងដើម្បីទៅផ្ទះបន្ទាប់ពីបានចេញពីធ្វើការហើយនៅពេលដែល **នារី ក** ដើរទៅដល់ចំណតរថយន្តក្រុងកំឡុងពេលអង្គុយចាំឡាន ស្រាប់តែ **លោក ខ** បានឃើញនាងមានរូបរាងស្រស់ស្អាតពេកដែលត្រូវនឹងចំណង់ចំណូលចិត្តរបស់ខ្លួនពេលនោះ **លោក ខ** ក៏បានយកដៃទៅប៉ះពាល់ និងស្ទាប់អង្អែលទៅកាន់សុដន់ និងស្ទាប់អង្អែលទៅលើរូបរាងកាយរបស់ **នារី ក** ថែមទាំងបានធ្វើសកម្មភាពផ្សេងៗដែលមានទំនោរទៅកាន់អារម្មណ៍រំជួលខាងផ្លូវភេទថែមទៀតផងទាំងដែល **នារី ក** មិនបានយល់ព្រមនោះទេហើយក្រោយមកនាងបានក៏បានធ្វើការស្រែកឆោឡោនៅទីនោះថាត្រូវគេបំពានរូបនាង។

ដូច្នេះតាមរយៈសកម្មភាពរបស់ **លោក ខ** ដែលជាជនល្មើសបានធ្វើទៅកាន់ **នារី ក** ដែលជាជនរងគ្រោះនោះយើងអាចសន្និដ្ឋានបានថា **លោក ខ** បានប្រព្រឹត្តនូវអំពើប្រទូស្តកេរខ្មាស់ដោយសារ លោក ខ មានគោលបំណង់ក្នុងការប៉ះពាល់ទៅលើរាងកាយរបស់នារីរងគ្រោះទាំងដែលនាងមិនបានព្រមព្រៀងឡើយ។

ជាក់ស្តែងនៅក្នុងបទប្រទូស្តកេរខ្មាសឃើញថា អំពើរបស់ជនល្មើសដែលសម្តែងចេញមកខាងក្រៅដែលហៅធាតុផ្សំសត្យានុម័តនេះ គឺអាចលេចក្នុងបីរូបភាព ឬ ជាបីទម្រង់ដែលអំពើទាំងនោះយើងនឹងធ្វើការបកស្រាយដូចខាងក្រោម៖

### ក.ជនល្មើសប៉ះពាល់ ស្ទាប អង្អែលកេរភេទ ឬ ផ្នែកផ្សេងភេទទៀតរបស់ជនរងគ្រោះ

ត្រង់រូបភាពទី១ នេះជនល្មើសបានធ្វើការប៉ះពាល់ ស្ទាប់ អង្អែល ទៅកាន់កេរភេទរបស់ជនរងគ្រោះ ឬ ទៅកាន់ផ្នែកភេទផ្សេងទៀត នៅលើរាងកាយរបស់ជនរងគ្រោះទាំងដែលជនរងគ្រោះនោះបានមិនស្ម័គ្រចិត្តនោះទេការដែលជនល្មើសធ្វើអំពើទាំងនេះ គឺធ្វើឡើងដោយក្នុងគោលបំណង់មានចេតនាមិនល្អទៅកាន់ជនរងគ្រោះ។ សកម្មភាពរបស់ជនល្មើសនៅត្រង់នេះ គឺធ្វើឡើងដើម្បីឱ្យមានទំនោរមានការរំជួលទៅខាងផ្លូវភេទណាមួយ។

**ឧទាហរណ៍៖** ជនល្មើសបានឃើញជនរងគ្រោះម្នាក់ដើរនៅតាមផ្លូវនៅពេលយប់ស្ងាត់ម្នាក់ឯងហើយនៅពេលនោះជនល្មើសបានឃើញថាមិនមាននរណាដើរជាមួយនាងផងនោះ ស្រាប់ដែលជនល្មើសក៏បានដើតាមជនរងគ្រោះ ហើយក៏បានធ្វើសកម្មភាពដោយយកដៃរបស់ខ្លួនទៅប៉ះពាល់ និងស្ទាប់អង្អែលទៅកេរភេទ និងសុដន់របស់ជនរងគ្រោះដោយចង់ធ្វើអោយមានអារម្មណ៍ផ្លូវភេទ នៅពេលនេះនារីរងគ្រោះក៏បានស្រែកឱ្យគេជួយ។

**ខ.ជនល្មើសបង្ខំអោយជនរងគ្រោះប៉ះពាល់ ស្ទាប់ អង្អែលកេរភេទ ឬ ផ្នែកផ្សេងភេទទៀតរបស់ខ្លួន**

តាមរយៈរូបភាពទី២ នេះឃើញថាជនល្មើសបានបង្ខិតបង្ខំឱ្យជនរងគ្រោះធ្វើនូវសកម្មភាព ប៉ះពាល់ ស្ទាប អង្អែល មកកាន់កេរភេទរបស់ខ្លួនវិញ ដែលមើលទៅមានភាពខុសគ្នាបន្តិចទៅ និងសកម្មភាពនៅក្នុងរូបភាពទី១។ ដែលនៅក្នុងរូបភាពទី២ នេះជនល្មើសជាអ្នកឱ្យជនរងគ្រោះធ្វើការប៉ះពាល់កាន់មកខ្លួនវិញក៏ប៉ុន្តែសម្មភាពទាំងនេះជនល្មើសធ្វើឡើង គឺក្នុងគោលបំណងឱ្យមានការរំជួលខាងផ្លូវភេទដូចគ្នា។

**ឧទាហរណ៍៖** ជនល្មើសបានធ្វើសកម្មភាពក្នុងការបង្ខិតបង្ខំអោយនារីដែលជាជនរងគ្រោះមកធ្វើការស្ទាបអង្អែលមកកាន់កេរភេទរបស់ខ្លួន ទាំងដែលជនរងគ្រោះនោះមិនបានក្នុងការស្ម័គ្រចិត្តផងការដែលជនល្មើសធ្វើអំពើបែបនេះគឺ ក្នុងគោលបំណងដើម្បីធ្វើឱ្យមានចំណង់ទៅកាន់អារម្មណ៍ខាងផ្លូវភេទរបស់ខ្លួន។

**គ.ជនល្មើសបានបង្ខំឱ្យជនរងគ្រោះប្រព្រឹត្តអំពើប៉ះពាល់ ស្ទាប អង្អែលកេរភេទ ឬ ផ្នែកផ្សេងទៀតរបស់តតិយជន**

នៅក្នុងសកម្មភាពនៃអំពើរបស់ចារីក្នុងរូបភាពទី៣ នោះគឺជនល្មើសមិនបានធ្វើសកម្មភាពប៉ះពាល់ទៅកាន់ជនរងគ្រោះនោះទេ ហើយជនល្មើក៏មិនបានបង្ខំឱ្យជនរងគ្រោះធ្វើការប៉ះពាល់ស្ទាបអង្អែលមកកាន់កេរភេទរបស់ខ្លួននោះដែរ ក៏ប៉ុន្តែជនល្មើសបែបជាបានបង្ខិតបង្ខំទៅកាន់ជនរងគ្រោះឱ្យធ្វើសកម្មភាព ប៉ះពាល់ ស្ទាប់អង្អែលទៅកាន់កេរភេទ ឬ ផ្នែកផ្សេងរបស់បុគ្គលដទៃដែលជាតតិយជនទៅវិញ។ ដែលក្នុងនៅអំពើនេះត្បិតតែជនល្មើសមិនបានធ្វើសកម្មភាពដោយផ្ទាល់ក៏ពិតមែន ក៏ប៉ុន្តជនល្មើសបានបង្ខំឱ្យជនដ៏ទៃទៅធ្វើសកម្មភាពនោះជំនួសខ្លួន ដែលធ្វើឱ្យប៉ះពាល់ទៅកាន់តតិយជន និងបុគ្គលដែលត្រូវជនល្មើសបង្ខំថែមទៀតផង។

**ឧទាហរណ៍៖** ជនល្មើសបានធ្វើការបង្ខិតបង្ខំទៅកាន់នារីរងគ្រោះឱ្យទៅធ្វើការប៉ះពាល់ និងស្ទាបអង្អែលកាន់កេរភេទរបស់បុរសម្នាក់ទៀត ទាំងដែលពួកគេមិនបានយល់ព្រមកក្នុងការធ្វើសកម្មភាពនោះឡើយ តែដោយសារតែជនល្មើសបានបង្ខំឱ្យជនរងគ្រោះ ធ្វើនូវសកម្មភាពទាំងនោះ គឺនៅចំពោះមុខរបស់ជនល្មើសផ្ទាល់តែម្តងថែមទៀត។

សរុបជារួមដោយសង្ខេបមក យើងឃើញថាអំពើនៃសកម្មភាពរបស់ជនល្មើសដែលបានប្រព្រឹត្តនៅក្នុងបទប្រទូស្តកេរខ្មាសនោះគឺមាន ៣(បី)ទម្រង់រួមមាន៖

រូបភាពទី១ ៖ ជនល្មើស បំពានលើ ជនរងគ្រោះ

រូបភាពទី២ ៖ ជនរងគ្រោះ ត្រូវបានបង្ខំឱ្យប្រព្រឹត្តលើ ជនល្មើស

រូបភាពទី៣ ៖ ជនរងគ្រោះ ត្រូវបានបង្ខំឱ្យប្រព្រឹត្តលើ តតិយបុគ្គល។[43]

**២.២.២.២.អវត្តមានការព្រមព្រៀងពីជនរងគ្រោះ**

ក្រៅពីអំពើរបស់ជនល្មើសនៅក្នុងចំណុចខាងលើនេះ គឺនៅមានចំណុចមួយទៀតផងដែរដែលជាផ្នែកមួយនៃធាតុផ្សំសត្យានុម័តនៅក្នុងបទល្មើសប្រទូស្តកេរខ្មាសនេះ គឺអវត្តមាននៃការព្រមព្រៀងពីជនរងគ្រោះ។ ជាការពិតណាស់តាមរយៈបទល្មើសប្រទូស្តកេរខ្មាសត្រង់ មាត្រា២៤៦ ក៏បានចែងផងដែរអំពីការដែលមិនមានការព្រមព្រៀងត្រង់ចំណុចដែលបាននិយាយថា បុគ្គលនោះមិនស្ម័គ្រផងទេ ដែលក្នុងឃ្លានេះបុគ្គលនោះ គឺចង់សំដៅទៅដល់ជនរងគ្រោះដែលមិនបានស្ម័គ្រចិត្តទៅនឹងទង្វើនៃការប្រព្រឹត្តរបស់ជនល្មើសឡើយ នោះបានសេចក្តីថាជនល្មើសបានប្រព្រឹត្តអំពើនោះទៅកាន់ជនរងគ្រោះទាំងដែលជនរងគ្រោះមិនបានព្រមឱ្យជនល្មើសធ្វើអំពើទាំនោះមកលើខ្លួននោះឡើយ។

ផ្ទុយមកវិញ ក្នុងករណីប្រសិនបើមានការព្រមព្រៀងគ្នាដែលបុគ្គលជាជនរងគ្រោះបានយល់ព្រមនូវអំពើខាងលើ ឬ យល់ព្រមប្រព្រឹត្តនូវអំពើទាំងនោះដែរ ត្រង់ចំណុចនេះមិនត្រូវបានចាត់ទុកថាមានបទល្មើសកើតឡើងនោះទេ។[44] ការដែលកំណត់ពីការព្រមព្រៀង ឬ មិនព្រមព្រៀង គឺអាស្រ័យទៅលើស្ថានភាពជាក់ស្តែងដែលកើតឡើង។ ក្នុងករណីមានការប្រើហិង្សា ការបង្ខិតបង្ខំ ការគំរាមកំហែង ទៅលើជនរងគ្រោះដែលទោះស្ថិតក្នុងស្ថានភាពដែលសម្តែងចេញឱ្យឃើញច្បាស់ថា ជនរងគ្រោះពុំយល់ព្រមទៅនឹងអំពើដែលជនល្មើសប្រព្រឹត្តនោះទេ យើងមិនអាចចាត់ទុកថាជាការព្រមព្រៀងឡើយ។

លើសពីនេះទៅទៀតប្រសិនជនរងគ្រោះនៅក្នុងអំពើនេះមានអាយុក្រោម ១៥ឆ្នាំ វិញនោះទោះបីជាមានការព្រមព្រៀងគ្នាយ៉ាងណាក្តីនៅតែបង្កើតឱ្យមានបទល្មើសដដែលតែជាបទល្មើសថ្មីមួយទៀត ដែលមានលក្ខណៈស្រដៀងទៅនឹងបទល្មើសប្រទូស្តកេរខ្មាសផងដែលដោយបទល្មើសនោះត្រូវបានគេឱ្យឈ្មោះថា អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម ១៥ឆ្នាំ ដែលមានចែងនៅ មាត្រា៣៤១ នៃក្រមព្រហ្មទណ្ឌ និង មាត្រា៤៣ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលត្រូវបានឱ្យនិយមន័យថាអំពើអាស គឺជាអំពើនៃការប៉ះពាល់ ឬការបង្ហាញកេរភេទ ឬផ្នែកភេទទៀតរបស់ជនដទៃ ឬការ

[43] នីតិព្រហ្មទណ្ឌពិសេស សាស្ត្រាចារ្យ កៅ សីហា ទំព័រ៤៣

[44] នីតិព្រហ្មទណ្ឌពិសេស សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ លោកស្រីសាស្ត្រចារ្យ ចាំង ស៊ីណាត ឆ្នាំ២០១៤-២០១៥

ឱ្យជនដទៃប៉ះពាល់កេរភេទ ឬផ្នែកភេទផ្សេងទៀតរបស់ជនល្មើសខ្លួនឯង ឬ របស់តតិយជន ក្នុងគោលបំណងធ្វើឱ្យរំជួល ឬរីករាយដល់ចំណង់ផ្លូវភេទរបស់ជនល្មើស។[45] ចំពោះច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទនៅត្រង់មាត្រា៤៣ក៏បានឱ្យនូវនិយមន័យដូចគ្នានេះផងដែរ។

សរុបជារួមនៅពេលដែលអំពើនៃការប្រទូស្តកេរខ្មាស ដែលប្រព្រឹត្តឡើងដោយជនល្មើសទៅលើជនរងគ្រោះដោយមិនមានការស្ម័គ្រចិត្តពីជនរងគ្រោះទេនោះអំពើនោះនឹងបង្កើតទៅជាបទល្មើស ប៉ុន្តែប្រសិនមានការយល់ព្រមពីជនរងគ្រោះវិញអំពើនោះមិនអាចបង្កើតជាបទល្មើសនោះឡើយ លើកលែងតែអនីតិជនអាយុតិចជាង១៥ឆ្នាំ ប៉ុណ្ណោះទោះមានការយល់ព្រមក៏ដោយក៏នៅតែមានបទល្មើសដដែល។

**២.២.៣.ធាតុផ្សំអត្តនោម័ត**

ជាការពិតណាស់នៅក្នុងបទល្មើសមួយ គឺមិនអាចខ្វះបានឡើយនៅនូវធាតុផ្សំណាមួយក្នុងចំណោមធាតុផ្សំទាំងបីនោះទេ ជាពិសេសធាតុអត្តនោម័តដែលជាធាតុមួយពិបាកក្នុងការកំណត់ជាងគេដោយហេតុថាវាស្ថិតនៅខាងក្នុងនៃចិត្តនៃបុគ្គលទាំងនោះ។

ធាតុផ្សំអត្តនោម័ត ឬជាទូទៅគេហៅថាធាតុចិត្តសាស្ត្រខាងក្នុងនៃបទល្មើសគឺ សំដៅទៅលើសភាពផ្លូវចិត្តខាងក្នុងរបស់ជនល្មើសដែលបានបង្ហាញចេតនានៃការប្រព្រឹត្តនៅក្នុងបទល្មើសណាមួយ។ យើងដឹងហើយថាចរិតគ្រោះថ្នាក់របស់វាគឺមិនត្រឹមតែស្តែងចេញមកខាងក្រៅតែប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងមានស្ថិតនៅក្នុងចិត្តរបស់បុគ្គលម្នាក់ៗទៀតផង។[46] ក្នុងន័យនោះដើម្បីបង្កើតបានជាបទល្មើស នោះចារីត្រូវបានប្រព្រឹត្តអំពើដោយមានកំហុសហើយកំហុសនេះទៀតសោធគឺកើតចេញមកពីឆន្ទៈរបស់ចារីផ្ទាល់។

ពោលគឺ ចារីមានឆន្ទៈសម្រេចនូវគោលដៅរបស់ខ្លួនដែលជាបទល្មើសទាំងដឹងហើយថាលទ្ធផលនៃអំពើដែលខ្លួប្រព្រឹត្តនេះ គឺផ្ទុយទៅនឹងច្បាប់យ៉ាងណាក្តីក៏ចារីនៅ តែមានចេតនាដើម្បីសម្រេចនូវអំពើរបស់ខ្លួនដដែល។ មានន័យថាចារីនៅក្នុងបទល្មើសនោះពិតជាមាននូវឆន្ទៈ និងបានដឹងផងដែលអំពីលទ្ធផលខុសច្បាប់នៃអំពើក្នុងបទល្មើសដែលខ្លួនបានប្រព្រឹត្ត។ នៅក្នុងធាតុអត្តនោម័តនេះចេតនារបស់ចារីត្រូវបានគេកត់សំគាល់ទៅកាន់ពីរចំណុចធំៗនោះ គឺចេតនាក្នុងការប្រព្រឹត្តនិងអចេតនានៅក្នុងការប្រព្រឹត្តនៅក្នុងបទល្មើសខាងក្រោមនេះយើងនឹងធ្វើការបកស្រាយលម្អិតបន្ថែមទៀតដើម្បីឱ្យយល់កាន់តែច្បាស់នៅក្នុងធាតុអត្តនោម័តនេះ។

[45] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ មាត្រា៣៤១

[46] នីតិព្រហ្មទូទៅនៅខ្មែរ សាស្ត្រាចារ្យ កៅ សីហា ទំព័រ១៣៩

### ២.២.៣.១.ចេតនាក្នុងប្រព្រឹត្ត

ជាការពិតណាស់ នៅក្នុងការប្រព្រឹត្តអំពើរបស់បុគ្គលម្នាក់តែងតែត្រូវមានការបញ្ជាក់អំពីឆន្ទៈរបស់បុគ្គលទាំងនោះផងដែរថាគាត់ចង់ប្រព្រឹត្តអំពើនោះហើយគាត់បានដឹងថាអំពើនោះ គឺជាអំពើមួយដែលបង្កនូវគ្រោះថ្នាក់ដល់សង្គមដែលច្បាប់បានហាមឃាត់។[47]

ជាក់ស្តែងនៅក្នុងបទប្រទូស្តកេរខ្មាសជាតុផ្សំអត្តនោម័តដែលជាចេតនាប្រព្រឹត្តនៅក្នុងនោះ គឺចារីដែលជាជនល្មើសនោះមានបំណង និងចេតនានៅក្នុងការប្រព្រឹត្តនូវអំពើប៉ះពាល់ស្ទាប់ និងអង្អែលទៅលើកេរភេទរបស់ជនរងគ្រោះទាំងដែលជននោះមិនបានស្ម័គ្រចិត្តនេះទេ លើសពីនេះទៅទៀតចារី ក៏មាននូវចេតនាប្រព្រឹត្តដោយស្ថិតក្នុងស្ថានភាពដែលបង្ខំឱ្យជនរងគ្រោះប្រព្រឹត្តនូវអំពើដូចខាងលើមកកាន់ខ្លួនឯងវិញ ឬ ប្រព្រឹត្តទៅកាន់តតិយជនផ្សេងទៀត។ ត្រង់ន័យនេះចារីបានដឹងរួចមកហើយថាអំពើរបស់ខ្លួន គឺខុសទៅនឹងច្បាប់បានចែងទុកជាមុនរួចមកហើយ តែចារីនៅតែមានគោលបំណងប្រព្រឹត្តនូវអំពើដែលធ្វើនឹងឱ្យប៉ះពាល់ទៅដល់ជនរងគ្រោះដដែល។

ជាកាពិតណាស់រាល់ចេតនារបស់ចារីដែលបានប្រព្រឹត្តនូវអំពើនេះឡើង គឺក្នុងគោលបំណងដើម្បីធ្វើឱ្យមានការរំជួល ឬធ្វើឱ្យរីករាយដល់ខាងផ្លូវភេទរបស់ខ្លួនឯងផ្ទាល់នោះ ហើយអំពើដែលចារីបានប្រព្រឹត្តខាងលើនេះ គឺគ្រាន់តែធ្វើការប៉ះពាល់និងស្ទាបអង្អែលទៅកាន់កេរភេទនៃជនរងគ្រោះប៉ុណ្ណោះ ដោយមិនបានប្រព្រឹត្តនូវអំពើនេះដល់ទៅជម្រៅណាមួយដូចអំពើរំលោភសេពសន្ថវៈឡើយ។

### ២.២.៣.២.អចេតនាក្នុងប្រព្រឹត្ត

អចេតនាក្នុងន័យនេះ គឺសំដៅដល់កាលដែលធ្វេសប្រហែស ដែលមិនប្រុងប្រយ័ត្ន ឬដែលខ្ជីខ្ជាដែលបំពានលើកាតព្វកិច្ច សន្តិសុខ ឬកាតព្វកិច្ចប្រុងប្រយ័ត្នដែលច្បាប់តម្រូវ។[48] ការប្រព្រឹត្តដោយអចេតនាគឺការដែលមិនមានបំណងក្នុងការធ្វើអំពើណាមួយនេះឡើយ ក៏ប៉ុន្តែអំពើនោះត្រូវបានលេចឡើងរួចមកហើយតាមរយៈការធ្វេសប្រហែសរបស់ខ្លួន។ តាមរយៈមាត្រា៤ កថាខណ្ឌទី១ នៃក្រមព្រហ្មទណ្ឌ បានចែងផងដែរថាពុំមានបទល្មើសទេ ប្រសិនបើគ្មានចេតនាប្រព្រឹត្ត។ ជាក់ស្តែងនៅក្នុងបទប្រទូស្តកេរខ្មាស ប្រសិនបើបុគ្គលនោះបានប្រព្រឹត្តនូវអំពើប៉ះពាល់ទៅកាន់កេរខ្មាស ឬ ផ្នែកភេទផ្សេងទៀតរបស់បុគ្គលដទៃ

[47] នីតិព្រហ្មទណ្ឌទូទៅនៅខ្មែរ សាស្ត្រាចារ្យ កៅ សីហា ទំព័រ១៣៩

[48] សទ្ទានុក្រមពាក្យច្បាប់ ខ្មែរ-អង់គ្លេស-បារាំង ផ្នែកព្រហ្មទណ្ឌរៀបរៀងដោយគណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ និងបោះពុម្ពផ្សាយដោយទីស្តីការគណៈរដ្ឋមន្ត្រី នៅឆ្នាំ២០១១

ដោយអចេតនា នឹងគ្មានគោលបំណងណាក្នុងការដែលធ្វើឱ្យមានការរំដួល ឬ រឹករាយដល់ចំណាងផ្លូវភេទរបស់ខ្លួននោះទេ គឺពុំត្រូវបានចាត់ទុកជាបទល្មើសនោះទេ។

**ឧទាហរណ៍៖ លោក ក** បានទៅចូលរួមការប្រគុំតន្ត្រីរបស់តារាល្បីមួយដែលមានមនុស្សចូលរួមច្រើនកុះករដែលធ្វើអោយមានភាពពិបាកក្នុងការចូលទៅខាងក្នុងនៅពេលដែល **លោក ក** ព្យាយាមចូលទៅក្នុងដោយដើរឆ្លងកាត់មនុស្សជាច្រើននោះ ស្រាប់តែដៃរបស់ **លោក ក** បានទៅប៉ះនឹងសុដន់របស់ **កញ្ញា ខ** ដោយអចេតនា ដោយសារតែមានមនុស្សច្រើនធ្វើឱ្យមានការរុញគ្នាទៅវិញទៅមកដើម្បីបានចូល។ តាមរយៈករណីនេះ **លោក ក** ពុំបានបង្កើតឱ្យមានជាបទល្មើសឡើយដោយលោកមិនមានឆន្ទៈក្នុងការប្រព្រឹត្តបទល្មើសនោះទេ។

## ២.៣.ទោសដែលត្រូវអនុវត្ត

ក្រោយពីបានស្វែងយល់ពីធាតុផ្សំនៃបទល្មើសនៃអំពើប្រទូស្តកេរខ្មាសរួមមក ចំណុចបន្ទាប់នេះយើងនឹងឈានមកដល់ទោសដែលមានកំណត់នៅក្នុងបទលល្មើសប្រទូស្តកេរខ្មាសម្តង ថាតើនៅក្នុងអំពើប្រទូស្តកេរខ្មាសគេកំណត់ការផ្តន្ទាទោសបែបណា និងមាននូវស្ថានទម្ងន់ទោសយ៉ាងណាខ្លះ ដើម្បីឱ្យយល់កាន់តែច្បាស់ខាងក្រោមនេះយើងខ្ញុំនឹងធ្វើការបកស្រាយជូន។

ទោស គឺសំដៅដល់ទណ្ឌកម្មដែលត្រូវផ្តន្ទាទោសដោយ សង្គមតាមរយៈច្បាប់ទៅលើរាល់បុគ្គលទាំងឡាយណាដែលបានប្រព្រឹត្តបទល្មើស។[49] យ៉ាងណាមិញទោសត្រូវបានកំណត់ឡើងដើមការពារនូវផលប្រយោជន៍សង្គមទាំងមូល រាល់ការកំណត់មានគោលបំណងដើម្បីធ្វើការផ្តន្ទាទោសទៅបុគ្គលដែលប្រព្រឹត្តខុសឱ្យមានភាពរាងចាល និងមិនប្រព្រឹត្តបទល្មើសណាផ្សេងតទៅទៀតក្រោយពីបានអនុវត្តទោសរួចរាល់។ ជាការពិតណាស់ទោសដែលមានកំណត់នៅក្នុងក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាដែលមានមូលទោសនិងទោសបន្ថែម។ ខាងក្រោមយើងខ្ញុំសូមអនុញ្ញាតធ្វើការបកស្រាយអំពីទោស ដែលត្រូវបានយកអនុវត្តនៅក្នុងបទល្មើសប្រទូស្តកេរខ្មាស។

### ២.៣.១.មូលទោសនៃបទប្រទូស្តកេរខ្មាស

ជាការពិតណាស់ នៅគ្រប់បទល្មើសទាំងអស់សុទ្ធសឹងតែមានមូលទោសរួមផ្សំមកជាមួយនឹងបទល្មើសទាំងនោះ។ នៅក្នុងក្រមព្រហ្មទណ្ឌយើងតាមរយៈ មាត្រា៤៣ ក៏បានចែងផងដែរអំពីមូលទោសដោយ

[49] នីតិព្រហ្មទណ្ឌទូទៅ សាស្ត្រចារ្យ រុន ពណ្ណារិទ្ធ លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០២២

ក្នុងនោះបានប្បញ្ញត្តិថា មូលទោសរួមមាន ទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់។[50] លើសពីនោះទៅទៀតរាល់ការពិន័យជាប្រាក់នៅក្នុងមូលទោសនោះគឺ ការពិន័យត្រូវគិតជាប្រាក់រៀល។[51]

ជាក់ស្តែងនៅក្នុងបទប្រទូស្តកេរខ្មាសក៏មានកំណត់ផងដែរអំពីមូលទោសនៅក្នុងបទល្មើសនេះ ដោយនៅក្នុងនោះបានកំណត់ថាអំពើប្រទូស្តកេរខ្មាសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ)ឆ្នាំ ទៅ ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី ២ ០០០ ០០០(ពីរលាន) រៀលទៅ ៦ ០០០ ០០០ (ប្រាំមួយលាន)រៀល។[52]

ដោយតាមរយៈបទល្មើសប្រទូស្តកេរខ្មាសនេះគួរកត់សម្គាល់ផងដែរថា គឺមាននូវទោសដាក់ពន្ធនាគារផង និងទោសពិន័យជាប្រាក់ផងដែលបូករួមផ្សំមកជាមួយគ្នាថែមទៀតផង។ រីឯច្បាប់ព្រហ្មទណ្ឌអន្តរកាលក៏កំណត់ពីការផ្តន្ទាទោសផងដែរចំពោះអំពើបៀតបៀនដល់កេរ្តិ៍ខ្មាស់ដោយត្រូវផ្តន្ទាទោសដាក់គុកពី ១ (មួយ)ឆ្នាំ ទៅ ៣ (បី) ឆ្នាំ។ ចំពោះនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរកាលនេះទៀតសោធ គឺបានកំណត់តែទោសដាក់ពន្ធនាគារប៉ុណ្ណោះ ដោយមិនមានការកំណត់ពីទោសពិន័យជាប្រាក់ឡើយ។

### ២.៣.២.ស្ថានទម្ងន់ទោស

ស្ថានទម្ងន់ទោស គឺចង់សំដៅទៅដល់ស្ថានភាពមួយដែលច្បាប់បានកំណត់ទុកជាមុនមករួចជាស្រេចយ៉ាងច្បាស់លាស់អំពីការផ្តន្ទាទោសបន្ថែមដោយមានស្ថានភាពធ្ងន់ធ្ងរជាងមុនពោលនោះ គឺនៅពេលដែរជនល្មើសទទួលបានការផ្តន្ទាទោសហើយតែមិនរាងចាល ឬ ការប្រព្រឹត្តរបស់ជនល្មើសទាក់ទងទៅនឹងស្ថានភាព នៃជនរងគ្រោះ ឬ ស្ថានភាពដែលទាក់ទងទៅនឹងចារីផ្ទាល់ជាដើម។ តាមរយៈមាត្រា៨៣ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាបានប្បញ្ញតមកថា ការមិនរាងចាលមានអានុភាពនាំឱ្យមានការបន្ថែមទម្ងន់អតិបរមានៃទោសដាក់ពន្ធនាគារ ចំពោះបទល្មើសឧក្រិដ្ឋ ឬមជ្ឈិមក្នុងលក្ខខណ្ឌមានចែងដោយកថាភាគនេះ។[53]

ការមិនរាងចាល គឺត្រូវបានសម្តែងឱ្យឃើញពីភាពបរាជ័យនៃការដែលផ្តន្ទាទោសជាស្ថាពរកាលពីលើកមុន ដោយសារតែជនល្មើសបានប្រពឹត្តបទល្មើសថ្មីមួយទៀតដែលត្រូវបានបំពេញនូវលក្ខខណ្ឌ នៃច្បាប់កំណត់ដែលទាក់ទងទៅនឹងការមិនរាងចាល។ ក្រៅពីស្ថានទម្ងន់ទោសនៃការមិនរាងចាល ក៏នៅមានស្ថានភាពផ្សេងទៀតផងដែរដូចជាស្ថានភាពដែលទាក់ទងទៅនិងជនរងគ្រោះ និងស្ថានភាពដែលទាក់ទង

[50] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ មាត្រា៤៣ កថាខណ្ឌទី១

[51] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ មាត្រា៤៣ កថាខណ្ឌទី២

[52] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ មាត្រា២៤៦ កថាខណ្ឌទី២

[53] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ មាត្រា៨៣

ទៅនឹងចារីផ្ទាល់ក៏ជាស្ថានភាពមួយក្នុងចំណោមស្ថានទម្ងន់ទោសដែលក្រមព្រហ្មទណ្ឌបានកំណតផងដែរ ខាងក្រោមនេះយើងខ្ញុំសូមធ្វើការអនុញ្ញាតធ្វើការបកស្រាយពី ស្ថានទម្ងន់ទោសទាក់ទងនឹងស្ថានភាពទាំងពីរនៃបទប្រទូស្តកេរខ្មាស។

**ក.ស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ**

ជាការពិតណាស់ក្រៅពីស្ថានទម្ងន់ទោសដែលទាក់ទង់ទៅនឹងស្ថានភាព ដែលមិនរាងចាលរបស់ចារីនោះ នៅមានស្ថានភាពផ្សេងៗទៀតដែលច្បាប់ព្រហ្មទណ្ឌបានកំណត់យកមកធ្វើជាស្ថានទម្ងន់ទោសផងដែរ។ ខាងក្រោមនេះយើងនឹងធ្វើការបកស្រាយពីស្ថានទម្ងន់ទោសដែលទាក់ទងទៅនឹងជនរងគ្រោះ ដើម្បីជាពុទ្ធិចង្អុលបង្ហាញបន្ថែមទៅលើស្ថានទម្ងន់ទោសនៃអំពើប្រទូស្តកេរខ្មាស។

ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ គឺសំដៅទៅដល់ស្ថានភាពនៃជនរងគ្រោះដែលត្រូវបានច្បាប់ព្រហ្មទណ្ឌបានកំណត់ទុកជាមុន ឬយកមកធ្វើជាស្ថានទម្ងន់ទោសនៃបទល្មើសដើម្បីការពារដល់ជនគ្រោះទាំងឡាយដែលមាន ស្ថានភាពទន់ខ្សោយពិសេសដោយមូលហេតុអាយុ ស្ថានភាពមានជំងឺមានពិការភាព ឬមានគភ៌ជាដើម។ ទន្ទឹមនឹងនេះយោងតាមរយៈ មាត្រា២៤៨ ដែលបានបញ្ញត្តិពីស្ថានទម្ងន់ទោសដែលមាននៅក្នុងអំពើប្រទូស្តកេរខ្មាសដែរបានកំណត់ចែងថាត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២(ពីរ) ឆ្នាំទៅ ៥ (ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី ៤ ០០០ ០០០ (បួនលាន) រៀល ទៅ ១០ ០០០ ០០០ (ដប់លាន) រៀល ។[54] ក្នុងករណីប្រសិនបើចារីបានប្រព្រឹត្តអំពើប្រទូស្តកេរខ្មាសស្ថិតក្នុងស្ថានភាពណាមួយដូចខាងក្រោមនេះ ដែលត្រូវនឹងលក្ខខណ្ឌមួយចំនួនដែលជាស្ថានទម្ងន់ទោសដែលទាក់ទងទៅនឹងជនរងគ្រោះ។ ដោយស្ថានភាពដែលទាក់ទងទៅនឹងជនរងគ្រោះបានកំណត់នៅក្នុងច្បាប់ព្រហ្មទណ្ឌបានចែងនូវស្ថានភាពមួយចំនួនដែលជាលក្ខខណ្ឌនៃស្ថានទម្ងន់ទោសដែលចារីបានប្រព្រឹត្តទៅលើ ៖

- **ទៅលើបុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុអាយុនៃបុគ្គលនោះ**[55]

**ឧទាហរណ៍៖ បុរស ក** បានទៅអង្គុយផឹកអីនៅក្នុងម៉ាតមួយកន្លែងនៅជិតសាលារៀនមួយ។ បន្តិចក្រោយមកក៏មានសិស្សាសាលាស្រីម្នាក់ (នារី ខ ) អាយុប្រហែល១៦ ១៧ ឆ្នាំបានចូលមកក្នុងម៉ាតនោះក្នុងគោលបំណងដើម្បីផឹកអីដូចគ្នា។ នៅពេលដែលក្មេងស្រីនោះកំពុងអង្គុយផឹកនៅក្បែរនឹង **បុរស ក** នៅពេល

[54] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ មាត្រា២៤៨

[55] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ មាត្រា២៤៨ ចំណុចទី១

នោះស្រាប់ពេលនោះ**បុរស ក** ក៏បានលូកដៃទៅស្ទាប់ និងអង្អែលទៅកាន់កេរភេទរបស់ក្មេងស្រីម្នាក់នោះ ដែលធ្វើឱ្យនាងភ័យខ្លាចនិងបានស្រែកយំនៅទីនោះ។

តាមរយៈអង្គហេតុខាងលើអំពើរបស់ **បុរស ក** គឺជាអំពើប្រទូស្តកេរខ្មាសដែលមាននូវស្ថានទម្ងន់ទោស ដោយសារតែចារីបានប្រព្រឹត្តអំពើប្រទូស្តកេរខ្មាសទៅកាន់ក្មេងស្រីដែលមានអាយុទើបតែ ១៦ ១៧ ឆ្នាំ ប៉ុណ្ណោះដែលក្មេងស្រីនោះត្រូវបានការពារដោយច្បាប់ដោយចាត់ទុកជាបុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុនៃអាយុ ដោយជនរងគ្រោះគឺជាអនីតិជន។

- **ទៅលើនារីមានគភ៌ កាលបើគភ៌ត្រូវបានឃើញជាក់ស្តែង ឬ កាលបើជនល្មើសបានដឹង**[56]

**ឧទាហរណ៍៖ លោកស្រី ក** បានធ្វើការនៅក្រុមហ៊ុនធានារ៉ាប់រងមួយកន្លែងនៅទីរួមខេត្តដោយនៅកន្លែងធ្វើការងាររបស់លោកស្រីភាគច្រើនមានមនុស្សស្រីច្រើនជាងបុរស។ **លោក ខ** ដែលជាអ្នកគ្រប់គ្រងរបស់ **លោកស្រី ក** បានលួចស្រលាញ់លោកស្រីទោះបីដឹងថាលោកស្រីទើបតែរៀបការនិងកំពុងតែពរពោះហើយក៏ពិតមែនក៏ **លោក ខ** នៅតែតាមលេបខាយសម្តីដាក់លោកស្រីជាពីយៗ។ ថ្ងៃមួយនៅកន្លែហូបអាហារថ្ងៃត្រង់នៅក្នុងក្រុមហ៊ុន **លោក ខ** បានឃើញ **លោកស្រី ក** នៅអង្គុយម្នាក់ឯងនោះ **លោក ខ** ក៏ចូលទៅអង្គុយជិតនិងបាននិយាយលេបខាយសម្តីដូចរាល់ដង ក៏ប៉ុន្តែដោយសារឃើញថានៅកន្លែងស្ងាត់តែពីរនាក់បែបនេះ **លោក ខ** ក៏បានឆ្លៀតឱកាសបង្ខំឱ្យ **លោកស្រី ក** ធ្វើការស្ទាបអង្អែលប្រដាប់ភេទរបស់ខ្លួនដើម្បីឱ្យរីករាយដល់ចំណងផ្លូវភេទរបស់ខ្លួនបើទោះបីជាដឹងរួចមកហើយថា **លោកស្រី ក** កំពុងពរពោះយ៉ាងណាក្តីក៏លោកនៅតែបង្ខិតបង្ខំលោកស្រីដដែល។

ដូច្នេះ ទង្វើរបស់ **លោក ខ** បានធ្វើទៅកាន់ **លោកស្រី ក** គឺជាអំពើប្រទូស្តកេរខ្មាសដែលមានស្ថានទម្ងន់ទោសទាក់ទងទៅនឹងអំពើដែលប្រព្រឹត្តទៅលើនារីមានគភ៌ លើសពីនេះទៅទៀតគភ៌របស់ **លោកស្រី ក** គឺគេដឹង និងបានឃើញជាក់ស្តែង។

- **ទៅលើបុគ្គលដែលទន់ខ្សោយពិសេសដោយមូលហេតុនៃជម្ងឺ ឬ ពិការភាពកាលបើស្ថានភាពបុគ្គលនោះត្រូវបានគេឃើញជាក់ស្តែង ឬ កាលបើជនល្មើសបានដឹង**[57]

**ឧទាហរណ៍៖ លោក ក** បានឃើញនារីម្នាក់ដើរនៅតាមផ្លូវដែលជាទូទៅគេបានដឹងហើយថា នារីម្នាក់នោះមានជម្ងឺដោយសារពាងកាយនាងមានលក្ខណៈទន់ខ្សោយខុសពីគេដទៃ។ នៅពេលដែលនាងដើរមក

---
[56] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ មាត្រា២៤៨ ចំណុចទី២

[57] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ មាត្រា២៤៨ ចំណុចទី៣

ជិតដល់ **លោក ក** ស្រាប់តែ **លោក ក** បានដើរប៉ះគូទ និងផ្នែកផ្សេងៗទៀតនៃកេរភេទរបស់នាងដោយគិតថានាងទន់ខ្សោយ និងមិនអាចតដៃនិងគាត់បាន ហេតុននេះហើយ **លោក ក** បានធ្វើអំពើនេះដោយមិនខ្លាចរអានោះឡើយ។ ប៉ុន្តែផ្ទុយមកវិញ នៅពេលនោះក៏មានគេមកឃើញក៏បានប្ដឹងទៅខាងនគរបាល ដើម្បីអន្តរាគមន៍ទៅកាន់**លោក ក** ភ្លាមៗ។

តាមរយៈអំពើដែល **លោក ក** បានប្រព្រឹត្តគឺជាអំពើប្រទូស្តកេរខ្មាសដែលមានស្ថានទម្ងន់ទោសទាក់ទងទៅនឹងអំពើដែលប្រព្រឹតទៅលើបុគ្គលទន់ខ្សោយពិសេសដោយមូលហេតុជម្ងឺពោលគឺ **លោក ក** បានប្រព្រឹត្តអំពើប្រទូស្តកេរខ្មាសទៅកាន់ នារីរងគ្រោះដែលមានជម្ងឺដោយសារពាងកាយទន់ខ្សោយហើយមនុស្សទូទៅគឺបានដឹងគ្រប់គ្នា។

**ខ.ស្ថានទម្ងន់ទោសទាក់ទងនឹងចារី**

ក្រោយពីបានស្វែងយល់បានច្បាស់រួចរាលពីស្ថានភាពមួយចំនួន នៃស្ថានទម្ងន់ទោសដែលទាក់ទងនឹងជនរងគ្រោះរួចមកនៅក្នុងចំណុចនេះយើងនឹងធ្វើការបកស្រាយអំពីស្ថានទម្ងន់ទោសមួយផ្សេងទៀត ដែលជាស្ថានភាពនៃស្ថានទម្ងន់ទោសទាក់ទងនឹងចារីម្តង ដើម្បីឱ្យយើងបានយល់កាន់តែច្បាស់និងស៊ីជម្រៅបន្ថែមទៀតអំពីស្ថានទម្ងន់ទោសដែលមាននៅក្នុងបទប្រទូស្តកេរខ្មាសនេះ។

ស្ថានទម្ងន់ទោសដែលទាក់ទងនឹងចារី គឺចង់សំដៅទៅលើស្ថានភាពមួយដែលច្បាប់បានកំណត់អំពីសកម្មភាពដែលចារីផ្ទាល់ប្រព្រឹត្ត ហើយត្រូវបានច្បាប់កំណត់យកមកធ្វើជាស្ថានទម្ងន់ទោសទៅអំពើដែលបានប្រព្រឹត្តនោះ ថាតើសកម្មភាពនៃអំពើដែលចារីបានប្រព្រឹត្តឡើងនោះបានបង្ហាញពីភាពធ្ងន់ធរបែបណាខ្លះ បន្ថែមពីលើនេះទៅទៀតគឺចង់បង្ហាញកាន់តែច្បាស់ពីស្ថានភាពដែលទាក់នឹងមធ្យបាយដែលចារីបានប្រព្រឹត្ត ឬស្ថានភាពផ្សេងៗទៀតដែលមានលក្ខណៈធ្ងន់ធ្ងរជាដើម។ នៅក្នុងបទប្រទូស្តកេរខ្មាសក៏មានចែងផងដែលអំពីស្ថានទម្ងន់ទោសដែលទាក់ទងនឹងការប្រើប្រាស់មធ្យោបាយ និងចារីផងដែរ តាមយៈមាត្រា២៤៧ បានចែងអំពីមូលទោសដែលជាស្ថានទម្ងន់ទោសនៅក្នុងនោះថាត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល។[58] ស្ថានទម្ងន់ទោសនេះនឹងត្រូវផ្តន្ទាទោសកាលបើចារីបាននូវអំពើប្រព្រឹត្តនូវអំពើប្រទូស្តកេរខ្មាសស្ថិតនៅក្នុងស្ថានភាពណាមួយដូចខាងក្រោមនេះ៖

[58] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ មាត្រា២៤៧

- **ដោយការប្រើអាវុធ ឬ ការគំរាមកំហែងនឹងអាវុធ**

**ឧទាហរណ៍៖ លោក ក** រស់នៅតាមទីជនបទជាកសិកធ្វើស្រែចំការនៅពេលព្រឹកព្រលឹមថ្ងៃរះ **លោក ក** បានធ្វើដំណើរទៅកាន់ស្រែរបស់ **លោក ក** នៅពេលដែលធ្វើដំណើរកាត់ត្រពាំងនៅតាមផ្លូវ **លោក ក** បានឃើញ **នារី ខ** កំពុងចង់ពង់ងូតទឹកនៅក្បែរនោះដោយទប់អារម្មណ៍ពុំបាន **លោក ក** ក៏បានចុះទៅងូតទឹកក្នុងត្រពាំងនោះដែល នៅពេល **នារី ខ** ឃើញបែបនេះនាងរៀបចំចេញពីទីនោះ ប៉ុន្តែនៅពេលនាងរៀបចំនឹងចាក់ចេញទៅហើយដោយមិនចង់ឱ្យបាត់បង់ឱកាស់នោះស្រាប់តែពេលនេះ **លោក ក** ក៏បានយាត់នឹងបានយកកាំបិតផ្គាក់មកគំរាមនាង និងធ្វើការប៉ះពាល់ ស្ទាបអង្អែលលើរាងកាយរបស់នាងថែមទៀតផងរហូលដល់នាងបានស្រែកឱ្យគេជួយ ទើប **លោក ក** ដោះលែងនាងវិញ។

ហេតុដូចនេះសកម្មភាពដែល **លោក ក** បានធ្វើទៅកាន់ **នារី ខ** គឺវាអំពើប្រទូស្តកេខ្មាសដែលមានស្ថានទម្ងន់ទោសទាក់ទងនឹងការប្រើអាវុធ និងគំរាមកំហែងដោយប្រើអាវុធ។ ពោលគឺ **លោក ក** បានយកកាំបិតផ្គាក់ទៅគំរាមគំហែង **នារី ខ** ដែលជាជនរងគ្រោះដើម្បីបានធ្វើការប៉ះពាល់លើរាងកាយរបស់នាង។

- **ដោយការប្រើប្រាសគ្រឿងញៀន ឬ គ្រប់វិធីដែលនាំឱ្យជនរងគ្រោះបាត់បង់ ឬចុះខ្សោយលទ្ធភាពទប់ទល់**

ឧទាហរណ៍៖ **នារី ក** បានទៅកំសាន្តលេងនៅខ្លឹបមួយកន្លែង ដើម្បីលំហែរអារម្មណ៍របស់ខ្លួននៅថ្ងៃចុងសប្តាហ៍។ នៅពេល **នារី ក** កំពុងតែអង្គុយតែម្នាក់ឯងនោះក៏មានបុរសម្នាក់ដែលជា **លោក ខ** មកសុំនាងអង្គុយជាមួយដោយចង់និយាយលេងជាមួយនាង នៅពេលនោះ **លោក ខ** បានលួងលោម**នារី ក** ឱ្យហូបគ្រឿងស្រវឹងដោយបានឱ្យនាងលើកដាច់ម្តងហើយម្តងទៀតរហូតដល់នាងស្រវឹងទន់ដៃទន់ជើង **លោក ខ** ក៏បានលួចដាក់ថ្នាំសណ្តំនៅក្នុងកែវរបស់នាង ដោយឃើញឱកាសល្អ **លោក ខ** ក៏មានបន្លំធ្វើការស្ទាបអង្អែលទៅកាន់រាងកាយរបស់នាងរហូរឈានដល់ការប៉ះពាល់កេរភេទរបស់នាងថែមទៀតផង។ ដោយនៅពេលនោះនាងបានស្រវឹងផង និងត្រូវថ្នាំផងនោះនាងមិនមានកម្លាំងនឹងរើបំរាសចេញពីប៉ះពាល់របស់ **លោក ខ** បានឡើយ។

ដូច្នេះសកម្មភាពដែល **លោក ខ** បានប្រព្រឹត្តគឺជាបទប្រទូស្តកេរខ្មាសដែលមានស្ថានទម្ងន់ទោសទាក់ទងនឹងការប្រើវិធីដែលនាំឱ្យជនរងគ្រោះបាត់បង់ ឬ ចុះខ្សោយសមត្ថភាពទប់ទប់។ ពោលគឺដូចដែល

**លោក ខ** បានលួងលោមឱ្យផឹកគ្រឿងស្រវឹងនិងបានដាក់ថ្នាំសណ្តំនៅក្នុងកែវ **នារី ខ** ហើយក៏ប្រព្រឹត្តអំពើនូវប្រទូស្តកេរខ្មាស។

– **ដោយបុគ្គលដែលមានអំណាចទៅលើជនរងគ្រោះ**

**ឧទាហរណ៍៖ នារី ក** បានមកស្នាក់នៅនៅផ្ទះរបស់ **លោក ខ** ដែលត្រូវជាឪពុកមារបស់នាងដើម្បីមករៀនបន្តនៅភ្នំពេញ ដោយបានជួយធ្វើការងារនៅក្នុងផ្ទះ និងចម្អិនម្ហូបអាហារជាដើម្បី។ នៅពេលដែលនាងបានទៅធ្វើការបោសសម្អាតទៅដល់បន្ទប់របស់ **លោក ខ** ស្រាប់តែ **លោក ខ** បានដើរចេញពីបន្ទប់ទឹកក៏បានឃើញ **នារី ក** កំពុងតែធ្វើការបោសសម្អាតនៅទីនោះ **លោក ខ** បានដើរទៅប៉ះពាល់រាងកាយរបស់នាងហើយថែមទាំងបង្ខំនាងឱ្យលេងកេរភេទរបស់ខ្លួនថែមទៀតនៅពេលនោះ **នារី ក** មិនព្រមនោះឡើយហើយ **លោក ខ** ក៏បានប្រើអំណាចដែលខ្លួនជាឪពុកមាធ្វើការគំរាមកំហែងនាងឱ្យធ្វើសកម្មភាពទាំងនោះ។

ដោយតាមរយៈសកម្មភាពដែល **លោក ខ** បានប្រព្រឹត្តនោះវាគឺជាបទល្មើសប្រទូស្តកេរខ្មាសដែលមានស្ថានទម្ងន់ទោសដោយបុគ្គលដែលមានអំណាចទៅលើជនរងគ្រោះពោលនោះគឺ **លោក ខ** បានប្រើប្រាស់អំណាចដែលខ្លួនជាឪពុកមាបង្ខំឱ្យ **នារី ក** ដែលជាជនរងគ្រោះ។

– **ដោយបុគ្គលដែលរំលោភអំណាចដែលមុខងាររបស់ខ្លួនបានប្រគល់ឱ្យ**

**ឧទាហរណ៍៖ លោក ក** ជាប្រធានការិយាល័យមួយដែលបម្រើការនៅស្ថាប័នមួយកន្លែង លោកមានជំនួយការស្រីម្នាក់ដែលជា **កញ្ញា ខ** ធ្វើនៅក្នុងស្ថាប័នជាមួយគ្នា។ នៅពេលមួយលោក ក ក៏បាននិយាយគ្នាជាមួយ**កញ្ញា ខ** អំពីរឿងឡើងដំណែង **លោក ក** បានបន្ថែមទៀតថាប្រសិននាងចង់ឡើងដំណែងលឿននោះនាងគួតែធ្វើតាមគាត់ព្រោះគាត់ជាប្រធាន។ **លោក ក** បានបង្ខំឱ្យ **កញ្ញា ខ** ធ្វើការប៉ះពាល់ និងលេងនូវប្រដាប់ភេទរបស់ខ្លួនដើម្បីឱ្យមានចំណង់រីករាយខាងផ្លូវភេទរបស់ខ្លួន លោកនិយាយទៀតថាប្រសិននាងធ្វើតាមគាត់នោះ **កញ្ញា ខ** និងបានឡើងដំណែងឆាប់ៗ តែនៅពេលនោះ **កញ្ញា ខ** នាងមិនព្រមនោះឡើយ។

តាមរយៈអំពើនិងសកម្មភាពរបស់ **លោក ក** ខាងលើគឺជាអំពើប្រទូស្តកេរខ្មាសដែលមាននូវស្ថានទម្ងន់ទោសទាក់ទងនឹងការរំលោភអំណាចដែលមុខងាររបស់ខ្លួនប្រគល់ឱ្យ ដោយហេតុថាលោកបានយកអំណាចរបស់ខ្លួនថានឹងឡើងដំណែងឱ្យ **កញ្ញា ខ** ប្រសិនបើនាងព្រមធ្វើតាមអ្វីដែលលោកប្រាប់នោះ។

– **ដោយបុគ្គលច្រើនរូប ដែលប្រព្រឹត្តឡើងក្នុងឋានៈជាចារី សហចារី អ្នកផ្តើមគំនិត ឬ ជាអ្នកសមគំនិត**

**ឧទាហរណ៍៖ លោក ក** និង**លោក ខ** បានផឹកគ្រឿងស្រវឹងនៅក្នុងហាងមួយកន្លែងបន្ទាប់ពីផឹកចប់ដោយមិនទាន់ស្រវឹងផងនោះ **លោក ក** ក៏បានបបួល **លោក ខ** ទៅផឹកនៅមួយកន្លែងទៀតនៅក្បែរនោះ។ នៅពេលដែលធ្វើដំណើរនៅតាមផ្លូវនោះស្រាប់តែពួកគេបានឃើញ **នារី គ** ដើរស្របគ្នាតាមផ្លូវនោះផងដែរ ដោយឃើញ **នារី គ** នោះស្រស់ស្អាតពេកដោយទ្រាំពុំបានពួកគេក៏បបួលគ្នាដើរតាម **នារី គ** នោះបន្តិចក្រោយមកនៅពេលដែលដើរដល់ផ្លូវស្ងាត់មួយកន្លែងពួកគេក៏បានចាប់នារីនោះដោយបានធ្វើការប៉ះពាល់ស្ទាបអង្អែលទៅលើកេរភេទ និងសុដន់របស់នាង ព្រមទាំងបង្ខំឱ្យនាងធ្វើការលេងនូវប្រដាប់ភេទរបស់ខ្លួនថែមទៀតផងតែមិនបានស៊ីជម្រៅនោះគេ ដោយ**នារី គ** បានស្រែកឱ្យគេជួយផងនោះពួកគេក៏បាននាំគ្នារត់ទៅបាត់។

តាមរយៈសកម្មភាពរបស់ **លោក ក** និង**លោក ខ** បានប្រព្រឹតនោះជាអំពើប្រទូស្តកេរខ្មាស់ដែលមានស្ថានទម្ងន់ទោសទាក់ទងនឹងការប្រព្រឹតឡើងដែលមានបុគ្គលច្រើនរូប ដែលក្នុងឋានៈជាសហចារីព្រោះតែអំពើនោះប្រព្រឹត្តឡើងដោយមានការចូលរួមពីសំណាក់ **លោក ក** និង**លោក ខ** ដែលបានប្រព្រឹត្តរួមគ្នាដែលស្ថិតនៅក្នុងអំពើប្រទូស្តកេរខ្មាសនោះ។

និយាយជារួមមក ក្រោយពីបានសិក្សាកាន់តែស៊ីជម្រៅអំពីទោសដែលអាចនឹងត្រូវផ្តន្ទានៅក្នុង អំពើប្រទូស្តកេរខ្មាសរួមមកយើងឃើញថា មានលក្ខខណ្ឌជាច្រើនដែលច្បាប់ព្រហ្មទណ្ឌបានកំណត់ទុកជាមុនដែលអាចយកមកសិក្សាធ្វើជាមូលទោស និងស្ថានទម្ងន់ទោសនៅក្នុងបទប្រទូស្តកេរខ្មាសនេះ។ ប្រសិនបើចារីបានប្រព្រឹត្តនូវអំពើប្រទូស្តកេរខ្មាសឡើង ហើយត្រូវបានបំពេញនូវលក្ខខណ្ឌខាងលើនោះចារីនឹងបានផ្តន្ទាទោសពីបទប្រទូស្តកេរខ្មាសដោយមានស្ថានទម្ងន់ទោសយ៉ាងពិតប្រាកដ។

### ២.៣.៣.ការប៉ុនប៉ងនៅក្នុងបទប្រទូស្តកេរខ្មាស

ជាការពិតណាស់ ប្រសិនបើពេលបទល្មើសមួយបានប្រព្រឹត្តឡើងមកហើយបានសម្រេចនូវលទ្ធិផលទៀតនោះនឹងត្រូវចាប់ទុកថាជាបទល្មើសដូចដែលច្បាប់បានកំណត់។ ក៏ប៉ុន្តែច្បាប់ក៏មិនបានតម្រូវថាទាល់តែបទល្មើសនេះបានសម្រេចទើបអាចផ្តន្ទាទោសនោះទេ ជួនកាលគេក៏អាចធ្វើការផ្តន្ទាទោសបានផងដែរដោយមិនចាំបាច់រងចាំរហូតដល់បទល្មើសនោះបានសម្រេចនូវលទ្ធិផលនោះទេពោល គឺប្រសិនបើចារីមានគំនិតប្រព្រឹត្តនូវបទល្មើសឡើងនោះឡើងហើយបានចាប់ផ្តើមដំណើការនៃការប្រព្រឹត្តនោះ ប៉ុន្តែត្រូវបានរាំងស្ទះ ឬ អាក់ខានដោយមិនមែនជាការស្ម័គ្រចិត្តនោះទេ អំពើនេះត្រូវបានគេហៅថា ការប៉ុនប៉ង

ប្រព្រឹត្តបទល្មើស។ តាមរយៈក្រមព្រហ្មទណ្ឌបានបញ្ជាក់ពីនិយមន័យនៃការប៉ុនប៉ងនេះថាការប៉ុនប៉ងក្នុងបទឧក្រិដ្ឋ ឬក្នុងករណីដែលច្បាប់បានចែងទុកក្នុងបទមជ្ឈិមអាចត្រូវផ្ដន្ទាទោសបាន កាលណាលក្ខខណ្ឌខាងក្រោមនេះត្រូវបានបំពេញៈ

- ចារីបានចាប់ផ្ដើមអនុវត្តបទល្មើសមានន័យថា ចារីបានប្រព្រឹត្តអំពើដែលមានគោលបំណងដោយផ្ទាល់ដើម្បីប្រព្រឹត្តបទល្មើស
- ចារីមិនបានបញ្ឈប់អំពើរបស់ខ្លួនទៅវិញដោយស្ម័គ្រចិត្ត តែត្រូវបានរាំងស្ទះ ឬ អាក់ខានដោយសារឥទ្ធិពលនៃកាលៈទេសៈ ក្រៅឆន្ទៈរបស់លខ្លួន។[59]

លើសពីនោះទៅទៀតនៅក្នុងបទប្រទូស្តកេរខ្មាស ក៏មានបញ្ញត្តិអំពីការប៉ុនប៉ងនៅក្នុងការប្រព្រឹត្តនូវអំពើប្រទូស្តកេរខ្មាសនោះផងដែរ ដោយយោងតាម មាត្រា២៥១ បានបញ្ញាត្តថា ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងក្នុងផ្នែកនេះ ត្រូវផ្ដន្ទាទោសដូចគ្នានឹងបទមជ្ឈិមខាងលើដែរ។[60] ពោលគឺប្រសិនបើចារីប្រព្រឹត្តនូវអំពើប្រទូស្តកេរខ្មាស ហើយអំពើនោះត្រូវបានអាក់ខាន ឬត្រូវបានរាំងស្ទះដោយប្រការណាមួយដែលមិនមែនជាឆន្ទៈដែលចារីចង់បញ្ឈប់នោះទេនោះអំពើរបស់ចារីដែលប្រព្រឹត្តមិនបានសម្រេចនោះ ត្រូវចាប់ទុកថាជាការប៉ុនប៉ងក្នុងការប្រព្រឹត្តអំពើប្រទូស្តកេរខ្មាស និងត្រូវបានធ្វើការផ្ដន្ទាទោសដូចគ្នាទៅនឹងបទប្រទូស្តកេរខ្មាសដូចគ្នា។

### ២.៣.៤.ទោសបន្ថែមនៃបទប្រទូស្តកេរខ្មាស

ដូចដែលយើងបានដឹងហើយថាក្រៅពីមូលទោសដែលយើងបានរៀបរាប់ខាងលើនោះ គឺនៅមានទោសបន្ថែមមួយចំនួនទៀតផងដែរ ដែលច្បាប់ព្រហ្មទណ្ឌយើងបានកំណត់ដើម្បីយកមកប្រកាសបន្ថែមទៀតទៅលើមូលទោស។ ពោលគឺ ទោសបន្ថែមនោះតុលាការអាចធ្វើការប្រកាសទោសបន្ថែមនេះពីលើមូលទោសដែលច្បាប់បានកំណត់នៅក្នុងល្មើសណាមួយបានប្រសិនបើតុលាការយល់ឃើញថាចាំបាច់ក្នុងការប្រកាសពីទោសបន្ថែមនេះ។

ជាក់ស្តែងនៅបទប្រទូស្តកេរខ្មាស ដែលជាផ្នែកមួយស្ថិតនៅក្នុងអំពើដែលចាត់ទុកថាជាការបំពានខាងផ្លូវភេទដទៃទៀតនៃក្រមព្រហ្មទណ្ឌក៏បានធ្វើការកំណត់នូវទោសបន្ថែមនៅក្នុងអំពើប្រទូស្តកេរខ្មាសនេះ

[59] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ មាត្រា២៧ កថាខណ្ឌទី១

[60] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ មាត្រា២៥១

ផងដែល។ ដោយយោងតាមរយៈ មាត្រា២៥២ បានបញ្ញត្តអំពីទោសបន្ថែមដែលមានកំណត់ពីប្រភេទ និង រយៈពេលដែលត្រូវអនុវត្តផងដែល ។

នៅក្នុងបញ្ញត្តិនៃ មាត្រា២៥២ នេះបានចែងពីទោសបន្ថែមដែលត្រូវបានយកមកប្រកាសដែល ទោសបន្ថែមទាំងនោះរួមមាន៖

- ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥(ប្រាំ) ឆ្នាំយ៉ាងច្រើន
- ការហាមឃាតចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬនៅក្នុងឱកាសនៃការប្រកបវិជាជីវៈនោះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន
- ការហាមឃាតចំពោះការស្នាក់នៅ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន
- ការហាមឃាតដល់ទណ្ឌិតបរទេសចំពោះការចូលឬការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬសម្រាប់រយៈពេល ៥(ប្រាំ)ឆ្នាំយ៉ាងច្រើ
- ការហាមឃាត់ចំពោះការកាន់កាប់ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ)ឆ្នាំយ៉ាងច្រើន
- ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែយ៉ាងច្រើន
- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសាព័ត៌មាន
- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសតាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន។

# ជំពូកទី៣

# ប្រៀបធៀបបទល្មើស
# រំលោភសេពសន្ថវៈ និង
# បទល្មើសប្រទូស្តកេរខ្មាស

# ជំពូកទី ៣

# ប្រៀបធៀបបទល្មើសរំលោភសេពសន្ថវៈ និងបទល្មើសប្រទូស្តកេរខ្មាស

## ៣.១. លក្ខណៈដូចគ្នានៃបទល្មើសទាំងពីរ

ជាការពិតនៅក្នុងគន្ថីទី២នេះ គឺមានផ្នែកមួយនៃមាត្រាខ្លះដូចគ្នាតួយ៉ាងដូចដែរមាននៅក្នុង បទល្មើសរំលោភសេពសន្ថៈ និង បទប្រទូស្តកេរខ្មាសជាដើម។ ចំពោះនៅក្នុងចំណុចនេះយើងនឹងសិក្សាអំពីចរិតលក្ខណៈដូចគ្នានៃបទល្មើសទាំងពីរដូចខាងក្រោមៈ

### ៣.១.១.ធាតុផ្សំនីត្យានុកូល

ដូចដែរយើងបានដឹងរួចមកហើយថា ធាតុផ្សំនីត្យានុកូល គឺជាធាតុមួយដែលត្រូវបានកំណត់នៅក្នុងច្បាប់ជាធរមាន។ នៅក្នុងការកំណត់របស់ច្បាប់នេះចំពោះបទរំលោភសេពសន្ថវៈ និងបទប្រទូស្តកេរខ្មាសមានលក្ខណៈដូចគ្នា ដែលមានដូចជា ការចែងក្នុងគន្ថី ការចែងក្នុងជំពូក និងទោសបន្ថែមហើយដើម្បីឱ្យកាន់តែច្បាស់យើងនឹងធ្វើការសិក្សាទៅលើចំណុចទាំងនេះជាបន្តទៀត។

#### ៣.១.១.១.ការបែងចែកក្នុងគន្ថី

ជាការពិតក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានបែងចែកជា៦គន្ថីហើយក្នុងនោះ ផងដែរ គឺមានតែ ៣ គន្ថីតែប៉ុណ្ណោះដែលកំណត់ពីបទល្មើស។ គន្ថីនោះរួមមាន គន្ថីទី២ និយាយអំពី បទល្មើសប្រឆាំងនិងបុគ្គល គន្ថីទី៣ ជាបទល្មើសប្រឆាំងនឹងទ្រព្យសម្បត្តិ ហើយគន្ថីទី៤ និយាយអំពីបទល្មើសប្រឆាំងនឹងជាតិ។ ជាក់ស្តែងចំពោះបទល្មើសរំលោភសេពសន្ថវៈ និងបទប្រទូស្តកេរខ្មាសវិញគឺមានចែងនៅក្នុងគន្ថីទី២ដែលនិយាយអំពីបទល្មើសប្រឆាំងនឹងបុគ្គល។[61] នេះជាមូលហេតុនៃការសិក្សាមួយដែលនាំឱ្យនីតិករៀបដាក់បទល្មើសទាំងពីរនេះក្នុងគន្ថីតែមួយព្រោះបទល្មើសទាំងពីរនេះ មានជាប់ទាក់ទងនឹងការបំពានផ្លូវភេទហើយក៏បានធ្វើឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាព និងសេចក្តីថ្លៃថ្នូររបស់បុគ្គល និងបញ្ហាផ្លូវចិត្តរបស់អ្នកបុគ្គលទាំងឡាយដែលរងការប៉ះពាល់។

#### ៣.១.១.២.ការបែងចែកក្នុងជំពូក

ដើម្បីជាគន្លឹះក្នុងការស្វែងយល់ឱ្យកាន់តែច្បាស់ និងមានភាពងាយស្រួលថែមទៀតនោះ នីតិករបានរៀបចំធ្វើការតាក់តែងក្រមនេះឡើងទៅតាមបែបបទ រចនាសម្ព័ន្ធតាមលំដាប់លំដោយនៃផ្នែកនីមួយៗ។ មិនតែប៉ុណ្ណោះនៅក្នុងមាតិកាខ្លះមានជំពូកតិច ឬ ច្រើនវាអាស្រ័យទៅលើវិសាលភាពនៃជំពូកនោះ ម្យ៉ាងវិញទៀតចំពោះបទល្មើសទាំងពីរនៃប្រធានបទយើង គឺត្រូវបានចែងនៅក្នុងជំពូកដែលទាក់ទងទៅនឹងការបំពាន

[61] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ គន្ថីទី២ បទល្មើសប្រឆាំងនឹងបុគ្គល

ខាងផ្លូវភេទ ជាមួយគ្នាថែមទៀតផង ការដែលនីតិករកំណត់បែបនេះដោយហេតុថាបទល្មើសទាំងពីរ គឺជាបទល្មើសដែលបំពាន់ទៅកាន់ផ្លូវភេទរបស់បុគ្គលដ៏ទៃដូចគ្នា។

**៣.១.១.៣.ទោសបន្ថែម**

ដោយយោងទៅតាម មាត្រា៥៤ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បានបញ្ញត្តិថាទោសបន្ថែមនេះអាចប្រកាសទៅបានលុះត្រាតែ ទោសនេះត្រូវបានចែងយ៉ាងជាក់លាក់ចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម ឬបទលហុ ដែលត្រូវបានចោទប្រកាន់។ ទោសបន្ថែមអាចប្រកាសក៏បាន មិនប្រកាសក៏បាន។ ទោសត្រូវប្រកាន់ជាកាតព្វកិច្ច ប្រសិនបើច្បាប់ចែងយ៉ាងជាក់លាក់។ ដោយឡែកចំពោះបទល្មើសរំលោភសេពសន្ថវៈ និងបទល្មើសប្រទូស្តកេរខ្មាសមានការបែងចែកផងដែរអំពីទោសបន្ថែម ដែលអាចត្រូវបានប្រកាសដែលចំនួនទោសបន្ថែមនៃបទល្មើសរំលោភសេពសន្ថវៈ និងបទល្មើសប្រទូស្តកេរខ្មាសមាន ៨(ប្រាំបី) ចំណុចដូចគ្នាៈ

១.ការដកសិទ្ធិខ្លះជាពលរដ្ឋជាស្ថាពរ ឬសម្រាប់រយៈពេល៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន។

២.ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈកាសបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះជាស្ថាពរ ឬសម្រាប់រយៈពេល៥(ប្រាំ) ឆ្នាំយ៉ាងច្រើន។

៣.ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល១០ (ដប់)ឆ្នាំយ៉ាងច្រើន។ការហាមឃាត់នេះចំពោះការបើកបរយានយន្តគ្រប់ប្រភេទ ។

៤.ការហាមឃាត់ចំពោះទណ្ឌិតដែលជាជនបរទេស ចំពោះការចូល ឬការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរឬសម្រាប់រយៈពេល៥ឆ្នាំយ៉ាងច្រើន។

៥.ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទជាស្ថាពរ ឬ សម្រាប់រយៈពេល៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន។

៦. ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល២ ( ពីរ) ខែយ៉ាងច្រើន ។

៧. ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន។

៨.ការផ្សាយសេចក្តីសម្រេច ផ្តន្ទាទោសតាមគ្រប់មធ្យោបាយ ទូរគមនាគមន៍ សោតទស្សន៍ ដោយសម្រាប់រយៈពេល៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន។[62]

[62] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ មាត្រា២៤៥ និងមាត្រា២៥២

**៣.១.២.ប្រធាននៃបទល្មើស**

ជាមួយគ្នានេះផងដែរទាក់ទងទៅនឹងអំពើដែលជាបទល្មើសរំលោភសេពសន្ថវៈ និងបទប្រទូស្តកេរខ្មាស បានកំណត់ដល់ស្ថានភាពដែលប្រព្រឹត្តឡើងដោយរូបវន្តបុគ្គល ឬ នីតិបុគ្គលដែលបង្កឡើងក្នុងន័យបម្រើនូវចំណង់ផ្លូវភេទដែលជាការសប្បាយអំពើនោះត្រូវបានច្បាប់បញ្ញត្តិថាជាបទល្មើស។ ចំពោះនៅក្នុងបទល្មើសទាំងពីរប្រធាននៃបទល្មើសជនល្មើសប្រព្រឹត្តក្នុងគោលបំណងរឿងផ្លូវភេទដូចគ្នា ហើយជនរងគ្រោះទទួលរងព្យសនកម្មផ្លូវភេទដូចគ្នាផងដែរ។ ដូច្នេះមិនថាការប្រព្រឹត្តនោះជាក្រុម ឬយ៉ាងណាសុទ្ធតែជាប្រធាននៃបទល្មើស។

**៣.១.២.១.ជនរងគ្រោះ**

ចំពោះស្ថានភាពរបស់ជនរងគ្រោះក្នុងបទល្មើសទាំងពីរនេះ គឺជនរងគ្រោះបានទទួលរងនូវផលប៉ះពាល់ផ្លូវចិត្តពីការរំលោភបំពាន និងរងនៅការបំពានផ្លូវភេទដូចគ្នាទោះបីជាអំពើប្រទូស្តកេរខ្មាសមិនស្ថិតក្នុងស្ថានភាពដែលស៊ីជម្រៅខ្លាំងដូចនិងបទរំលោភសេពសន្ថវៈក៏ដោយ។ តែការបំពានផ្លូវភេទនេះគឺមានផលប៉ះពាល់ខ្លាំងដែលនាំឱ្យជនរងគ្រោះបាត់បង់នូវភាពបរិសុទ្ធ និងសេចក្តីថ្លៃថ្នូរ។

**៣.១.២.២.ជនល្មើស**

នៅក្នុងស្ថានភាពនៃសកម្មភាពរបស់ជនល្មើស ក៏មានចេតនាទុច្ចរិតដែលបានបង្ហាញឱ្យឃើញពីតម្រូវការរបស់ខ្លួនមិនថាការប្រព្រឹត្តនោះជាការគំរាមពីសំណាក់ក្រុមមនុស្សមួយចំនួន ឬក៏យ៉ាងណានោះទេវាជាការបម្រើដល់ចំណង់របស់ខ្លួនដែលជាចេតនាដោយមិនមានការយល់ព្រមពីភាគីម្ខាងទៀតក៏ដោយ។ មែនទែនទៅជនល្មើស គឺមានចេតនាក្នុងការធ្វើអំពើមួយនេះដោយដឹងហើយថាអ្វីគាត់កំពុងប្រព្រឹត្តនេះជាអំពើខុស ដែលនេះវាមិនមែនជាកំហុសដោយចៃដន្យ ឬដោយប្រធានសិក្កិណាមួយនោះឡើង។

**៣.១.៣.ព្យសនកម្ម**

ប្រសិនយើងសង្កេតទៅលើធាតុផ្សំនៃបទល្មើសព្យសនកម្មនេះបានកើតឡើង នៅពេលដែលអំពើមួយបាននាំឱ្យមានការប៉ះពាល់ ឬ បំពានទៅលើផ្លូវភេទដែលគ្មានការព្រមព្រៀងពីជនរងគ្រោះដែលធ្វើឱ្យបាត់បង់នូវសិទ្ធិសេរីភាពរបស់ជនរងគ្រោះ និងមានផលប៉ះពាល់ធ្ងន់ធ្ងរទាំងផ្លូវចិត្តសតិអារម្មណ៍ដោយមធ្យោបាយឬដោយឧបាយកលទុច្ចរិតណាមួយរបស់ជនល្មើស។

**៣.២.លក្ខណៈខុសគ្នានៃបទល្មើសទាំងពីរ**

ជាការពិតណាស់នៅក្នុងបទល្មើសនីមួយៗ ត្បិតថាមានចំណុចមួយចំនួនមាននូវលក្ខណៈដូចគ្នាក៏ពិតមែន ក៏ប៉ុន្តែចំពោះនៅក្នុងបទល្មើសតែងតែមានបង្កប់នូវមានលក្ខណៈមួយចំនួនផ្សេងទៀត ដែលមាន

នូវលក្ខណៈខុសពីគ្នា ជាក់ស្តែងដូចជាចំណាត់ថ្នាក់នៃបទល្មើសស្ថានភានៅក្នុងបទល្មើស និងលើពីនេះទៅទៀត នោះថ្វីត្បិតថានៅគ្រប់បទល្មើសទាំងអស់យើងសង្កេតឃើញថាមាននូវនៅធាតុផ្សំសំខាន់ៗ ៣(បី) ដូចគ្នាក៏ពិតមែនក៏ប៉ុន្តែនៅក្នុងធាតុផ្សំនីមួយៗ មិនមានលក្ខណៈដូចគ្នាទាំងអស់នោះឡើយពោលគឺ នៅមានលក្ខណៈជាច្រើនមួយចំនួនទៀតដែលបានបង្ហាញពីស្ថានភាពដែលមានលក្ខណៈខុសប្លែកពីគ្នាផងដែរ ចំពោះលក្ខណៈដែកខុសប្លែកពីគ្នានោះយើងអាចសង្កេតឃើញរួមមាន ធាតុផ្សំនីមួយៗ ដែលទាក់ទងទៅនឹងលក្ខណៈនៃនិយមន័យការចែងនៅក្នុងច្បាប់ និងរូបភាពនៃអំពើដែលជនល្មើសបានប្រព្រឹត្តនៅក្នុងបទល្មើសរៀងៗខ្លួនដែលមានលក្ខណៈផ្សេងទៀតខុសពីគ្នា។ ខាងក្រោមនេះយើងខ្ញុំនឹងធ្វើការបកស្រាយអំពីលក្ខណៈខុសប្លែកពីគ្នារវាងបទរំលោភសេពសន្ថវៈ និងបទប្រទូស្តកេរខ្មាសដើម្បីជាពុទ្ធិបន្ថែមក្នុងការយល់កាន់តែស៊ីជម្រៅ។

### ៣.២.១.ធាតុនីត្យានុកូលនៃបទល្មើស

#### ៣.២.១.១.និយមន័យនៃបទល្មើសទាំងពីរ

នៅក្នុងក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាយើងនៅគ្រប់រាល់បទល្មើសទាំងអស់នីតិករតែងតែធ្វើការកំណត់នូវនិយមន័យនៃបទល្មើសទាំងនោះយ៉ាងក្បោះក្បាយ និងមានភាពលម្អិតថែមទៀតចំពោះខ្លឹមសារដែលចែងនោះ កាលដែលនីតិករធ្វើការកំណត់ពីនិយមន័យយ៉ាងច្បាស់លាប់បែបនេះ គឺក្នុងគោលបំណង់ចង់បង្ហាញពីស្ថានភាពនៅក្នុងអំពើនៃបទល្មើសទាំងនោះឱ្យកាន់តែច្បាស់។ បើយើងក្រឡេចមកមើលបទល្មើសទាំងពីរនៃប្រធានបទយើងវិញ ក្រមព្រហ្មទណ្ឌក៏បានកំណត់ពីនិយមន័យនៃបទល្មើសទាំងពីរនេះបានយ៉ាងក្បោះក្បាយថា៖

**បទល្មើសរំលោភសេពសន្ថវ:** បានឱ្យនិយមន័យថាគ្រប់អំពើបញ្ចូលអង្គជាតិតាមបែបណាក៏ដោយ ឬការបញ្ចូលឧបករណ៍ណាមួយទៅក្នុងអង្គជាតិដែលប្រព្រឹត្តទៅលើអ្នកដទៃទោះបីភេទដូចគ្នា ឬមិនដូចគ្នាក៏ដោយ ដោយការប្រើហិង្សា ការបង្ខិតបង្ខំ ការគំរាមគំហែង ឬដោយការឆ្មក់ឱកាស។[63]

**បទល្មើសប្រទូស្តកេរខ្មាស** បានឱ្យនិយមន័យថាគ្រប់អំពើប៉ះពាល់ ស្ទាប់ អង្អែលកេរភេទ ឬផ្នែកភេទផ្សេងទៀតរបស់បុគ្គលដទៃ តែបុគ្គលនេះមិនស្ម័គ្រផងទេ ឬបង្ខំបុគ្គលដទៃអោយប្រព្រឹត្តិអំពើនេះមកលើខ្លួន ឬទៅលើតតិយបុគ្គលក្នុងគោលបំណងរំជួល ឬរីករាយដល់ចំណង់ផ្លូវភេទរបស់ជនល្មើស។[64]

---

[63] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ មាត្រា២៣៩ កថាខណ្ឌទី១

[64] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ មាត្រា២៣៩ កថាខណ្ឌទី២

តាមរយៈនិយមន័យ នៃបទល្មើសទាំងពីរខាងលើយើងឃើញថាមាននីតិករបានធ្វើការចែងកំណត់អំពីស្ថានភាពផ្សេងៗ ដែលអាចនឹងកើតមាននៅក្នុងបទល្មើសទាំងពីរនេះដែលធ្វើឱ្យយើងយល់កាន់តែច្បាស់អំពីស្ថានភាពជាក់ស្តែងដែលកើតមាន ពោលគឺបទល្មើសទាំងពីរនេះមាននូវនិយមន័យដែលបានបង្ហាញពីស្ថានភាពពីរផ្សេងដាច់ពីគ្នាផងដែរ។

**៣.២.១.២.ការផ្តន្ទាទោស**

ជាការពិតណាស់ នៅគ្រប់បទល្មើសទាំងអស់ដែលបានកំណត់នៅក្នុងក្រមព្រហ្មទណ្ឌ គឺសុទ្ធសឹងតែបានកំណត់អំពីមូលទោសនៃបទល្មើសនីមួយៗ នោះដោយមូលទោសទាំងនេះមានដូចជាទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ ជាក់ស្តែងនៅក្នុងបទល្មើសទាំងពីរនៃប្រធានបទយើង ក៏មានបង្ហាញអំពីមូលទោសនៅក្នុងនោះផងដែរ ហើយថាតើមូលទោសដែលមាននោះមានលក្ខណៈបែបណាយើងនឹងធ្វើការបកស្រាយជាបន្តទៅនេះ។

**បទល្មើសរំលោភសេពសន្ថវៈ** នៅក្នុងបទល្មើសនេះចំពោះការផ្តន្ទាទោសដាក់ពន្ធនាគារ គឺត្រូវបានច្បាប់កំណត់ចាប់ពី៥ (ប្រាំ)ឆ្នាំ ទៅ១០ (ដប់)ឆ្នាំដោយនៅក្នុងបទល្មើសនេះចំពោះមូលទោសមិនមានការពិន័យជាប្រាក់នេះទេដោយយោងតាមមាត្រា២៣៩កថាខណ្ឌទី២។

**បទល្មើសប្រទូស្តកេរខ្មាស** នៅក្នុងបទល្មើសនោះមូលទោសរួមមានការផ្តន្ទាទោសទោសដាក់ពន្ធនាគាពីរ១(មួយ)ឆ្នាំ ទៅ ៣ (បី)ឆ្នាំនិងចំពោះការពិន័យជាប្រាប់វិញគឺចាប់ពី២.០០០.០០០(ពីរលាន)រៀលទៅ៦.០០០.០០០(ប្រាំមួយលាន) រៀលដោយយោងតាមមាត្រា២៤៦ កថាខណ្ឌទី២។

សរុបជារួមមកការផ្តន្ទាទោសចំពោះបទល្មើសទាំងពីរនេះ គឺមានលក្ខណៈខុសដាច់ពីគ្នាដោយនៅក្នុងបទល្មើសរំលោភសេពសន្ថវៈ មានការផ្តន្ទាទោសធ្ងន់ធ្ងរជាងដោយត្រូវច្បាប់កំណត់ពីការផ្តន្ទាទោសរហូតដល់១០ឆ្នាំ រីឯចំពោះបទប្រទូស្តកេរខ្មាសវិញត្រូវបានច្បាប់កំណត់ពីការផ្តន្ទាទោស ៣ឆ្នាំ ប៉ុណ្ណោះដែលវាមានលក្ខណៈស្រាលជាង បទរំលោភសេពសន្ថវៈ ក៏ប៉ុន្តែនៅក្នុងបទល្មើសប្រទូស្តកេរខ្មាសមានកំណត់ពីការពិន័យជាប្រាក់បន្ថែមពីលើនៃទោសដាក់ពន្ធនាគារដែលរៀងខុសប្លែកពីបទរំលោភសេពសន្ថវៈបន្តិច។

**៣.២.១.៣.ស្ថានទម្ងន់ទោសនៃបទល្មើសទាំងពីរ**

ជាការពិតណាស់ នៅក្នុងបទល្មើសនីមួយៗនីតិករបានកំណត់អំពីស្ថានភាព នៃការប្រព្រឹត្តបទល្មើសទាំងឡាយដើម្បីយកស្ថានភាពទាំងនោះយកមកសិក្សាទៅលើការផ្តន្ទាទោសហើយថា តើអំពើទាំងនោះបានចូលទៅក្នុងលក្ខខណ្ឌដែលជាស្ថានទម្ងន់ទោសឬទេ។ ពោលគឺ រាល់អំពើទាំងឡាយណាដែល

បានប្រព្រឹត្តនោះមាននូវការបង្ករព្យាសនកម្មផ្សេងគ្នាទៅតាមបទល្មើសនីមួយៗ ដោយបទល្មើសខ្លះបង្កនូវព្យសនកម្មតិចតួច ហើយមានខ្លះទៀតបានបង្ករនូវព្យាសនកម្មយ៉ាងធ្ងន់ធ្ងរព្រមទាំងមានលក្ខណៈឃោរឃៅព្រៃផ្សៃជាដើម។ ហេតុដូច្នេះហើយទើបការដែលច្បាប់កំណត់ពីការផ្តន្ទាទោស និងស្ថានទម្ងន់ទោសនៅក្នុងបទល្មើសនីមួយខុសៗ ពីគ្នាទៅតាមទំហំដែលបទល្មើសនោះបានបង្កព្យសនកម្ម។ មួយវិញទៀតមានតែស្ថានទម្ងន់ទោសដែលច្បាប់បានកំណត់យ៉ាងច្បាស់លាស់នៅក្នុង បទល្មើសនោះទើបអាចធ្វើការប្រកាសទោសនោះបាន។

ជាក់ស្តែងនៅក្នុងបទល្មើសរំលោភសេពសន្ថវៈ និងបទល្មើសប្រទូស្តកេរខ្មាសនៃប្រធានបទរបស់យើងត្រូវបានក្រមព្រហ្មទណ្ឌកំណត់ពីស្ថានភាពខុសៗ គ្នារវាងបទល្មើសទាំងពីរនោះផងដែរដើម្បីកំណត់ឱ្យកាន់តែច្បាស់ចំពោះអំពើទាំងឡាយណា ដែលត្រូវបានចាត់ទុកថាជាការប្រព្រឹត្តដែលស្ថិតនៅក្នុងស្ថានភាពដែលជាស្ថានទម្ងន់ទោសដែលច្បាប់បានកំណត់នៅក្នុងក្រមព្រហ្មទណ្ឌនៃបទល្មើសទាំងពីរនេះ។

**បទល្មើសរំលោភសេពសន្ថវៈ** ទាក់ទងទៅនឹងស្ថានទម្ងន់ទោសដែលច្បាប់បានកំណត់ទុកនៅក្នុងបទរំលោភសេពសន្ថវៈនេះយើងសង្កេតឃើញថា ច្បាប់បានកំណត់ពីស្ថានភាពជាច្រើនដែលត្រូវបានចាប់ទុកថាស្ថិតក្នុងលក្ខខណ្ឌដែលជាស្ថានទម្ងន់ទោស។ ពោលគឺនៅក្នុងក្រមព្រហ្មទណ្ឌត្រង់ចំណុចដែលនីតិករបានកំណត់អំពីស្ថានទម្ងន់ទោសនៃបទរំលោភសេពសន្ថវនោះមានចាប់ពី មាត្រា២៤០ រហូតដល់មាត្រា២៤៤។ នៅក្នុងបទល្មើសនេះចំពោះស្ថានទម្ងន់ទោសទាក់ទងនឹងជនល្មើសយើងឃើញថា ត្រូវបានកំណត់តែមួយមាត្រាប៉ុណ្ណោះត្រង់ មាត្រា២៤០ ក៏ប៉ុន្តែស្ថានទម្ងន់ទោសដែលទាក់ទងនឹងជនរងគ្រោះវិញឃើញថានីតិរបានកំណត់អំពីស្ថានភាពមួយចំនួនដែលជាលក្ខខណ្ឌ ដែលត្រូវបានចាត់ទុកថាសស្ថិតក្នុងស្ថានទម្ងន់ទោសរហូតដល់ទៅបួនមាត្រាដែរទាក់ទងទៅនឹងការកាត់អវយវៈ ឬពិការភាព[65] ការធ្វើទារុណកម្ម ឬអំពើឃោរឃៅ[66] និងទាក់ទងទៅនឹងមរណៈភាពនៃជនរងគ្រោះ ថែមទៀត[67]។

**បទល្មើសប្រទូស្តកេរខ្មាស** ចំពោះស្ថានទម្ងន់ទោសដែលនៅក្នុងបទល្មើសប្រទូស្តកេរខ្មាសនេះឃើញថាមានស្ថានភាពមួយចំនួនដែលជាលក្ខខណ្ឌ នៃស្ថានទម្ងន់ទោសដែលស្ថិតនៅក្នុងបទល្មើសនេះដែលបានកំណត់នៅក្រមព្រហ្មទណ្ឌមានតែពីរមាត្រាប៉ុណ្ណោះ ដែលមានស្ថានទម្ងន់ទោសដែលទាក់ទងនឹង

[65] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ មាត្រា២៤២

[66] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ មាត្រា២៤៣

[67] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ មាត្រា២៤៤

ការប្រើប្រាស ឬទាក់ទងនឹងចារីត្រង់ មាត្រា២៤៧ និងស្ថានទម្ងន់ទោសដែលទាក់ទងនឹងជនរងគ្រោះត្រង់ មាត្រា២៤៨ នៃក្រមព្រហ្មទណ្ឌ។

សរុបជារួមមក ស្ថានទម្ងន់ទោសដែលមាននៅក្នុងបទល្មើសទាំងពីនេះ គឺមានលក្ខណៈប្រហាក់ប្រហែលគ្នាក៏ពិតមែន ប៉ុន្តែមិនមែនមានន័យថាដូចគ្នានោះទេ។ នៅក្នុងស្ថានទម្ងន់ទោសនៃបទល្មើសទាំងពីរនេះ យើងឃើញថាបទរំលោភសេពសន្ថវៈបានចែងពីស្ថានភាព នៃស្ថានទម្ងន់ទោសច្រើនចំណុច និងបានរៀបរាប់ពីស្ថានភាពយ៉ាច្បាស់លាស់ដែលអាចបង្ហាញឱ្យយើងយល់កាន់តែច្បាប់ថែមទៀត ទៅកាន់ស្ថានជាក់ស្តែងនៅក្នុងបទល្មើសនេះ។ កាលដែលនីតិករធ្វើការកំណត់ និងរៀបរាប់លម្អិតបែបនេះដោយសារតែបទរំលោភសេពសន្ថវៈនេះ ជាបទល្មើសមួយដែលបង្ករនូវព្យសនកម្មធន់ធ្ងរយ៉ាងខ្លាំងទៅលើជនរងគ្រោះដែលធ្វើឱ្យជនដែលទទួលរងនូវព្យសនកម្មនោះទទួលនូវភាពអាម៉ាស់ចំពោះខ្លួនឯងដែលត្រូវបុគ្គលដទៃបំពានមកកាន់ខ្លួនបែបនោះ បន្ថែមពីលើនេះទៅទៀត ក៏បានធ្វើឱ្យគ្រួសាររបស់ជនរងគ្រោះបាត់បង់នូវកិត្តិយសថែមទៀតផង ជាពិសេសជាងនេះទៅទៀតនោះ អំពើទាំងនោះក៏បានធ្វើឱ្យប៉ះពាល់ទៅដល់សណ្តាប់ធ្នាប់សាធារណៈព្រមទាំងសីលធម៌សង្គមផងដែរ។ ក៏ប៉ុន្តែបើក្រឡេកមកមើលបទប្រទូស្តកេរខ្មាសវិញឃើញថា គឺមាននូវស្ថានទម្ងន់ទោសដែលទាក់ទងទៅនឹងចារី និងទាក់ទងទៅនឹងជនរងគ្រោះដូចគ្នាពិតមែន ប៉ុន្តែស្ថានទម្ងន់ទោសដែលបានកំណត់នៅក្នុងបទប្រទូស្តកេរខ្មាសនេះ ចំពោះស្ថានភាពដែលទាក់ទងទៅនឹងជនរងគ្រោះនៅក្នុងបទប្រទូស្តកេរខ្មាសនេះ នីតិករមិនបានរៀបរាប់ច្រើនពីស្ថានភាពដែលជាស្ថានទម្ងន់ទោសនៅក្នុងនេះឡើយដោយនីតិរបានរៀបរាប់តែចំណុចមួយចំនួនដែលជាចំណុចសំខាន់ៗដែលតែងតែកើតមានឡើង និងមានការប៉ះពាល់ច្រើនប៉ុណ្ណោះ។ នៅក្នុងបទប្រទូស្តកេរខ្មាសនោះក៏បានបង្កនូវព្យសនកម្មទៅលើជនរងគ្រោះ និងសីលធម៌សង្គមផងដែរក៏ប៉ុន្តែបើធៀបទៅ និងបទរំលោភសេពសន្ថវៈវិញគឺមានការបង្កនូវព្យសនកម្មស្រាល់ជាងបន្តិច តែទោះយ៉ាងណាក្តីក៏បទល្មើសនេះនៅតែធ្វើឱ្យមាននូវ ព្យសនកម្មដដែល។

### ៣.២.២.ធាតុសត្យានុម័តនៃបទល្មើសទាំងពីរ

#### ៣.២.២.១.រូបភាពនៃអំពើ

ជាការពិតណាស់នៅក្នុងបទល្មើសនីមួយៗតែងតែមាននូវស្ថានភាព និងរូបភាពនៃអំពើដែលចារីប្រព្រឹត្តចេញមកខុសៗគ្នាទៅតាមស្ថានភាពនៃបទល្មើសនីមួយៗ។ មិនតែប៉ុណ្ណោះនោះទេរូបភាពនៃអំពើទាំងនោះនឹងបង្ហាញពីស្ថានភាពជាក់ស្តែងនូវទំហំនៃព្យសនកម្ម ដែលបានបង្កឡើងដោយអំពើរបស់ចារីបានប្រព្រឹត្តនោះ។ រាល់សកម្មភាពនៃអំពើដែលបានបញ្ចេញមកខាងក្រៅទាំងនេះនឹងបង្ហាញឱ្យយើងឃើញ

ច្បាស់ពីទង្វើ នៃការប្រព្រឹត្តរបស់ចារីយ៉ាងច្បាស់ហើយថា តើសកម្មភាពនៃអំពើរបស់ចារីបានប្រព្រឹត្តនៅក្នុងបទល្មើសទាំងពីរនោះមានរូបភាពបែបណាខ្លះនោះនិងមានលក្ខណៈខុសគ្នាបែបណាខ្លះខាងក្រោមនេះយើងនឹងធ្វើការបកស្រាយលម្អិតបន្ថែមទៀត។

**បទល្មើសរំលោភសេពសន្ថវៈ** នៅក្នុងបទល្មើសនេះអំពើដែលចារីបានប្រព្រឹត្តនេះ គឺជាអំពើសកម្មដែលមានបង្ហាញនៅក្នុងបញ្ញត្តិ មាត្រា២៣៩។ ពោលគឺនៅក្នុងបញ្ញត្តិមាត្រានេះបានបង្ហាញពីសកម្មភាពនៃអំពើមួយចំនួនដែលចារីបានប្រព្រឹត្តនៅក្នុងសកម្មភាពនោះបានបង្ហាញឡើងនៅក្នុងទម្រង់នៃរូបភាពចំនួន ៣ (បី)ដែលរួមមាន៖

- រូបភាពទី១ ការប្រើហិង្សា៖ ដោយចារីបានប្រព្រឹត្តអំពើបញ្ចូលអង្គជាតឬបញ្ចូលឧបករណ៍ណាមួយដោយការប្រើប្រាស់នូវអំពើហិង្សា គឺជាការប្រើហិង្សាផ្នែករូបរាងកាយទៅលើជនរងគ្រោះដូចជាការប្រតាយប្រតប់ទះកំផ្លៀងទាត់ធាក់ជាដើម។
- រូបភាពទី២ ការបង្ខិតបង្ខំឬគំរាមកំហែង៖ ចារីបញ្ចូលអង្គជាតឬបញ្ចូលឧបករណ៍ណាមួយដោយបង្ខិតបង្ខំ ឬការគំរាមកំហែងអាចជាការគំរាមកំហែងផ្នែកផ្លូវចិត្ត ឬការគំរាមកំហែងផ្នែកផ្លូវកាយជាដើម។
- រូបភាពទី៣ ដោយឆ្មក់ឱកាស៖ គឺចារីបញ្ចូលអង្គជាតឬបញ្ចូលឧបករណ៍ណាមួយដោយមានការឆ្មក់ឱកាសពោលគឺចារីបានប្រព្រឹត្តឡើងដោយមិនឱ្យជនរងគ្រោះបានដឹងខ្លួននោះឡើយ ដូចជាពេលកំពុងគេងលក់ស្រវឹងស្រាជាដើម...។

**បទប្រទូស្តកេរខ្មាស** ចំពោះបទល្មើសនេះវិញសកម្មភាពដែលជាអំពើរបស់ចារីបានប្រព្រឹត្តឡើងដែលបានបង្ហាញមកខាងក្រៅដែលយើងអាចសម្គាល់ឃើញយ៉ាងច្បាស់ទៅលើអំពើទាំនោះបានដោយស្ថិតក្នុង៣(បី) រូបភាពរួមមាន៖

- រូបភាពទី១៖ ជនល្មើសប៉ះពាល់ ស្ទាប់អង្អែលកេរភេទ ឬផ្នែកភេទផ្សេងទៀតរបស់ជនរងគ្រោះពោលគឺជនល្មើសបានធ្វើការប៉ះពាល់ ស្ទាប់ អង្អែល ទៅកាន់កេរភេទរបស់ជនរងគ្រោះ ឬទៅកាន់ផ្សេងទៀតនៅលើរាងកាយរបស់ជនរងគ្រោះទាំងដែលជនរងគ្រោះនោះបានមិនស្ម័គ្រចិត្តនោះទេ។
- រូបភាពទី២៖ ជនល្មើសបង្ខំអោយជនរងគ្រោះប៉ាពាល់ ស្ទាប់អង្អែលកេរភេទឬ ផ្នែកភេទផ្សេងទៀតមកកាន់ខ្លួនក្នុងគោលបំណង់ឱ្យមានការរំជួលអារម្មណ៍។

- រូបភាពទី៣៖ ជនល្មើសបានបង្ខំឱ្យជនរងគ្រោះប្រព្រឹត្តអំពើប៉ះពាល់ ស្ទាប អង្អែលកេរភេទ ឬផ្នែកភេទផ្សេងទៀតរបស់តតិយជន។

សរុបជារួម ចំពោះរូបភាព នៃអំពើដែលជនល្មើសប្រព្រឹត្តនៅក្នុងបទរំលោភសេពសន្ថវៈ និងបទប្រមាថកេរខ្មាសដោយឃើញថារវាងបទល្មើសទាំងពីរនេះមានចំណុចមួយចំនួន គឺមានលក្ខណៈប្រហាក់ប្រហែលគ្នាខ្លះក៏ពិតមែន ក៏ប៉ុន្តែមិនមែនប្រហាក់ប្រហែលគ្នាទាំងស្រុងនោះឡើយពោល គឺនៅក្នុងបទរំលោភសេពសន្ថវៈឃើញថាមានបង្ហាញពីសកម្មភាពដូចជាការប្រើអំពើហិង្សា និងការបង្ខិតបង្ខំ ឬ គំរាមគំហែងដែលបានបង្ហាញពីភាពឃោរឃៅ ដែលជនល្មើសប្រព្រឹត្តនូវសកម្មភាពទាំងនេះលើសពីនេះទៅទៀតនៅក្នុងបទរំលោភសេពសន្ថវៈ ក៏មាននូវសកម្មភាពនៃការឆ្មក់ឱកាសដើម្បីប្រព្រឹត្តអំពើរបស់ខ្លួនផងដែរ។ បើយើងក្រឡេកមកមើលនៅក្នុងបទប្រមាថកេរខ្មាសវិញយើងឃើញថារូបភាពនៃអំពើដែលមាននៅក្នុងបទល្មើសនេះ មានចំណុចមួយចំនួនប្រហាក់ប្រហែលគ្នាទៅនឹងរូបភាពនៃការបង្ខិបង្ខំតែប៉ុណ្ណោះ ដោយនៅក្នុងបទល្មើសនេះមិនមានបង្ហាញពីការប្រើហិង្សា និងការឆ្មក់ឱកាសណាមួយដើម្បីសម្រេចនូវ លទ្ធផលនៃអំពើរបស់ខ្លួនដូចទៅនឹងបទរំលោភសេពសន្ថវៈនោះទេ។

### ៣.២.៣.ធាតុអត្តនោម័តនៃបទល្មើសទាំងពីរ

#### ៣.២.៣.១.ចេតនាក្នុងការប្រព្រឹត្ត

ជាការពិតណាស់ នៅក្នុងបទល្មើសនានាតែងតែមានបង្កប់នូវសភាពផ្លូវចិត្ត នៃចេតនារបស់ចារី ហើយត្រូវបង្ហាញចេញតាមរយៈអំពើដែលចារីប្រព្រឹត្តមកខាងក្រៅ។ ពោលគឺនៅខាងក្នុងផ្លូវចិត្តរបស់ចារីដែលមាននូវចេតនានៃការប្រព្រឹត្តទៅតាមបទល្មើសនីមួយៗ ហើយចេតនានៃកាប្រព្រឹត្តរបស់ចារីធ្វើឡើងគឺដើម្បីឱ្យបានសម្រេចនូវគោលបំណងរបស់ខ្លួនដែលចង់បាន។ ជាក់ស្តែងនៅក្នុងបទល្មើសរំលោភសេពសន្ថវៈ និងបទល្មើសប្រមាថកេរខ្មាស ក៏មានបង្ហាញពីចេតនាក្នុងការប្រព្រឹត្តរបស់ចារីក្នុងបទល្មើសទាំងពីរនេះផងដែរ។ តើចេតនាក្នុងការប្រព្រឹត្តរបស់ចារីនៅក្នុងបទល្មើសទាំងពីរមាននូវស្ថានភាពបែបណា និងមានលក្ខណៈខុសគ្នាបែបណាខ្លះខាងក្រោមនេះយើងខ្ញុំនិងធ្វើការបកស្រាយយ៉ាងលម្អិតបន្ថែមទៀត។

**បទល្មើសរំលោភសេពសន្ថវៈ** ចំពោះចេតនានៅក្នុងការប្រព្រឹត្តរបស់ចារីនៅក្នុងបទល្មើនេះ គឺចារីមានចេតនាឬឆន្ទៈរបស់ខ្លួនក្នុងការបញ្ចូលអង្គជាត ឬ ឧបករណ៍ផ្សេងៗទៅដល់ក្នុងទីជម្រៅនៃអង្គជាតិរបស់ជនរងគ្រោះ ទោះបីជាបានដឹងយ៉ាងប្រាកដក្នុងចិត្តហើយថាជនរងគ្រោះពុំព្រមព្រៀងស្ម័គ្រចិត្ត ក្នុងការរួមសេវារកិច្ចជាមួយខ្លួនយ៉ាងណាក្តីក៏ចារីនៅតែចង់សម្រេចនូវអំពើរបស់ខ្លួនដដែល ការដែលចារីមានឆន្ទៈក្នុងការប្រព្រឹត្ត គឺក្នុងគោលបំណង់ដើម្បីសម្រេចបាននូវចំណង់ខាងផ្លូវភេទរបស់ខ្លួន។

**បទប្រទូស្តកេរខ្មាស** ចេតនាក្នុងការប្រព្រឹត្តរបស់ចារីនោះ គឺគ្រាន់តែចង់ប៉ះពាល់ស្ទាបអង្អែលទៅលើកេរភេទរបស់ជនរងគ្រោះ ឬ ទៅកាន់ផ្នែកភេទផ្សេងទៀតនៃជនរងគ្រោះឬតតិយជនផ្សេងទៀតប៉ុណ្ណោះ ក៏ប៉ុន្តែចារីមិនមាននូវចេតនាដែលធ្វើសកម្មភាពណាដល់ទីជម្រៅនេះទេ មានន័យថាចារីមិនបានបញ្ចូលអង្គជាតរបស់ខ្លួនទៅកាន់ជនរងគ្រោះឡើយ។ គោលបំណង់របស់ចារីប្រព្រឹត្តឡើងនូវអំពើនេះគឺដើម្បីធ្វើឱ្យមានការរីករាយអារម្មណ៍ខាងផ្លូវភេទខ្លួនឯងផ្ទាល់។

ហេតុដូច្នេះនិយាយជារួមមក ចេតនានៃការប្រព្រឹត្តរបស់ចារីនៅក្នុងបទល្មើសទាំងពីរនេះមាននូវលក្ខណៈខុសប្លែកពីរគ្នាផងដែលដោយចេតនារបស់ចារីនៅក្នុងបទរំលោភសេពសន្ថវៈ គឺចារីមានចេតនាចង់បញ្ចូលអង្គជាតរបស់ខ្លួន ឬឧបករណ៍ផ្សេងទៀតទៅកាន់អង្គជាតជនរងគ្រោះ ឬ ផ្នែកផ្សេងទៀតនៃជនរងគ្រោះចំណែកនៅក្នុងបទប្រទូស្តកេរខ្មាសវិញចេតនារបស់ចារី គឺគ្រាន់តែធ្វើការប៉ះពាល់ស្ទាបអង្អែលទៅលើជនរងគ្រោះតែប៉ុណ្ណោះហើយមិនតែប៉ុណ្ណោះចារី ក៏អាចមានចេតនាបង្ខំឱ្យជនរងគ្រោះប្រព្រឹត្តអំពើទាំងនោះមកកាន់ខ្លួនឬទៅលើតតិយជនផ្សេងថែមទៀតផង ក៏ប៉ុន្តែរាល់ចេតនាទាំងអស់របស់ចារីនៅក្នុងបទប្រទូស្តកេរខ្មាសនេះគ្រាន់តែធ្វើការប៉ះពាល់ស្ទាបអង្អែលទៅកាន់កេរភេទប៉ុណ្ណោះ ដោយមិនបានដល់ទីជម្រៅនោះទេ មានន័យថាមិនបានបញ្ចូលនូវ អង្គជាតរបស់ខ្លួននោះឡើង ដែលខុសពីបទរំលោភសេពសន្ថវៈដែលមានចេតនាបញ្ចូលអង្គជាតទៅកាន់ជនរងគ្រោះ។

### ៣.២.៤.ចំណាត់ថ្នាក់នៃបទល្មើសទាំងពីរ

នៅក្នុងបទល្មើសនីមួយៗ ត្រូវបានគេកំណត់ពីចំណាត់ថ្នាក់នៃបទល្មើសទាំងនោះដោយផ្អែកទៅតាមទម្ងន់ទោសនៃបទល្មើសទាំងនោះដោយយោងតាម មាត្រា២ វាក្យខណ្ឌទី២នៃក្រមព្រហ្មទណ្ឌបានបញ្ញត្តថា បទល្មើសត្រូវបានចាត់ថ្នាក់ជាបទឧក្រិដ្ឋ បទមជ្ឈិមនិងបទលហុទៅតាមនៃបទលល្មើសនោះ។ គួរកត់សម្គាល់ផងដែរថាក្រមព្រហ្មទណ្ឌបានកំណត់យកអតិបរមា នៃទោសដែលច្បាប់តម្រូវឱ្យផ្តន្ទាទោសមកធ្វើជាមូលដ្ឋាននៃការវិនិច្ឆ័យ។

ហេតុដូចនេះហើយចំណាត់ថ្នាក់ទាំង ៣ (បី) នៃបទល្មើសត្រូវបានគេកំណត់ដូចតទៅៈ

**ក.ចំពោះទោសបទឧក្រិដ្ឋនៅករណីដែលអតិបរិមានៃទោសដាក់ពន្ធនាគារដែលត្រូវ**

– ជាប់ទោសដាក់ពន្ធនាគារអស់មួយជីវិត។

– ជាប់ទោសដាក់ពន្ធនាគារមានរយៈពេលលើសពី ៥(ប្រាំ)ឆ្នាំ និង ក្រោមឬស្មើនឹង ៣០(សាមសិប) ឆ្នាំ។[68]

**ខ.ចំពោះបទមជ្ឈិម នៅករណីដែលអតិបរិមានៃទោសដាក់ពន្ធនាគារដែលត្រូវ**

– អតិបរិមានៃទោសមានរយៈពេលលើសពី ៦(ប្រាំមួយ)ថ្ងៃ និងក្រោមឬស្មើនឹង៥ (ប្រាំ)ឆ្នាំ។[69]

**គ.ចំពោះបទលហុ នៅករណីដែលអតិបរិមានៃទោសដាក់ពន្ធនាគារដែលត្រូវ**

– អតិបរិមានៃទោសមានរយៈពេលក្រោម ឬស្មើនឹង ៦(ប្រាំមួយ)ថ្ងៃ។[70]

បន្ទាប់ពីបានយល់ពីខ្លឹមសារនៃការកំណត់ចំណាត់ថ្នាក់បទល្មើសរួចរាល់ហើយ ខាងក្រោមនេះយើងខ្ញុំនឹងធ្វើការបកស្រាយពីចំណាត់នៃបទល្មើសរំលោភសេពសន្ថវៈ និងបទប្រទូស្តកេរខ្មាសដើម្បីឱ្យយល់កាន់តែច្បាស់បន្ថែមទៀតអំពីភាពខុសផ្លែកគ្នារវាងបទល្មើសទាំងពីរនេះ។

**៣.២.៤.១.ចំណាត់ថ្នាក់បទល្មើសនៃបទរំលោភសេពសន្ថវៈ**:

ដូចដែលបានរៀបរាប់ខាងលើរួមហើយ ថាដើម្បីកំណត់ថ្នាក់នៃបទល្មើសមួយថាស្ថិតនៅក្នុងចំណាត់ថ្នាក់ណានោះ គឺផ្អែកទៅតាមអតិបរមានៃទោសដែលត្រូវផ្តន្ទាទោសនៅក្នុងបទល្មើសនោះចំពោះបទរំលោភសេពសន្ថវៈត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីរ ៥(ប្រាំ)ឆ្នាំ រហូតទៅ១០(ដប់)ឆ្នាំ នោះបើយោងតាមមាត្រា២៣៩ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌ។ ហេតុនេះយើងឃើញថាបទរំលោភសេពសន្ថវៈនេះ គឺស្ថិតនៅក្នុងបទឧក្រិដ្ឋព្រោះតែអតិបរមានៃទោសនៅក្នុងបទនេះត្រូវបានកំណត់លើសពី ៥ឆ្នាំ ដែលស្របទៅតាមមាត្រា៤៦ កថាខណ្ឌទី១ ចំណុចទី២ នៃក្នុងក្រមព្រហ្មទណ្ឌដែលបានឱ្យនិយមន័យពីបទឧក្រិដ្ឋ។

**៣.២.៤.២.ចំណាត់ថ្នាក់បទល្មើសនៃបទប្រទូស្តកេរខ្មាស**

ចំណែកឯនៅក្នុងបទល្មើសនៃបទប្រទូស្តកេរខ្មាសវិញ ឃើញថាអតិបរិមានៃទោសផ្តន្ទាទោសដាក់ពន្ធនាគារនៅក្នុងបទល្មើសនេះត្រូវបានកំណត់ពី ១(មួយ)ឆ្នាំ ទៅ៣(បី) ឆ្នាំហេតុដូចនេះយើងអាចកំណត់បានថាបទប្រទូស្តកេរខ្មាស គឺស្ថិតនៅក្នុងបទមជ្ឈិមតែប៉ុណោះ។ បន្ថែមពីលើនេះទៅទៀតនៅក្នុងបទល្មើសប្រទូស្តកេរខ្មាសក៏មានបន្ថែមការពិន័យជាប្រាក់ថែមទៀតផងដោយធ្វើការពិន័យជាប្រាក់ពី ២.០០០.០០០ (ពីលាន) រៀលទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល។

[68] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ មាត្រា៤៦ កថាខណ្ឌទី១
[69] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ មាត្រា៤៧ កថាខណ្ឌទី១
[70] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ មាត្រា៤៨ កថាខណ្ឌទី១

សរុបជារួមមក ចំពោះចំណាត់ថ្នាក់នៃបទល្មើសទាំងពីរនេះ គឺបទរំលោភសេពសន្ថវៈ និងបទប្រទូស្តកេរខ្មាសឃើញថាបទល្មើសទាំងពីរនេះមិនស្ថិតនៅក្នុងចំណាត់ថ្នាក់នៃបទល្មើសតែមួយនោះឡើយ ដោយឆ្លងតាមការបកស្រាយខាងលើយើងអាចធ្វើការប្រៀបធៀបបានថានៅក្នុងបទរំលោភសេពសន្ថវ គឺស្ថិតនៅក្នុងបទឧក្រិដ្ឋដោយសារតែវាបានបង្កនូវព្យសនកម្មដែលវាមានលក្ខណៈធ្ងន់ធ្ងរ ចំណែកបទប្រទូស្តកេរខ្មាសវិញស្ថិតនៅក្នុងចំណាត់ថ្នាក់នៃបទមជ្ឈិមប៉ុណ្ណោះដែលស្ថិតនៅក្នុងចំណាត់ថ្នាក់ទាបជាង បទរំលោភសេពសន្ថវៈ ព្រោះតែវាមិនបានបង្កនូវព្យសនកម្មណាមួយដែលធ្ងន់ធ្ងរដូចនឹងបទរំលោភសេពសន្ថវៈឡើយ ក៏ប៉ុន្តែមិនមែនមានន័យថាមិនបង្កព្យសនកម្មនោះទេ គឺបទល្មើសនេះនៅតែបានបង្កឱ្យមានការខូចខាតដដែល។

**៣.២.៥.ការប៉ុនប៉ងប្រព្រឹត្តបទល្មើស**

ក្រោយពីយើងធ្វើការសិក្សាអំពីលក្ខណៈខុសគ្នាមួយចំនួនរួចមក បានធ្វើឱ្យយើងយល់បានកាន់តែស៊ីជម្រៅបន្ថែមរវាងបទល្មើសទាំងពីរនេះបន្ថែមទៀត មិនខុសគ្នាពីធាតុផ្សំមួយចំនួនខាងលើនេះទេចំពោះការប៉ុនប៉ងនៅក្នុងបទល្មើសទាំងពីរនេះ ក៏មាននូវលក្ខណៈខុសគ្នាផងដែរពោល គឺនៅក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិមក្នុងករណីដែរបទល្មើសនេះមានចែកទុកជាមុនពីការប៉ុនប៉ងនេះ ហើយការបើអំពើនៃការប្រព្រឹត្តរបស់ចារីត្រូវនឹងលក្ខខណ្ឌដែលមានកំណត់នៅក្នុង មាត្រា២៧ នៃក្រមព្រហ្មទណ្ឌនោះត្រូវបានចាត់ទុកថាជាការប៉ុនប៉ងហើយអំពើនោះនឹងត្រូវបានផ្តន្ទាទោសដូចគ្នាផងដែរទៅនឹងការប្រព្រឹត្តបទល្មើសបានសម្រេចនោះ។

ជាក់ស្តែងបទល្មើសរំលោភសេពសន្ថវៈ ត្រូវបានចាត់ទុកថាស្ថិតនៅក្នុងបទឧក្រិដ្ឋហេតុដូច្នេះហើយចំពោះអំពើទាំងឡាយណាដែលចារីបានធ្វើសកម្មភាពមកខាងក្រៅ ទោះបីជាសកម្មភាពនៃអំពើទាំងនោះបានសម្រេច ឬមិនបានសម្រេចយ៉ាងណាក៏ដោយឱ្យតែស្របទៅតាមលក្ខខណ្ឌដែរបានកំណត់នៅក្នុងមាត្រា២៧ នោះនឹងត្រូវចាត់ទុកថាជាអំពើនៃការប៉ុនប៉ង។ ហេតុដូច្នេះចារីនឹងត្រូវបានផ្តន្ទាទោសដូចគ្នាទៅនឹងបទរំលោភសេពសន្ថវៈនេះផងដែរ។

ដោយឡែកចំពោះបទប្រទូស្តកេខ្មាស ត្រូវបានចាត់ថាជាបទមជ្ឈិមតែប៉ុណ្ណោះ ក៏ប៉ុន្តែចំពោះបទល្មើសនេះត្រូវបានច្បាប់កំណត់ពីការប៉ុនប៉ងនៃការប្រព្រឹត្តបទល្មើសនេះបើយោងតាម មាត្រា២៥១ ដែលនិយាយពីការប៉ុនប៉ងចំពោះបទមជ្ឈិមដែលមាននៅក្នុងផ្នែកនោះ ហេតុដូច្នេះហើយរាល់ការប៉ុនប៉ងប្រព្រឹត្តអំពើប្រទូស្តកេរខ្មាសនោះនឹងត្រូវបានផ្តន្ទាទោសដូចគ្នាទៅនឹងបទប្រទូស្តកេរខ្មាសផងដែរ។ គួរកត់សម្គាល់ផងដែរថាមិនមែនគ្រប់បទមជ្ឈិមទាំងអស់សុទ្ធតែមានចែងពីការប៉ុនប៉ងនោះឡើយ។

សរុបជារួមមក នៅក្នុងបទល្មើសទាំងពីរសុទ្ធសឹងតែមានការកំណត់ពីការប៉ុនប៉ងក៏ប៉ុន្តែការប៉ុនប៉ង នៅក្នុងបទល្មើសទាំងពីរនេះមិនមានលក្ខណៈដូចគ្នានោះទេ ទាំងការកំណត់ពីការប៉ុនប៉ង និងការផ្តន្ទាទោសពីការប៉ុនប៉ងទាំងនោះពោល គឺនៅក្នុងបទល្មើសរំលោភសេពសន្ថវៈការប៉ុនប៉ងនៅក្នុងបទល្មើសនេះ គឺជាការប៉ុនប៉ងចំពោះបទឧក្រិដ្ឋហេតុដូច្នេះហើយការផ្តន្ទាទោសចំពោះការប៉ុនប៉ងនេះ ក៏ស្ថិតក្នុងបទឧក្រិដ្ឋដូចគ្នា។ តែផ្ទុយមកវិញចំពោះការប៉ុនប៉ងនៅក្នុងបទប្រទូស្តកេរខ្មាស គឺជាការប៉ុនប៉ងដែលស្ថិតនៅក្នុងបទមជ្ឈិមដែលខុសគ្នាពីបទល្មើសរំលោភសេពសន្ថវៈដែលស្ថិតនៅក្នុងបទឧក្រិដ្ឋចំពោះការផ្តន្ទាទោសនៃការប៉ុនប៉ងនៅក្នុងបទល្មើសនេះនឹងត្រូវបានផ្តន្ទាទោសដូចគ្នាទៅនឹងបទប្រទូស្តកេរខ្មាសដែរ។

### ៣.២.៦.តារាងនៃការប្រៀបធៀប

| **បទរំលោភសេពសន្ថវៈ** | **បទប្រទូស្តកេរខ្មាស** |
|---|---|
| **និយមន័យ** យោងតាម មាត្រា២៣៩ កថាខណ្ឌ១ បានឱ្យនិយមន័យថា គ្រប់អំពើបញ្ចូលអង្គជាតិតាមបែបណាក៏ដោយ ឬការបញ្ចូលឧបករណ៍ណាមួយទៅក្នុងអង្គជាតដែលប្រព្រឹត្តទៅលើអ្នកដទៃ ទោះបីភេទដូចគ្នា ឬមិនដូចគ្នាក៏ដោយ ដោយការប្រើហិង្សា ការបង្ខិតបង្ខំ ការគំរាមកំហែង ឬដោយការឆក់ឱកាស។ | **និយមន័យ** យោងតាម មាត្រា២៤៦ កថាខណ្ឌ១ បានឱ្យនិយមន័យថា គ្រប់អំពើប៉ះពាល់ ស្ទាប់ អង្អែលកេរភេទ ឬផ្នែកភេទផ្សេងទៀតរបស់បុគ្គលដទៃ តែបុគ្គលនេះមិនស្ម័គ្រចិត្តទេ ឬបង្ខំបុគ្គលដទៃប្រព្រឹត្តិអំពើនេះមកលើខ្លួន ឬទៅលើតតិយបុគ្គលក្នុងគោលបំណងអោយរំជួល ឬរីករាយដល់ចំណង់ផ្លូវភេទរបស់ជនល្មើស។ |
| **ចំណុចវិភាគរួម** តាមរយៈនិយមន័យនៃបទល្មើសទាំងពីរខាងលើយើងឃើញថាមាននីតិករបានបានធ្វើការចែងកំណត់អំពីស្ថានភាពផ្សេងៗរវាងបទល្មើសទាំងពីរនោះ ពោលគឺនៅក្នុងបទរំលោភសេពសន្ថវៈ នីតិករបានបង្ហាញពីស្ថានភាពដែលកើតមាននៅក្នុងបទល្មើសនេះយ៉ាងច្បាស់ដូចជាស្ថានភាពនៃអំពើបញ្ចូលអង្គជាត ឬបញ្ចូលឧបករណ៍តាមគ្រប់វិធីជាដើម លើសពីនេះទៅទៀតនីតិករបានបញ្ជាក់ថាការប្រព្រឹត្តអំពើទាំងនោះនឹងកើតមានទៅបុគ្គលភេទដូចគ្នា ឬមិនដូចគ្នា ត្រង់ន័យនេះនីតិករចង់បញ្ជាក់ឱ្យកាន់តែច្បាស់ទៅលើស្ថានភាពដែលអាចនឹងកើតមាន។ រីឯនៅក្នុងនិយមន័យនៃបទប្រទូស្តកេរខ្មាសវិញ នីតិករបានកំណត់ពីស្ថានភាពមួយផ្សេងទៀតដូចជាអំពើប៉ះពាល់ ស្ទាប់ អង្អែលទៅកាន់កេរភេទ ឬផ្នែកភេទផ្សេងទៀតរបស់បុគ្គលដទៃជាដើម ហើយបន្ថែមពីលើនេះទៅទៀតយើងបានសង្កេតឃើញពីភាពខុសប្លែកមួយទៀតនៅក្នុងនិយមន័យបទល្មើសនេះ មិនបានបញ្ជាក់ច្បាស់ថាចារីនឹងប្រព្រឹត្តអំពើប៉ះពាល់ទាំងនោះទៅកាន់បុគ្គលដែលមានភេទដូចគ្នា ឬ មិនដូចគ្នានោះឡើយដោយគ្រាន់តែបញ្ជាក់ ថាប្រព្រឹត្តទៅ | |

<table>
<tr><td colspan="2">បុគ្គលដទៃប៉ុណ្ណោះ។ ហេតុដូចដែលរៀបរាប់ខាងលើបានបញ្ជាក់ថាការកំណត់នៅនិយម នៃបទល្មើសទាំងពីរនេះគឺបានបង្ហាញពីស្ថានភាពដែលកើតមានផ្សេងៗគ្នាផងដែរ។</td></tr>
<tr><td>ការផ្តន្ទាទោស បទរំលោភសេពសន្ថវៈត្រូវផ្តន្ទាទោសដាក់ពន្ធនាគាពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ។ ដោយយោងតាម មាត្រា២៣៩ កថាខណ្ឌ២។</td><td>ការផ្តន្ទាទោស ប្រទូស្តកេរខ្មាសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល។ ដោយយោងតាម មាត្រា២៤៦ កថាខណ្ឌ២</td></tr>
<tr><td colspan="2">ចំណុចវិភាគរួម សរុបជារួមមកការផ្តន្ទាទោសចំពោះបទល្មើសទាំងពីរនេះ គឺមានលក្ខណៈខុសដាច់ពីគ្នាដោយនៅក្នុងបទល្មើសរំលោភសេពសន្ថវៈមានការផ្តន្ទាទោសធ្ងន់ធ្ងរជាងដោយត្រូវច្បាប់កំណត់ពីការផ្តន្ទាទោស រហូតដល់១០ឆ្នាំ រីឯចំពោះបទប្រទូស្តកេរខ្មាសវិញត្រូវបានច្បាប់កំណត់ពីការផ្តន្ទាទោស ៣ឆ្នាំ ប៉ុណ្ណោះដែលវាមានលក្ខណៈស្រាលជាងបទរំលោភសេពសន្ថវៈ ក៏ប៉ុន្តែនៅក្នុងបទល្មើសប្រទូស្តកេរខ្មាសនោះមានកំណត់ពីការពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល បន្ថែមពីនេះទោសដាក់ពន្ធនាគារដែលរៀងខុសប្លែកពីបទរំលោភសេពសន្ថវៈបន្តិចដែលមិនមានកំណត់ពីការពិន័យជាប្រាក់។</td></tr>
<tr><td>ស្ថានទម្ងន់ទោស ច្បាប់បានកំណត់ពីស្ថានភាពជាច្រើនដែលត្រូវបានចាប់ទុកថាស្ថិតក្នុងលក្ខខណ្ឌដែរជាស្ថានទម្ងន់ទោស។ ពោល គឺនៅក្នុងក្រមព្រហ្មទណ្ឌត្រង់ចំណុចដែលនីតិករបាន កំណត់អំពីស្ថានទម្ងន់ទោស នៃបទរំលោភសេពសន្ថវៈនោះមានចាប់ពីមាត្រា២៤០ រហូតដល់ មាត្រា២៤៤។ នៅក្នុងបទល្មើសនេះ ចំពោះស្ថានទម្ងន់ទោសទាក់ទងនឹងជនល្មើសយើងឃើញថា ត្រូវបានកំណត់តែមួយមាត្រាប៉ុណ្ណោះត្រង់មាត្រា២៤០ ក៏ប៉ុន្តែចំពោះស្ថានភាពដែលនៃស្ថានទម្ងន់ទោសដែលទាក់ទងនឹងជនរងគ្រោះវិញ ឃើញថានីតិករបានកំណត់អំពីស្ថានភាពមួយចំនួន ដែលជា</td><td>ស្ថានទម្ងន់ទោស ចំពោះស្ថានទម្ងន់ទោសដែលនៅក្នុងបទល្មើសប្រទូស្តកេរខ្មាសនេះឃើញថាមានស្ថានភាពមួយចំនួនដែលជាលក្ខខណ្ឌ នៃស្ថានទម្ងន់ទោសដែលស្ថិតនៅក្នុងបទល្មើសនេះដែលបានកំណត់នៅក្រមព្រហ្មទណ្ឌ មានតែពីរមាត្រាប៉ុណ្ណោះ ដែលមានស្ថានទម្ងន់ទោសដែលទាក់ទងនឹងការប្រើប្រាស ឬទាក់ទងនឹងចារីត្រង់មាត្រា២៤៧ និងស្ថានទម្ងន់ទោសដែលទាក់ទងនឹងជនរងគ្រោះត្រង់ មាត្រា២៤៨។</td></tr>
</table>

<table>
<tr><td>លក្ខខណ្ឌ ដែលត្រូវបានចាត់ទុកថាជាស្ថានទម្ងន់ទោសរហូតដល់ ទៅបួនមាត្រាដែរមានទាក់ទងទៅនឹងការកាត់អវយវៈ ឬពិការភាព ការធ្វើទារុណកម្ម ឬអំពើឃោរឃៅ និងទាក់ទងទៅនឹងមរណៈភាពនៃជនរងគ្រោះថែមទៀត។</td><td></td></tr>
<tr><td colspan="2">ចំណុចវិភាពរួម ស្ថានទម្ងន់ទោសដែលមាននៅក្នុងបទល្មើសទាំងពីនេះមានលក្ខណៈខុសពីគ្នា ដោយនៅក្នុងស្ថានទម្ងន់ទោសនៃបទល្មើសទាំងពីរនេះយើងឃើញថាបទរំលោភសេពសន្ថវៈបានចែងពីស្ថានភាពនៃស្ថានទម្ងន់ទោសច្រើនចំណុច និងបានរៀបរាប់ពីស្ថានភាពយ៉ាងច្បាស់លាស់ដែលអាចបង្ហាញឱ្យយើងយល់កាន់តែច្បាស់ថែមទៀតទៅកាន់ស្ថានភាពជាក់ស្តែងនៅក្នុងបទល្មើសនេះ។ កាលដែលនីតិករធ្វើការកំណត់ និងរៀបរាប់លម្អិតបែបនេះដោយសារតែបទរំលោភសេពសន្ថវៈនេះជាបទល្មើសមួយដែលបង្ករនូវព្យសនកម្មធន់ធ្ងរយ៉ាងខ្លាំងទៅលើជនរងគ្រោះ និងសណ្តាប់ធ្នាប់សាធារណៈព្រមទាំងសីលធម៌សង្គមផងដែរ។ ក៏ប៉ុន្តែបើក្រឡេចមកមើលបទប្រទូស្តកេរខ្មាសវិញឃើញថាមានស្ថានទម្ងន់ទោសដែលទាក់ទងទៅនឹងចារី និងទាក់ទងនឹងជនរងគ្រោះដូចគ្នាពិតមែន ប៉ុន្តែស្ថានទម្ងន់ទោសដែលទាក់ទងទៅនឹងជនរងគ្រោះ នៅក្នុងបទប្រទូស្តកេរខ្មាសនេះនីតិករមិនបានរៀបរាប់ច្រើនពីស្ថានភាពដែលជាស្ថានទម្ងន់ទោសនៅក្នុងនេះឡើយដោយនីតិករបានរៀបរាប់តែចំណុចមួយចំនួន ដែលជាចំណុចដែលប៉ះពាល់ច្រើនប៉ុណ្ណោះ។ នៅក្នុងបទប្រទូស្តកេរខ្មាសនោះក៏បានបង្ករនូវព្យសនកម្មទៅលើជនរងគ្រោះនិងសីលធម៌សង្គមផងដែរក៏ប៉ុន្តែបើធៀបទៅ និងបទរំលោភសេពសន្ថវៈវិញ គឺមានការបង្ករនូវព្យសនកម្មស្រាលជាងបន្តិច តែទោះយ៉ាងណាក្តីក៏បទល្មើសនេះនៅតែធ្វើឱ្យមាននូវព្យសនកម្មដដែល។</td></tr>
<tr><td>រូបភាពនៃអំពើ ចារីបានប្រព្រឹត្តនេះ គឺជាអំពើសកម្មដែលមានបង្ហាញនៅក្នុងបញ្ញត្តិ មាត្រា២៣៩។ ពោលគឺនៅក្នុងបញ្ញត្តិមានត្រានេះបានបង្ហាញពីសកម្មភាពដែលចារីបានប្រព្រឹត្តអំពើបញ្ចូលអង្គជាត ឬ បញ្ចូលឧបករណ៍ណាមួយទៅលើជនរងគ្រោះដោយការប្រព្រឹត្តនៅក្នុងសកម្មភាពនោះបានបង្ហាញឡើងនៅក្នុងទម្រង់នៃរូបភាពចំនួន ៣ (បី)ដែលរួមមាន៖</td><td>រូបភាពនៃអំពើ អំពើរបស់ចារីបានប្រព្រឹត្តឡើងដែលបានបង្ហាញមកខាងក្រៅ ដែលយើងអាចសម្គាល់ឃើញយ៉ាងច្បាស់ទៅលើអំពើទាំនោះបានដោយស្ថិតក្នុង ៣(បី) រូបភាពរួមមាន៖<br>• រូបភាពទី១ ជនល្មើស ប៉ះពាល់ ស្ទាប់ អង្អែលទៅកាន់កេរភេទ ឬ ផ្នែកភេទផ្សេងទៀតរបស់ជនរងគ្រោះពោលគឺជនល្មើបានធ្វើការប៉ះពាល់ ស្ទាប់ អង្អែល ទៅកាន់កេរ</td></tr>
</table>

<table>
<tr>
<td>• រូបភាពទី១ ការប្រើហិង្សា៖ គឺជាការប្រើហិង្សាផ្នែករូបរាងកាយទៅលើជនរងគ្រោះ ដូចជា ការប្រតាយប្រតប់ទះកំផ្លៀងទាត់ធាក់ជាដើម។<br>• រូបភាពទី២ ការបង្ខិតបង្ខំឬគំរាមកំហែង៖ គឺជាការបង្ខិតបង្ខំ ឬការគំរាមកំហែងដែលអាចជាការគំរាមកំហែងផ្នែកផ្លូវចិត្ត ឬ ការគំរាមកំហែងផ្នែកផ្លូវកាយជាដើម។<br>• រូបភាព ទី៣ ដោយឆ្មក់ឱកាស៖ គឺការប្រព្រឹត្ត ដោយមានការឆ្មក់ឱកាសពោលគឺចារីបានប្រព្រឹត្តឡើងដោយមិនឱ្យជនរងគ្រោះបានដឹងខ្លួននោះឡើយដូចជាពេលកំពុងគេងលក់ស្រវឹងស្រាជាដើម...។</td>
<td>ភេទរបស់ជនរងគ្រោះ ឬ ទៅកាន់ផ្សេងទៀតនៅលើរាងកាយរបស់ជនរងគ្រោះទាំងដែលជនរគ្រោះនោះបានមិនស្ម័គ្រចិត្តនោះទេ។<br>• រូបភាពទី២ ជនល្មើសបង្ខំអោយជនរងគ្រោះប៉ះពាល់ ស្ទាប់អង្អែលកេរភេទឬ ផ្នែកភេទផ្សេងទៀតមកកាន់ខ្លួនវិញ។<br>• រូបភាពទី៣ ជនល្មើសបានបង្ខំឱ្យជនរងគ្រោះប្រព្រឹត្តអំពើប៉ះពាល់ ស្ទាប អង្អែល កេរភេទ ឬផ្នែកភេទផ្សេងទៀតរបស់តតិយជន។</td>
</tr>
<tr>
<td colspan="2">ចំណុចវិភាគរួម ចំពោះរូបភាពនៃអំពើដែលជនល្មើសប្រព្រឹត្តនៅក្នុងបទរំលោភសេពសន្ថវៈ និងបទប្រូទូស្តកេខ្មាសដោយឃើញថារវាងបទល្មើសទាំងពីរនេះមានចំណុចមួយចំនួន គឺមានលក្ខណៈប្រហាក់ប្រហែលគ្នាខ្លះក៏ពិតមែន ក៏ប៉ុន្តែមិនមែនប្រហាក់ប្រហែលគ្នាទាំងស្រុងនោះឡើយ ពោលគឺនៅក្នុងបទរំលោភសេពសន្ថវៈឃើញថាមានបង្ហាញពីសកម្មភាពដូចជាការប្រើអំពើហិង្សា និងការបង្ខិតបង្ខំ ឬ គំរាមគំហែងដែលបានបង្ហាញពីភាពឃោរឃៅ ដែលជនល្មើសប្រព្រឹត្តនូវសកម្មភាពទាំងនេះទៅលើជនរងគ្រោះ ហើយលើសពីនេះទៅទៀតនៅក្នុបទរំលោភសេពសន្ថវៈ ក៏មាននូវសកម្មភាពនៃការឆ្មក់ឱកាសដើម្បីប្រព្រឹត្តអំពើទាំងនោះផងដែរ។ បើយើងក្រឡេកមកមើលនៅក្នុងបទប្រទូស្តកេរខ្មាសវិញយើងឃើញថារូបភាពនៃអំពើ ដែលមាននៅក្នុងបទល្មើសនេះមានចំណុចប្រហាក់ប្រហែលគ្នាទៅនឹងរូបភាពនៃការបង្ខិតបង្ខំតែប៉ុណ្ណោះ ក៏ប៉ុន្តែនៅក្នុងបទល្មើសនេះមិនមានបង្ហាញពីការប្រើហិង្សា និងការឆ្មក់ឱកាសដើម្បីសម្រេចនូវលទ្ធិផលនៃអំពើរបស់ខ្លួនដូចទៅនឹងបទរំលោភសេពសន្ថវៈនោះទេ។</td>
</tr>
<tr>
<td>ចេតនាក្នុងការប្រព្រឹត្ត ចំពោះចេតនានៅក្នុងការប្រព្រឹត្តរបស់ចារីនៅក្នុងបទរំលោភសេពសន្ថវៈនេះ គឺចារីមានចេតនា ឬឆន្ទៈរបស់ខ្លួនក្នុងការបញ្ចូល</td>
<td>ចេតនាក្នុងការប្រព្រឹត្ត ចេតនាក្នុងការប្រព្រឹត្តរបស់ចារីនោះ គឺគ្រាន់តែចង់ប៉ះពាល់ស្ទាបអង្អែលទៅលើកេរភេទរបស់ជនរងគ្រោះ ឬទៅកាន់ផ្នែកភេទផ្សេង</td>
</tr>
</table>

<table>
<tr><td>អង្គជាត ឬឧបករណ៍ផ្សេងៗ ទៅដល់ក្នុងទីជម្រៅនៃអង្គជាតរបស់ជនរងគ្រោះទោះបីជាបានដឹងយ៉ាងប្រាកដក្នុងចិត្តថាជនរងគ្រោះនឹងពុំព្រមព្រៀងស្ម័គ្រចិត្ត ក្នុងការរួមសេវារកិច្ចជាមួយខ្លួនយ៉ាងណាក្តី ក៏ចារីនៅតែចង់សម្រេចនូវអំពើរបស់ខ្លួនដដែល ការដែលចារីមាននូវឆន្ទៈក្នុងការប្រព្រឹត្ត គឺក្នុងគោលបំណងដើម្បីឱ្យសម្រេចបាននូវចំណង់ខាងផ្លូវភេទរបស់ខ្លួន។</td><td>ទៀតនៃជនរងគ្រោះ ឬទៅតតិយជនផ្សេងទៀតប៉ុណ្ណោះ។ គោលបំណង់របស់ចារីប្រព្រឹត្តឡើងនូវអំពើនេះគឺដើម្បីធ្វើឱ្យមានការរីករាយអារម្មណ៍ខាងផ្លូវភេទខ្លួនឯងផ្ទាល់។</td></tr>
<tr><td colspan="2">ចំណុចវិភាគរួម និយាយជារួមមកចេតនានៃការប្រព្រឹត្តរបស់ចារីនៅក្នុងបទល្មើសទាំងពីរនេះមាននូវលក្ខណៈខុសប្លែកពីរគ្នាផងដែលដោយចេតនារបស់ចារីនៅក្នុងបទរំលោភសេពសន្ថវៈ គឺចារីមាននូវចេតនាចង់បញ្ចូលអង្គជាតរបស់ខ្លួន ឬឧបករណ៍ផ្សេងទៀតទៅកាន់អង្គជាតជនរងគ្រោះ ឬផ្នែកផ្សេងទៀតនៃជនរងគ្រោះចំណែកនៅក្នុងបទប្រទូស្តកេរខ្មាសវិញចេតនារបស់ចារី គឺគ្រាន់តែធ្វើការប៉ះពាល់ស្ទាប អង្អែល ទៅលើជនរងគ្រោះតែប៉ុណ្ណោះហើយមិនតែប៉ុណ្ណោះចារី ក៏អាចមានចេតនាបង្ខំឱ្យជនរងគ្រោះប្រព្រឹត្តអំពើទាំងនោះមកកាន់ខ្លួន ឬ ទៅលើតតិយជនផ្សេងថែមទៀតផង ក៏ប៉ុន្តែរាល់ចេតនាទាំងអស់របស់ចារីនៅក្នុងបទប្រទូស្តកេរខ្មាសនេះគ្រាន់តែចង់ធ្វើការប៉ះពាល់ស្ទាបអង្អែលទៅកាន់កេរភេទប៉ុណ្ណោះ ដោយមិនបានដល់ទីជម្រៅនោះទេ មានន័យថាមិនបានបញ្ចូលនូវ អង្គជាតរបស់ខ្លួននោះឡើយ ដែលខុសពីបទរំលោភសេពសន្ថវៈដែលមានចេតនាបញ្ចូលអង្គជាតទៅកាន់ជនរងគ្រោះ។</td></tr>
<tr><td>ចំណាត់ថ្នាក់នៃបទល្មើស ចំពោះបទរំលោភសេពសន្ថវៈត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីរ ៥(ប្រាំ) ឆ្នាំ រហូតទៅ១០(ដប់) ឆ្នាំនោះបើយោងតាម មាត្រា ២៣៩ កថាខណ្ឌទី២នៃក្រមព្រហ្មទណ្ឌ។ ហេតុនេះយើងអាចកំណត់បានថាបទរំលោភសេពសន្ថវៈនេះ គឺស្ថិតនៅក្នុងបទឧក្រិដ្ឋ ក៏ព្រោះតែ អតិបរមានៃទោសនៅក្នុងបទនេះ ត្រូវបានកំណត់លើសពី</td><td>ចំណាត់ថ្នាក់នៃបទល្មើស បទប្រទូស្តកេរខ្មាសវិញឃើញថាចំពោះអតិបរិមានៃទោសផ្តន្ទាទោសដាក់ពន្ធនាគារនៅក្នុងបទល្មើសនេះត្រូវបានកំណត់ពី ១(មួយ)ឆ្នាំ ទៅ ៣(បី)ឆ្នាំ ហេតុដូចនេះយើងអាចធ្វើការកំណត់បានថាបទប្រទូស្តកេរខ្មាស គឺស្ថិតនៅបទមជ្ឈិមតែប៉ុណ្ណោះ។</td></tr>
</table>

<table>
<tr><td>៥ឆ្នាំ ដែលស្របទៅនឹងលក្ខខណ្ឌដែលមាននៅក្នុង មាត្រា៤៦ កថាខណ្ឌទី១ ចំណុចទី២ នៃក្នុងក្រមព្រហ្មទណ្ឌដែលបានឱ្យនិយមន័យពីបទឧក្រិដ្ឋ។</td><td></td></tr>
<tr><td colspan="2">ចំណុចវិភាគរួម ចំពោះចំណាត់ថ្នាក់នៃបទល្មើសទាំងពីរនេះ គឺបទរំលោភសេពសន្ថវៈនិងបទប្រទូស្តកេរខ្មាស ឃើញថាបទល្មើសទាំងពីរនេះមិនស្ថិតនៅក្នុងចំណាត់ថ្នាក់នៃបទល្មើសតែមួយនោះឡើយ ដោយឆ្លងតាមការបកស្រាយខាងលើយើងអាចធ្វើការប្រៀបធៀបបានថានៅក្នុង បទរំលោភសេពសន្ថវៈ គឺស្ថិតនៅក្នុងបទឧក្រិដ្ឋដោយសារតែវាបានបង្ករនូវព្យសនកម្មដែលវាមានលក្ខណៈធ្ងន់ធ្ងរ ចំណែកឯបទប្រទូស្តកេរខ្មាសវិញស្ថិតនៅក្នុងចំណាត់ថ្នាក់នៃបទមជ្ឈិម ប៉ុណ្ណោះដែលស្ថិតនៅក្នុងចំណាត់ថ្នាក់ទាបជាងបទរំលោភសេពសន្ថវៈ ព្រោះតែវាមិនបានបង្ករនូវព្យសនកម្មណាមួយដែលធ្ងន់ធ្ងរខ្លាំងដូច បទរំលោភសេពសន្ថវៈឡើយ ក៏ប៉ុន្តែមិនមែនមានន័យថាមិនបង្ករព្យសនកម្មនោះ គឺនៅតែបានបង្ករឱ្យមានការខូចខាតដដែល។</td></tr>
<tr><td>ការប៉ុនប៉ង ចំពោះអំពើទាំងឡាយណាដែលចារីបានធ្វើសកម្មភាពរួចមកខាងក្រៅហើយ ទោះបីជាសកម្មភាពនៃអំពើទាំងនោះបានសម្រេច ឬមិនបានសម្រេចយ៉ាងណា ក៏ដោយឱ្យតែស្របទៅតាមលក្ខខណ្ឌតែបានកំណត់នៅក្នុង មាត្រា២៧ នោះនឹងត្រូវចាត់ទុកថាជាអំពើនៃការប៉ុនប៉ង។ ហេតុដូច្នេះចារីនឹងត្រូវបានផ្តន្ទាទោសដូចគ្នាទៅនឹងបទរំលោភសេពសន្ថវៈនេះផងដែរ។</td><td>ការប៉ុនប៉ង ចំពោះបទល្មើសនេះត្រូវបានច្បាប់កំណត់ពីការប៉ុនប៉ងនៃការប្រព្រឹត្តបទល្មើសនេះបើយោងតាម មាត្រា២៥១ ដែលនិយាយពីការប៉ុនប៉ងចំពោះបទមជ្ឈិមដែលមានដែលនៅក្នុងផ្នែកនោះ ហេតុដូច្នេះហើយរាល់ការប៉ុនប៉ងប្រព្រឹត្តអំពើប្រទូស្តកេរខ្មាសនោះ និងត្រូវបានផ្តន្ទាទោសដូចគ្នាទៅនឹងបទប្រទូស្តកេរខ្មាសផងដែរ។</td></tr>
<tr><td colspan="2">ចំណុចវិភាគរួម បទល្មើសទាំងពីរសុទ្ធសឹងតែមានការកំណត់ពីការប៉ុនប៉ងក៏ប៉ុន្តែការប៉ុនប៉ងនៅក្នុងបទល្មើសទាំងពីរនេះមិនមានលក្ខណៈដូចគ្នានោះទេ ទាំងការកំណត់ពីការប៉ុនប៉ងនិងការផ្តន្ទាទោសពីការប៉ុនប៉ងទាំនោះពោលគឺ នៅក្នុងបទល្មើសរំលោភសេពសន្ថវៈការប៉ុនប៉ងនៅក្នុងបទល្មើសនេះគឺជាការប៉ុនប៉ងចំពោះបទឧក្រិដ្ឋហេតុដូច្នេះហើយការផ្តន្ទាទោសចំពោះការប៉ុនប៉ងនេះ ក៏ដូចគ្នាទៅនឹងបទរំលោភសេពសន្ថវៈផងដែរ។ តែផ្ទុយមកវិញចំពោះការប៉ុនប៉ងនៅក្នុងបទប្រទូស្តកេរខ្មាស គឺជាការប៉ុនប៉ងដែលស្ថិតនៅក្នុងបទមជ្ឈិម ហេតុដូច្នេះ ការផ្តន្ទាទោសនៃការប៉ុនប៉ងនៅក្នុងបទល្មើសនេះនឹងត្រូវបាន</td></tr>
</table>

ផ្តន្ទាទោសដូចគ្នានឹងបទប្រទូស្តកេរខ្មាសផងដែរ យើងឃើញថាដែលខុសគ្នាពីបទល្មើសរំលោភសេពសន្ថវៈដែលស្ថិតនៅក្នុងបទឧក្រិដ្ឋ។

## ៣.២.ករណីសិក្សា

### ក.ករណីសិក្សាទី១

កាលពីថ្ងៃទី០២ ខែ មករា ឆ្នាំ ២០២២ វេលាម៉ោង ២៣ និង ០០នាទីនៅចំណុចក្នុងបន្ទប់ជួលលេខ០០រាជធានីភ្នំពេញ មានករណី រំលោភសេពសន្ថវៈ ដែលពេលកើតហេតុជនរងគ្រោះ ឈ្មោះ A ភេទស្រី អាយុ ២១ឆ្នាំ បានជួបជុំផឹកស៊ីជាមួយអ្នកជិតខាង ឈ្មោះ B ភេទប្រុស អាយុ ៣១ឆ្នាំដោយនៅក្នុងបន្ទប់ជួលមានគ្នាប្រហែល៥នាក់ រហូតដល់ម៉ោងប្រហែល ២៣ និង ៣០នាទី ជនរងគ្រោះឈ្មោះ Aបានឈប់ផឹក ហើយចូលសម្រាកក្នុងបន្ទប់ជួលរបស់ ដោយពុំបានចាក់សោរបន្ទប់ទេ ពេលនោះឈ្មោះ Bក៏បានឈប់ផឹកហើយដើរទៅសម្រាកដែរ ឃើញទ្វារបន្ទប់ជនរងគ្រោះមិនចាក់សោរក៏បានចូលបន្ទប់របស់ជនរងគ្រោះ ហើយក៏បានដោយឃើញឱកាសល្អដែលឈ្មោះ Aនៅម្នាក់ឯងក៏បានចូលទៅហើយក៏ធ្វើសកម្មភាពរំលោភរហូតបានសម្រេចរួចដើរទៅដេកបន្ទប់ជួលបាត់។ លុះដល់ថ្ងៃទី០៣ ខែមករា ឆ្នាំ២០២២ម្តាយឈ្មោះ A ដែលជាជនរងគ្រោះបាន ឃើញឈ្មោះ Bនៅបន្ទប់ជួលក៏បានរាយការណ៍ប្រាប់សមត្ថកិច្ចឲ្យចុះមកឃាត់ខ្លួនជនជាប់ចោទហើយជនរងគ្រោះបានដាក់ពាក្យបណ្តឹងចោទប្រកាន់ជនសង្ស័យតែម្តង ។

ដំណោះស្រាយយោងតាមអង្គហេតុខាងលើនេះ យើងត្រូវពិនិត្យមើលរាល់ធាតុផ្សំទាំងអស់នៃបទល្មើសដូចខាងក្រោម ៖

**ធាតុផ្សំទី១៖** ឈ្មោះ B ត្រូវបានចោទប្រកាន់ថារូបគាត់មានចេតនាក្នុង ការប្រព្រឹត្តអំពើរំលោភសេពសន្ថវៈ ដែលអំពើនេះជាអំពើផ្ទុយពីច្បាប់ ដែលជនជាប់ចោទបានធ្វើសកម្មភាព ឆ្លៀតឱកាសក្នុងពេលដែលជនរងគ្រោះស្ថិតក្នុងស្ថានភាពស្រវឹង ហើយស្នាក់នៅក្នុងបន្ទប់ជួលម្នាក់ឯង។

**ធាតុផ្សំទី២៖** ការចូលទៅចាប់ជនរងគ្រោះឈ្មោះ A រំលោភនោះគឺផ្ទុយពីឆន្ទៈរបស់ជនរងគ្រោះដែលអំពើរបស់ជនជាប់ចោទនេះ វាបាន បំពារបំពានទៅនឹងកិច្ចការពារសិទ្ធិ នៃការជ្រើសរើសដៃគូរបស់ភាគីជនរងគ្រោះ បំពារបំពានទៅនិងសេចក្តីថ្លៃថ្នូររបស់មនុស្ស និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ និង

បំពារបំពានទៅនិងកិច្ចការពារលើកកម្ពស់នូវទំនៀមទំលាប់ប្រពៃណី ដ៏ល្អរបស់ជាតិយើងដែលកើតចេញពីអំពើដោយផ្ទាល់របស់ជនជាប់ចោទ។

ដោយផ្អែកលើការវិភាគនេះយើងឃើញថា រាល់ធាតុផ្សំទាំងអស់នៃបទល្មើសរំលោភសេពសន្ថវៈ ដែលកើតចេញពីអំពើដោយផ្ទាល់របស់ជនជាប់ចោទហើយត្រូវបាន ដាក់អោយទទួលខុសត្រូវចំពោះបទឧក្រិដ្ឋ នៃបទ រំលោភសេពសន្ថវៈ ដែលបានចោទប្រកាន់ប្រឆាំងជនជាប់ ចោទដោយអនុលោមតាមមាត្រា ២៣៩ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ។

**ខ.ករណីសិក្សាទី២**

កាលពីថ្ងៃទី ០៨ ខែមីនា ឆ្នាំ ២០១១ ក្រុមគ្រួសាររបស់ ឈ្មោះ ច បានរៀបចំពិធីស្រោចទឹកលើករាសី ដោយបានអញ្ជើញ ឈ្មោះ វ ឱ្យមកស្រោចទឹកលើករាសី ។ លុះពេលដែលឈ្មោះ ច និងគ្រួសារ លើករាសីរួច ឈ្មោះ វ បានឱ្យឈ្មោះ ច ផ្លាស់សំលៀកបំពាក់ស្រោចទឹកចេញ ហើយឱ្យចូលទៅក្នុងបន្ទប់ដេក រួចឈ្មោះ វ ទៅតាមក្រោយលុះពេលដែល ឈ្មោះ វ ចូលទៅដល់ក្នុងបន្ទប់ដេករបស់ ឈ្មោះ ច បន្ទាប់មកឈ្មោះ វ ក៏បានយកដៃច្របាច់សុដន់ និងបឺតជញ្ជក់សុដន់ឈ្មោះ ច ដោយបុរស ឈ្មោះ វ ប្រើល្បិចថាបញ្ចូលមន្តអាគន៍ ។ ក្រោយពេលដែល ឈ្មោះ វ ត្រឡប់ទៅផ្ទះវិញ ឈ្មោះ ច ក៏បាន និយាយរឿងនេះប្រាប់ក្រុមគ្រួសាររបស់ខ្លួន ។ លុះដល់ថ្ងៃទី ០៩ ខែមីនា ឆ្នាំ ២០១១ ក្រុមគ្រួសាររបស់ជនរងគ្រោះ ឈ្មោះ ច ក៏បានហៅ ឈ្មោះ វ ឱ្យមកមើលជំងឺ របស់ជនរងគ្រោះ ឈ្មោះ ច ម្តងទៀត ។ ពេលដែល ឈ្មោះ វ មកដល់ក្រុមគ្រួសាររបស់ជនរងគ្រោះ ក៏បានឱ្យ ឈ្មោះ វ ចូលមើលឈ្មោះ ច ដែលឈឺដេកនៅក្នុងបន្ទប់ ហើយក្រុមគ្រួសារជនរងគ្រោះចាំលបមើលពីខាងក្រៅ នៅពេលនោះក៏ឃើញ ឈ្មោះ វ លូកស្ទាបសុដន់ ឈ្មោះ ច ហើកក៏នាំគ្នាចូលទៅចាប់ខ្លួនឈ្មោះ វ ប្រគល់ឱ្យសមត្ថកិច្ចតែម្តង ។

ដំណោះស្រាយ យោងតាមអង្គហេតុខាងលើនេះ យើងត្រូវពិនិត្យមើលរាល់ធាតុផ្សំទាំងអស់នៃបទល្មើសដូចខាងក្រោម ៖

**ធាតុផ្សំទី១៖** កាលពីថ្ងៃទី ០៨ ខែមីនា ឆ្នាំ ២០១១ នៅចំណុច ផ្ទះជួលគ្មានលេខ ផ្លូវបេតុង ក្រុម ០០ ភូមិ០០ សង្កាត់០០ ខណ្ឌ០០ រាជធានីភ្នំពេញ ពិតជាមានករណី ប្រទូស្តកេរខ្មាស (ស្ថានទម្ងន់ទោស) លើជនរងគ្រោះឈ្មោះ ច ដោយជនជាប់ចោទ ឈ្មោះ វ ប្រាកដមែន ។

**ធាតុផ្សំទី២៖** នាពេលសវនាការ ជនជាប់ចោទឈ្មោះ ឆ្លើយបដិសេធថា ខ្លួនពុំបានប៉ះពាល់កេរខ្មាសរបស់ ជនរងគ្រោះឈ្មោះទេ ។ ចម្លើយនេះ គ្រាន់តែជាការឆ្លើយដោះសាររបស់ជនជាប់ចោទតែ

ប៉ុណ្ណោះ ដោយ ហេតុថា ផ្អែកតាមចំលើយជនជាប់ចោទឆ្លើយនៅដំណាក់កាលសមត្ថកិច្ច, អយ្យការ, ចំលើយជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណី, ចំលើយសាក្សីបំភ្លឺ និងភស្តុតាងនានាដែលមានក្នុងសំណុំរឿង បង្ហាញអោយឃើញថា ជនជានប់ចោទពិតជាបានច្របាច់ និងបឺតជញ្ជក់សុដន់ជនរងគ្រោះ ឈ្មោះ ប្រាកដមែន ។

**ធាតុផ្សំទី៣៖** ទង្វើ និងសកម្មភាពរបស់ជនជាប់ចោទ ឈ្មោះ វ ដែលបានច្របាច់ និងបឺតជញ្ជក់សុដន់ជនរងគ្រោះឈ្មោះ ច ជាអំពើល្មើសព្រហ្មទណ្ឌ បទប្រទូស្តកេរខ្មាស(ស្ថានទម្ងន់ទោស) ។ ដែលបានប្រើអំណាចរបស់ខ្លួនជាគ្រូមន្តអាគម និងប្រើល្បិចថាបញ្ចូលមន្តអាគមទទៅកាន់ជនរងគ្រោះ។

**ធាតិផ្សំទី៤៖** ការប្រព្រឹត្តអំពើល្មើសរបស់ជនជាប់ចោទ ធ្វើឡើងដោយមានចេតនា និងមានស្មារតីទទួលខុសត្រូវគ្រប់គ្រាន់ និងបានធ្វើអោយប៉ះពាល់ដល់កិត្តិយស សេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះ និងក្រុមគ្រួសាររបស់ជនរងគ្រោះ ប៉ះពាល់ដល់ប្រពៃណីដ៏ល្អរបស់ជាតិ ជាពិសេសបំពានទៅលើនីត្យានុកូលភាពសង្គមដែលត្រូវបានច្បាប់ការពារយ៉ាងម៉ឺងម៉ាត់បំផុត ។

**ធាតុផ្សំទី៥៖** ដោយឃើញថាមានពិរុទ្ធភាពលើឈ្មោះ វ ភេទប្រុស អាយុ ៥៣ឆ្នាំ ជាតិខ្មែរ ពីបទ : ប្រទូស្តកេរខ្មាស (ស្ថានទម្ងន់ទោស)តាមបញ្ញត្តិមាត្រា ២៤៧ នៃក្រមព្រហ្មទណ្ឌ ។

# សេចក្ដីសន្និដ្ឋាន

ឆ្លងតាមរយៈការសិក្សាស្រាវជ្រាវ និងព្រមទាំងបានធ្វើការបកស្រាយកន្លងមករវាងបទល្មើសទាំងពីរគឺបទរំលោភសេពសន្ថវៈ និងបទប្រទូស្តកេរខ្មាសដែលយើងបានសម្រឹតសម្រាំងដើម្បីកំណត់ពីប្រភពនៃបទល្មើសទាំងពីរដែលបានកំណត់នៅក្នុងក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាបានបង្ហាញឱ្យឃើញច្បាស់អំពីស្ថានភាពនៃការបំពានទៅលើច្បាប់ដែលតែងតែកើតមាននៅក្នុងសង្គមយើង ក៏ប៉ុន្តែបទល្មើសទាំងពីរនៃប្រធានបទរបស់យើងត្រូវច្បាប់បានកំណត់យ៉ាងតឹងរឹងបំផុតចំពោះរាល់ការបំពានដែលកើតមានឡើង។

ដើម្បីឆ្លើយតបចំពោះការសិក្សាកន្លងមក យើងខ្ញុំបានលើកយកបទល្មើសចំនួនពីរ ដើម្បីយកធ្វើការសិក្សាស្រាវជ្រាវនិងធ្វើការប្រៀបធៀបដោយបទល្មើសទីមួយគឺ បទរំលោភសេពសន្ថវៈដែលបានចែងត្រង់មាត្រា២៣៩ និងបទល្មើសមួយទៀតគឺបទប្រទូស្តកេរខ្មាសដែលត្រូវបានចែងនៅមាត្រា២៤៦។ យើងបានបង្ហាញបានពីសញ្ញាណមួយចំនួននៃបទល្មើសទាំងពីរជាពិសេសនោះ គឺការប្រៀបធៀបដែលយើងបានរៀបរាប់យ៉ាងលំអិតអំពីលក្ខណៈដូច និងខុសគ្នារវាងបទល្មើសទាំងពីរនេះ។ ចំពោះលក្ខណៈដែលដូចបានបង្ហាញពីធាតុនីត្យានុកូល(ការដែលនីតិករបានយកបទល្មើសទាំងពីរនេះមកដាក់នៅក្នុងគន្ថីនិងជំពូកតែមួយ) ទោសបន្ថែម(ដែលបទរំលោភសេពសន្ថវៈត្រូវបានកំណត់ត្រង់ មាត្រា២៤៥ និងបទប្រទូស្តកេរខ្មាសត្រូវបានចែងក្នុង មាត្រា២៥២ ដោយទោសបន្ថែមនៅក្នុងបទល្មើសទាំងពីរនេះត្រូវបានកំណត់ផ្តន្ទាទោសដូចគ្នា) លើសពីនេះទៅទៀតប្រធាននៃបទល្មើសក៏មានលក្ខណៈដូចគ្នាផងដែល( ទាក់ទងទៅនឹងជនល្មើសនិងជនរងគ្រោះ) ការបង្ករនូវព្យសនកម្មក៏មាននូវលក្ខណៈដូចគ្នាថែមទៀតផង។ រីឯចំពោះលក្ខណៈខុសគ្នាវិញបានបង្ហាញអំពីចំណាត់ថ្នាក់នៃបទល្មើសទាំងពីរ(ចំណាត់ថ្នាក់នៃរំលោភសេពសន្ថវៈគឺស្ថិតនៅក្នុងបទឧក្រិដ្ឋរីឯនៅក្នុងបទប្រទូស្តកេរខ្មាសវិញស្ថិតនៅក្នុងបទមជ្ឈិម) ធាតុនីត្យានុកូលនៃបទល្មើស (ការឱ្យនូវនិយមន័យដែលបានបង្ហាញពីស្ថានភាពផ្សេងគ្នា នៃបទល្មើសទាំងពីរនិងការផ្តន្ទាទោសនៃស្ថានទម្ងន់ទោសបទរំលោភសេពសន្ថវៈមានចែងត្រង់ មាត្រា២៤០រហូតដល់មាត្រា២៤៤ រីឯបទប្រទូស្តកេរខ្មាសវិញមានចែងត្រង់ មាត្រា២៤៧ និង មាត្រា២៤៨ លើសពីរនេះទៀតមាននូវការប៉ុនប៉ងនៅក្នុងបទល្មើសដោយបទរំលោភសេពសន្ថវៈមានចែងត្រង់ មាត្រា២៧ និងការប៉ុនប៉ងបទប្រទូស្តកេរខ្មាសត្រង់មាត្រា២៥១) ធាតុសត្យានុម័ត (រូបរាងនៃអំពើដែលកើតមានបានលេចឡើងក្នុងរូបភាពពីរផ្សេងគ្នា) និងធាតុអត្តនោម័ត(ចេតនាក្នុងការប្រព្រឹត្តដែលបង្ហាញពីចេតនាក្នុងការប្រព្រឹត្តដោយស្ថិតនៅក្នុងគោលបំណង់ខុសពីគ្នាចំពោះបទល្មើសទាំងពីរនេះ)។

# អនុសាសន៍

ក្រោយពីបានធ្វើការសិក្សាយ៉ាងលម្អិតទៅលើអំពើបទល្មើសរំលោភសេពសន្ថវៈ និងបទល្មើសប្រទូស្តកេរខ្មាសរួចមកយើងបានឃើញថាចំពោះបញ្ញត្តិច្បាប់ដែលបានកំណត់អំពីអំពើបទល្មើសទាំងពីរនេះមានទាំងចំណុចខ្លាំង និងចំណុចមួយចំនួនដែលជាបញ្ហាដែលតម្រូវឱ្យមានការពិនិត្យរកដំណោះស្រាយ និងធ្វើការបំពេញបន្ថែមទៀត។

- **ចំណុចខ្លាំង**

ជាពិសេសចំពោះបញ្ញត្តិច្បាប់នេះ ជាបញ្ញត្តិដែលមានលក្ខណៈទាន់សម័យនិងមានភាពជឿនលឿនថែមទៀតផងដែលយើងអាចរាប់ថាជាសមិទ្ធផលមួយឬ ជាលទ្ធផលនៃនីតិទំនើប។ ដោយរួមផ្សំជាមួយនឹងពាក្យពេចន៍នៃការតាក់តែងនៅក្នុងនេះ និងទាំងរចនាសម្ព័ន្ធនៃការចងក្រងក៏មាននូវលក្ខណៈតាម លំដាប់លំដោយ និងមានទំនាក់ទំនងគ្នាយ៉ាងល្អ។ បន្ថែមពីលើនេះទៅទៀត ចំពោះខ្លឹមសារដែលបានបញ្ញត្តិមកនេះគឺបានគ្រប់ដណ្តប់ទៅស្ថានភាពដែលមាននៅក្នុងបរិបទនៃសង្គមខ្មែរយើងនាពេលបច្ចុប្បន្ន មិនតែប៉ុណ្ណោះយើងឃើញថានីតិករដែលបានតាក់តែងក្រមនេះឡើងមកដោយបានឱ្យច្បាប់អាចធ្វើការបត់បែនទៅតាមគ្រប់ស្ថានភាពជាច្រើន ដែលហាក់បីដូចជានីតិករបានមើលឃើញពីចក្ខុវិស័យដ៏វែងឆ្ងាយយ៉ាងដូច្នោះ។

- **បញ្ហាចោទមួយចំនួន**

ដោយឡែកឃើញថានៅតែមានបញ្ហាមួយចំនួនតែងតែកើតមានឡើងជាបន្តបន្ទាប់រហូតមក ដោយមិនអាចជៀសបាននេះឡើយបើទោះបីជាបញ្ញត្តិនៃច្បាប់នេះ ជាបញ្ញត្តិដែលមានលក្ខណៈទាន់សម័យនិងមានភាពជឿនលឿនយ៉ាងក្តី។

ជាក់ស្តែងទាក់ទងទៅនឹងបទល្មើសរំលោភសេពសន្ថវៈ គឺជាបទល្មើសមួយដែលភាគច្រើនកើតឡើងនៅក្នុងសង្គម មានជាញឹកញាប់ដែលអំពើនោះកើតលើក ស្ត្រី និងកុមារ ហើយក៏អាចកើតលើភេទដូចគ្នា មិនថាតែបទល្មើសនេះទេបទប្រទូស្តកេរខ្មាស ក៏មានកាលវិករាលដាលផងដែរដោយអំពើនេះកើតមាននៅទីកន្លែងណាដែលកំបាំងភ្នែករបស់មនុស្សទូទៅមិនឱ្យមើលឃើញឬជាទីន្លែងណាដែលស្ងប់ស្ងាត់ជាដើមដែលពិបាកក្នុងការដែលមនុស្សទូទៅអាចកត់សម្គាល់ដឹងបានដោយហេតុនេះហើយទើប បទល្មើសទាំងនេះភាគច្រើនគឺពឹងពាក់លើច្បាប់ក្នុងការរកយុត្តិធម៌ និងជួយសង្គ្រោះដោយអាស្រ័យទៅលើការដាក់ពាក្យបណ្តឹងរបស់ជនឯផ្ទាល់ ឬពីសំណាក់បុគ្គលដែលបានដឹងអាចជាអាណាព្យាបាលជនគ្រោះ និងសាច់ញាតិរបស់ជនរងគ្រោះ។ ក៏ប៉ុន្តែដោយសារទាក់ទងទៅនឹងសេចក្តីថ្លៃថ្នូរកិត្តិយសកេរ្តិ៍ឈ្មោះ ដែលរស់នៅក្នុង

សង្គមនោះដោយប្រជាពលរដ្ឋខ្មែរភាគច្រើនឱ្យតម្លៃទៅលើរឿងនោះច្រើនជាង ទើបនាំឱ្យជនរងគ្រោះឬសាច់ញាតិនៃជនរងគ្រោះមិនចង់ឱ្យខូចកិត្តិយស កេរ្តិ៍ឈ្មោះខ្លួនរួមទាំងក្រុម គ្រួសារហើយនឹងមិនចង់ឱ្យបែកធ្លាយរឿងអាម៉ាស់របស់ខ្លួនឱ្យអ្នកក្រៅដឹងថែមទៀតនោះ ទើបតែងតែបណ្តាលឱ្យជនរងគ្រោះភាគច្រើនសុខចិត្តលាក់បាំងរឿងរបស់ខ្លួន ហើយទើបមិនបានប្តឹងទៅកាន់នគរបាលមានសមត្ថកិច្ច។ រីឯនៅក្នុងអំពើប្រទូស្តកេរខ្មាសវិញភាគច្រើន គឺតែងតែកើតមានឡើងចំពោះនារីភេទនិងអនីតិជនដែលមិនទាន់គ្រប់អាយុ ហើយអំពើទាំងនោះ កើតមានឡើងតាមរយៈការបន្លំប៉ះពាល់ទៅកាន់កន្លែងកេរភេទរបស់ជនរងគ្រោះដែលជាទីបិតបាំងរបស់មនុស្សគ្រប់រូប ហេតុដូចនេះហើយដោយសារតែភាពតឹងរឹងនៃប្រពៃណីនៅក្នុងសង្គមយើងបានធ្វើឱ្យជនរងគ្រោះមួយចំនួនមិនហ៊ាន និងដាក់ពាក្យបណ្តឹងដោយខ្លាចរឿងដែលខ្លួនត្រូវបានគេបំពាននោះត្រូវបានផ្សព្វផ្សាយដែលនឹងធ្វើឱ្យប៉ះពាល់ដលកិត្តិយសរបស់ខ្លួន និងក្រុមគ្រួសារ។

បន្ថែមពីលើនេះទៅទៀតចំពោះភស្តុតាងក្នុងបទល្មើសទាំងពីរនេះវិញ យើងឃើញថាភស្តុតាងក្នុងបទល្មើសដែលកើតមាននេះ គឺងាយនឹងបាត់បង់ និងពិបាកក្នុងការស្វែងរក។ ជាទូទៅក្នុងបទល្មើសទាំងពីរនេះយើងឃើញមានភស្តុតាងដូចជា ភស្តុតាងដែលបានបន្សល់ទុកនៅកន្លែងកើតហេតុ និងភស្តុតាងដែលជាប់នៅលើជនរងគ្រោះ ឬ ជាប់លើជនល្មើសជាដើម។ រាល់ភស្តុតាងដែលបន្សល់ទុកនៅកន្លែងកើតហេតុគឺងាយនឹងបាត់បង់ដោយសារតែរយៈពេលដែលកន្លងផុតទៅ។ ចំណែកឯភស្តុតាងដែលជាប់នៅលើជនរងគ្រោះជាទូទៅភស្តុតាងដែលជាប់នៅលើរូបរាងកាយនឹងបាត់បង់ទៅតាមរយៈការជាសះស្បើយ ហើយចំពោះភស្តុតាងដែលបន្សល់ទុកនៅក្នុងប្រដាប់ភេទរបស់ជនរងគ្រោះវិញ ក៏មានកាលកំណត់របស់វាដែរប្រសិនបើផុតកាលកំណត់ហើយវានឹងបាត់បង់ទៅតាមការវិវត្តន៍នៃសរីរាង្គកាយរបស់មនុស្ស។ ចំពោះភស្តុតាងដែលជាប់នៅលើជនល្មើស ជាទូទៅជនល្មើសតែងតែបំបាត់ភស្តុតាង ហើយវាកម្រមានភស្តុតាងដែលបន្សល់ទុកនៅលើជនល្មើសណាស់។ម្យ៉ាងបុគ្គលម្នាក់ៗ មានសិទ្ធិលើបូរណភាព រូបរាងកាយ ក្នុងករណីបើសិនជាជននោះមិនយល់ព្រមឱ្យពិនិត្យលើរូបរាងកាយរបស់ខ្លួនទេ សមត្ថកិច្ចពុំមាន សិទ្ធិក្នុងការចាប់បង្ខំទេ។ ចំពោះភស្តុតាងដែលមាននៅក្នុងអំពើប្រទូស្តកេរខ្មាសគឺពិបាកនៅក្នុងកំណត់ព្រោះថាក្រៅពីការដែលបានឃើញផ្ទាល់ពីសំណាក់សាក្សីនៅកន្លែងកើតហេតុ នោះភស្តុតាងផ្សេងទៀតៗ មានស្ទួចស្តើងខ្លាំណាស់ដោយហេតុថាជនល្មើសនៅក្នុងអំពើនេះគ្រាន់តែប៉ះពាល់ស្ទាប់អង្អែលប៉ុណ្ណោះដូច្នេះភស្តុតាដែលមាននៅលើជនរងគ្រោះនិងនៅលើជនល្មើសគឺងាយនឹងបាត់បង់ទៅវិញ។

- **ដំណោះស្រាយ**

ជុំវិញបញ្ហាដែលកើតមាននេះចំពោះដំណោះស្រាយដែលមានប្រសិទ្ធិភាព គឺមានតែការចូលរួមបង្កើនការផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋគ្នាយល់ដឹងឱ្យបានច្រើនអំពីបទល្មើសរំលោភសេពសន្ថវៈ និងបទល្មើសប្រទូស្តកេរខ្មាសនេះនិងព្រមទាំងលើកកម្ពស់ឱ្យមានការអប់រំអំពីបញ្ហាសុខភាពផ្លូវភេទឱ្យកាន់តែទូលំទូលាយផងដែរ។ មិនតែប៉ុណ្ណោះយើងត្រូវបង្កើតឱ្យមានយន្តការក៏ដូចជាការចូលរួមក្នុងការពន្យល់អំពីបញ្ហាផ្លូវច្បាប់ដល់ប្រជាពលរដ្ឋក៏ដូចជាជនរងគ្រោះឱ្យបានយល់ថា បើជនរងគ្រោះមិនប្តឹង ឬ មិនធ្វើបណ្តឹងបរិហារទៅលើករណីដែលបានកើតមាននូវអំពើបំពានផ្លូវភេទទេនោះជនល្មើសអាចនឹងប្រព្រឹត្តបទល្មើសនេះដដែលៗទៅលើអ្នកផ្សេងទៀត និងអាចបង្កើនចំនួនជនរងគ្រោះដោយអំពើនេះថែមទៀត។

# ឯកសារយោង

## ក.រដ្ឋធម្មនុញ្ញក្រមនិងច្បាប់

– ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បោះពុម្ពផ្សាយដោយ ក្រសួងយុត្តិធម៌ឆ្នាំ២០១១
– ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ បោះពុម្ពផ្សាយដោយ ក្រសួងយុត្តិធម៌ឆ្នាំ២០១២
– ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០០៨
– ច្បាប់ព្រហ្មទណ្ឌអន្តកាល ឆ្នាំ១៩៩២
– សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ១៩៤៨

## ខ.សៀវភៅបោះពុម្ព

– វចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត បោះពុម្ពផ្សាយដោយពុទ្ធសានបណ្ឌិត្យ ព.ស២៥១១
– នីតិព្រហ្មទណ្ឌពិសេសសាស្ត្រាចារ្យ កើត រិទ្ធ ២០១៥
– នីតិព្រហ្មទូទៅសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ ២០១២
– នីតិព្រហ្មទូទៅសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០២២
– នីតិព្រហ្មទូទៅសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០១៤-២០១៥
– នីតិព្រហ្មពិសេសសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០១៣-២០១៤
– នីតិព្រហ្មទណ្ឌទូទៅរៀបរាងដោយសាស្ត្រាចារ្យ ហ៊ី សោភា
– នីតីព្រហ្មទណ្ឌទូទៅនៅខ្មែរសាស្ត្រាចារ្យ កៅ សីហា ឆ្នាំ២០១៣
– នីតីព្រហ្មទណ្ឌពិសេសសាស្ត្រាចារ្យ កៅ សីហា

## គ.គេហទំព័រនិងតំណរភ្ជាប់

– http://www.pheakdeylaw.com/kh/publication/45
– https://ams.com.kh/central/detail/33867
– https://freshnewsasia.com/index.php/en/localnews/121740-2019-05-12-03-12-36.html
– https://pdf.legalcodelawfirm.com/63f594ca51cee1677038794.pdf

# ឧបសម្ព័ន្ធ

# មាតិកាឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី១** ក្រម

**ឧបសម្ព័ន្ធទី២** ច្បាប់ផ្សេងៗ

**ឧបសម្ព័នទី៣** សាលក្រម

# ឧបសម្ព័ន្ធទី១៖

# ក្រម


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
ក្រមព្រហ្មទណ្ឌ
នៃ
ព្រះរាជាណាចក្រកម្ពុជា
២០១០
ក្រសួងយុត្តិធម៌
Ministère de la Justice

## ព្រះរាជក្រម

នស/រកម/១១០៩/០២២

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/១៩៦/០៤ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌

-បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមព្រហ្មទណ្ឌ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១២ ខែតុលា ឆ្នាំ ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះ ទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ ២០០៩ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៦ នីតិកាលទី ២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

### មាត្រា ៤៣.- មូលទោស

មូលទោសរួមមាន ទោសដាក់ពន្ធនាគារ និងទោសពិន័យ ។

ការពិន័យត្រូវគិតជាប្រាក់រៀល ។

### មាត្រា ៤៤.- អប្បបរមា និងអតិបរមានៃមូលទោស

កាលបើបទល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ច្បាប់កំណត់អំពី អប្បបរមា និងអតិបរមានៃទោសដាក់ពន្ធនាគារ ។

កាលបើបទល្មើសត្រូវផ្តន្ទាទោសពិន័យ ច្បាប់កំណត់អំពីអប្បបរមា និង អតិបរមា នៃចំនួនទឹកប្រាក់ពិន័យដែលត្រូវទទួល ។



### មាត្រា ៤៥.- ការទម្ងន់ទោស និងការសម្រាលទោស

អប្បបរមា និងអតិបរមានៃទោសដាក់ពន្ធនាគារ និងការពិន័យជាប្រាក់ អាចបន្ថែម ឬបន្ថយនៅក្នុងលក្ខខណ្ឌដែលចែងដោយក្រមនេះ ។

### មាត្រា ៤៦.- និយមន័យនៃបទឧក្រិដ្ឋ

បទល្មើសជាបទឧក្រិដ្ឋ នៅក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគារដែលត្រូវរងនោះ :

១-ជាទោសដាក់ពន្ធនាគារអស់មួយជីវិត ។

២-ជាទោសដាក់ពន្ធនាគារមានរយៈពេលលើសពី ៥ (ប្រាំ) ឆ្នាំ និងក្រោម ឬស្មើនឹង ៣០ (សាមសិប) ឆ្នាំ ។

ទោសដាក់ពន្ធនាគារ អាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ ។

### មាត្រា ៤៧.- និយមន័យនៃបទមជ្ឈិម

បទល្មើសជាបទមជ្ឈិម នៅក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគារដែលត្រូវរងនោះ មានរយៈពេលលើសពី ៦ (ប្រាំមួយ) ថ្ងៃ និងក្រោម ឬស្មើនឹង ៥ (ប្រាំ) ឆ្នាំ ។

ទោសដាក់ពន្ធនាគារ អាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ ។

**មាត្រា ៤៨.-** និយមន័យនៃបទលហុ

បទល្មើសជាបទលហុ នៅក្នុងករណីដែល :

១-អតិបរមានៃទោសដាក់ពន្ធនាគារដែលត្រូវវាងនោះ មានរយៈពេលក្រោម ឬស្មើនឹង ៦ (ប្រាំមួយ) ថ្ងៃ ។ ទោសដាក់ពន្ធនាគារ អាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ ។

២-បទល្មើសត្រូវផ្តន្ទាទោសត្រឹមតែពិន័យជាប្រាក់ប៉ុណ្ណោះ។

# ជំពូកទី ៣
# ការបំពានខាងផ្លូវភេទ
## ផ្នែកទី ១
## ការរំលោភសេពសន្ថវៈ

**មាត្រា ២៣៩.-** បទរំលោភសេពសន្ថវៈ

គ្រប់អំពើបញ្ចូលអង្គជាត តាមបែបណាក៏ដោយ ឬអំពើបញ្ចូលឧបករណ៍ណាមួយទៅក្នុងអង្គជាត ដែលប្រព្រឹត្តទៅលើអ្នកដទៃ ទោះបីមានភេទដូចគ្នា ឬមិនដូចគ្នាក៏ដោយ ដោយការប្រើហិង្សា ការបង្ខិតបង្ខំ ការគំរាមកំហែង ឬដោយការឆ្មក់ឱកាស គឺជាបទរំលោភសេពសន្ថវៈ ។

បទរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ។

នីតិភាពនៃការរួមភេទត្រូវបានកំណត់ចាប់ពីអាយុ ១៥ (ដប់ប្រាំ) ឆ្នាំ ឡើងទៅ ។

**មាត្រា ២៤០.-** ស្ថានទម្ងន់ទោសដោយសារមធ្យោបាយប្រើប្រាស់ ឬទាក់ទងនឹងជនល្មើស

បទរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ កាលបើបទល្មើសនេះប្រព្រឹត្តឡើង :

១-ដោយការប្រើអាវុធ ឬគំរាមកំហែងនឹងអាវុធ ។

២-ដោយការប្រើគ្រឿងញៀន ឬគ្រប់វិធីដែលនាំឱ្យជនរងគ្រោះបាត់បង់ ឬចុះខ្សោយលទ្ធភាពទប់ទល់ ។

៣-ដោយបុគ្គលដែលមានអំណាចទៅលើជនរងគ្រោះ ។

៤-ដោយបុគ្គលដែលរំលោភអំណាចដែលមុខងាររបស់ខ្លួនបានប្រគល់ឱ្យ ។

៥-ដោយបុគ្គលច្រើនរូប ដែលប្រព្រឹត្តឡើងក្នុងឋានៈជាចារី សហចារី អ្នកផ្តើមគំនិត ឬជាអ្នកសមគំនិត ។

**មាត្រា ២៤១.-** ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ

បទរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ

១៥ (ដប់ប្រាំ) ឆ្នាំ កាលបើអំពើនេះប្រព្រឹត្តទៅលើ :

១-បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុអាយុនៃបុគ្គលនោះ ។

២-នារីមានគភ៌ កាលបើគភ៌ត្រូវបានគេឃើញជាក់ស្តែង ឬកាលបើជនល្មើសបានដឹង ។

៣-បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុនៃជំងឺ ឬពិការភាព កាលបើស្ថានភាពបុគ្គលនេះត្រូវបានគេឃើញជាក់ស្តែង ឬកាលបើជនល្មើសបានដឹង។

**មាត្រា ២៤២.-** ស្ថានទម្ងន់ទោសដោយសារការកាត់អវយវៈ ឬពិការភាព

បទរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ កាលបើបទល្មើសនេះនាំឱ្យមានការកាត់អវយវៈ ឬពិការភាពជាអចិន្ត្រៃយ៍ ដល់ជនរងគ្រោះ ។

**មាត្រា ២៤៣.-** ស្ថានទម្ងន់ទោសដោយសារការធ្វើទារុណកម្ម ឬអំពើឃោរឃៅ

បទរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ កាលបើបទល្មើសនេះប្រព្រឹត្តឡើងមុនពេល ក្នុងពេល ឬ ក្រោយពេលប្រព្រឹត្តអំពើទារុណកម្ម ឬអំពើឃោរឃៅ ។

**មាត្រា ២៤៤.-** ស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ

បទរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ កាលបើបទល្មើសនេះបណ្តាលឱ្យជនរងគ្រោះស្លាប់ ដោយគ្មានចេតនាសម្លាប់។

**មាត្រា ២៤៥.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទឧក្រិដ្ឋដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្ត នៅក្នុងការប្រកបវិជ្ជាជីវៈ ឬនៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន ។

៤-ការហាមឃាត់ដល់ទណ្ឌិតបរទេសចំពោះការចូល ឬការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

៦-ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៧-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មាន ។

៨-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ផ្នែកទី ២
## ការបំពានខាងផ្លូវភេទដទៃទៀត

**មាត្រា ២៤៦.-** បទប្រទូស្តកេរខ្មាស

គ្រប់អំពើប៉ះពាល់ ស្ទាប អង្អែលកេរភេទ ឬផ្នែកភេទផ្សេងទៀតរបស់បុគ្គលដទៃ តែបុគ្គលនេះមិនសុគ្រចិត្តផងទេ ឬបង្ខំបុគ្គលដទៃឱ្យប្រព្រឹត្តអំពើនេះមកលើខ្លួន ឬទៅលើតតិយបុគ្គល ក្នុងគោលបំណងធ្វើឱ្យរំជួល ឬរីករាយដល់ចំណង់ផ្លូវភេទរបស់ជនល្មើស គឺជាអំពើប្រទូស្តកេរខ្មាស។

អំពើប្រទូស្តកេរខ្មាសត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២ ០០០ ០០០ (ពីរលាន) រៀល ទៅ ៦ ០០០ ០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ២៤៧.-** ស្ថានទម្ងន់ទោសដោយសារមធ្យោបាយប្រើប្រាស់ ឬទាក់ទងនឹងចារី

បទល្មើសដែលមានចែងក្នុងមាត្រា ២៤៦ (បទប្រទូស្តកេរខ្មាស) នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤ ០០០ ០០០ (បួនលាន) រៀល ទៅ ១០ ០០០ ០០០ (ដប់លាន) រៀល កាលបើអំពើនេះ ប្រព្រឹត្តឡើង :

១-ដោយការប្រើអាវុធ ឬការគំរាមកំហែងនឹងអាវុធ ។

២-ដោយការប្រើគ្រឿងញៀន ឬគ្រប់វិធីដែលនាំឱ្យជនរងគ្រោះបាត់បង់ ឬចុះខ្សោយលទ្ធភាពទប់ទល់ ។

៣-ដោយបុគ្គលដែលមានអំណាចទៅលើជនរងគ្រោះ ។

៤-ដោយបុគ្គលដែលរំលោភអំណាច ដែលមុខងាររបស់ខ្លួនបានប្រគល់ឱ្យ ។

៥-ដោយបុគ្គលច្រើនរូប ដែលប្រព្រឹត្តឡើងក្នុងឋានៈជាចារី សហចារី អ្នកផ្តើមគំនិត ឬជាអ្នកសមគំនិត ។

**មាត្រា ២៤៨.-** ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ

បទល្មើសដែលមានចែងក្នុងមាត្រា ២៤៦ (បទប្រទូស្តកេរខ្មាស) នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤ ០០០ ០០០ (បួនលាន) រៀល ទៅ ១០ ០០០ ០០០ (ដប់លាន) រៀល កាលបើអំពើនេះប្រព្រឹត្តទៅលើ :

១-បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុអាយុនៃបុគ្គលនោះ ។

២-នារីមានគភ៌ កាលបើគភ៌ត្រូវបានគេឃើញជាក់ស្តែង ឬកាលបើជនល្មើសបានដឹង ។

៣-បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុនៃជំងឺ ឬពិការភាព កាលបើស្ថានភាពបុគ្គលនេះត្រូវបានគេឃើញជាក់ស្តែង ឬកាលបើជនល្មើសបានដឹង។

**មាត្រា ២៥១.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងក្នុងផ្នែកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមខាងលើដែរ ។

**មាត្រា ២៥២.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬនៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៤-ការហាមឃាត់ដល់ទណ្ឌិតបរទេសចំពោះការចូល ឬការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។



៥-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

៦-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៧-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៨-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រមរដ្ឋប្បវេណី
# នៃ
# ព្រះរាជាណាចក្រកម្ពុជា

កាលបរិច្ឆេទប្រកាសឲ្យប្រើ
០៨ ធ្នូ ២០០៧

# ព្រះរាជក្រម

នស/រកម/១២០៧/០៣០

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រ្តីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមរដ្ឋប្បវេណី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្រប តាមទម្រង់ និងគតិនៃក្រមនេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៤ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

## ជំពូកទី ២
## ការបន្លាញឆន្ទៈ និង កិច្ចសន្យា

### ផ្នែកទី ១
### ការបង្កើតកិច្ចសន្យា

**មាត្រា ៣៣៦.–** ការបង្កើតកិច្ចសន្យាដោយសំណើ និង ស្វីការ

១-កិច្ចសន្យាមានអានុភាពដោយសារសំណើ និង ស្វីការត្រូវគ្នា ។

២-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ក៏កិច្ចសន្យាដែលភាគីម្ខាងទទួលករណីយកិច្ចធ្វើអនុប្បទាននូវកម្មសិទ្ធិលើអចលនវត្ថុ ឬ ករណីយកិច្ចធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុ នឹងមានអានុភាព លុះត្រាតែបានធ្វើលិខិតយថាភូត ។

**មាត្រា ៦១៤.–** ការបន្តជាថ្មីដោយតុណ្ហីភាព

ចំពោះភតិសន្យាចលនវត្ថុ នៅក្នុងករណីដែលភតិកៈបានបន្តការប្រើប្រាស់ ឬ អាស្រ័យផលលើវត្ថុជួលនោះ ទោះនៅក្រោយអំឡុងពេលនៃភតិសន្យា បានផុតកំណត់ហើយក៏ដោយ បើភតិបតីបានដឹងអំពីហេតុនោះហើយ តែមិនបានធ្វើការតវ៉ាទេ ត្រូវសន្មតថាជាភតិសន្យាដែលបានបន្តជាថ្មី ដោយគ្មានកំណត់អំឡុងពេល ហើយមានល័ក្ខខ័ណ្ឌដូចគ្នានឹងកិច្ចសន្យាដែលបានជួលពីមុន លើកលែងតែអំឡុងពេលចេញ ។

# ឧបសម្ព័ន្ធទី២៖

# ច្បាប់ផ្សេងៗ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ច្បាប់ស្តីពី

# ការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ



ឆ្នាំ ២០០៨

ក្រសួងយុត្តិធម៌

Ministry of Justice

# ព្រះរាជាណាចក្រកម្ពុជា


មីសែល បូនីញើ

ចៅក្រម

ទីប្រឹក្សារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ នៃព្រះរាជាណាចក្រកម្ពុជា

ប្រធានគំរោង « គាំទ្រនីតិរដ្ឋ »

សហប្រតិបត្តិការបារាំង


# សេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី

## អត្ថាធិប្បាយ និងប្រៀបធៀប

# វិភាគទាន ចំពោះការសិក្សានីតិព្រហ្មទណ្ឌខ្មែរ


ផូវ សំភី

ហ៊ែល ចំរើន

ចាំង ស៊ីណាត

កើត រិទ្ធ

ម៉ារីយ៉ុង គូរីដាត់

## ជំពូកទី ៦
## អំពើអាសអាភាសលើអនីតិជនអាយុក្រោម ១៥ ឆ្នាំ

**មាត្រា ៤២.-- អំពើរួមភេទជាមួយអនីតិជនអាយុក្រោម ១៥ ឆ្នាំ**

ជនណារួមភេទជាមួយជនដទៃ ដែលមានអាយុតិចជាង ១៥ (ដប់ប្រាំ)ឆ្នាំ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ)ឆ្នាំ ដល់ ១០ (ដប់) ឆ្នាំ ។

**មាត្រា ៤៣.-- អំពើអាសអាភាសលើអនីតិជនអាយុក្រោម ១៥ ឆ្នាំ**

អំពើអាសនៅក្នុងច្បាប់នេះ មានន័យថា ជាអំពើនៃការប៉ះពាល់ ឬ ការបង្ហាញកេរភេទ ឬ ផ្នែកភេទផ្សេងទៀតរបស់ជនដទៃ ឬ ការឱ្យជនដទៃប៉ះពាល់កេរភេទ ឬ ផ្នែកភេទផ្សេងទៀតរបស់ជនល្មើសខ្លួនឯង ឬ របស់តតិយជនក្នុងចេតនាធ្វើឱ្យរំជួល ឬរីករាយដល់ចំណង់ផ្លូវភេទរបស់ជនល្មើស ។

ជនណាដែលប្រព្រឹត្តអំពើអាសទៅលើជនដទៃ ដែលមានអាយុតិចជាង ១៥ (ដប់ប្រាំ) ឆ្នាំ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១(មួយ)ឆ្នាំ ដល់ ៣ (បី) ឆ្នាំ និង ពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន)រៀល ដល់៦.០០០.០០០ (ប្រាំមួយលាន)រៀល ។

ជនណាដែលប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា ៤២ ឬ មាត្រានេះ បើមិនរាងចាលទេ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារទ្វេដង ។

**មាត្រា ៤៤.-- ការលើកលែងពីការផ្ដន្ទាទោស**

ជនណាដែលមានអាយុក្រោម ១៥ ឆ្នាំ នឹងត្រូវលើកលែងពីការផ្ដន្ទាទោស ចំពោះបទល្មើសដូចមានចែងនៅក្នុងមាត្រា ៤២ និងមាត្រា ៤៣ នៃច្បាប់នេះ ។

# ឧបសម្ព័ន្ធទី៣៖

# សាលក្រម

# សាលក្រម

# សំណុំរឿងបទរំលោភសេពសន្ថវៈ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមព្រហ្មទណ្ឌ**

-លេខ

ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២២

-សំណុំរឿងព្រហ្មទណ្ឌលេខ

ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២២

-សំណុំរឿងស៊ើបសួរលេខ

ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២២

-សំណុំរឿងជំនុំជម្រះលេខ

ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២

## សាលក្រម

តាងនាមប្រជារាស្ត្រខ្មែរ

សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២២ វេលាម៉ោង ០២ និង ៣០ នាទីរសៀល នៅសាលសវនាការទី៣ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជម្រះដូចខាងក្រោម៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

១-លោក ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ

២-លោក ជាចៅក្រមប្រឹក្សា

៣-លោក ជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

-លោក ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

-លោក ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

**ដើម្បីជំនុំជម្រះ**

លើសំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២២ ដែលមានជនជាប់ចោទ៖

ឈ្មោះ ភេទប្រុស អាយុ ៣១ឆ្នាំ ជនជាតិខ្មែរ មុខរបរ មិនពិតប្រាកដ មានទីកន្លែងកំណើតនៅភូមិ មានទីលំនៅបច្ចុប្បន្នមុនពេលឃាត់ខ្លួននៅ ឪពុកឈ្មោះ "រ" ម្តាយឈ្មោះ "រ" នៅលីវ ជានីតិជន ទោសពីមុនគ្មាន ។ (ក្នុងឃុំ)

-ឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២២ នៅមណ្ឌលអប់រំកែប្រែទី១ (ម១) ។

ជាប់ចោទពីបទ៖ **រំលោភសេពសន្ថវៈ** ប្រព្រឹត្តនៅចំណុចក្នុងបន្ទប់ជួល កាលពីថ្ងៃទី បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៣៩ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ភេទស្រី អាយុ ២១ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នស្នាក់នៅបន្ទប់ជួល រាជធានីភ្នំពេញ ។

Scanned with CamScanner

-លោកមេធាវី និងមេធាវី

ជា មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ ។

## <u>រំពឹះអង្គហេតុ</u>

យោងតាមរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ដីកាសន្និដ្ឋានស្ថាពររបស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ និងដីកាដំណោះស្រាយបញ្ជូនសំណុំរឿងទៅជំនុំជម្រះបានលើកឡើងនៅអង្គហេតុនៃរឿងក្តីនេះថា៖

កាលពីថ្ងៃទី វេលាម៉ោង ២៣ និង ០០នាទី នៅចំណុចក្នុងបន្ទប់ជួលលេខ រាជធានីភ្នំពេញ មានករណី រំលោភសេពសន្ថវៈ ដែលប្រព្រឹត្ត ឡើងដោយជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ ៣១ឆ្នាំ ជនជាតិខ្មែរ ដោយមុនពេលកើតហេតុជនរងគ្រោះឈ្មោះ ភេទស្រី អាយុ ២១ឆ្នាំ ជួបជុំផឹកស៊ីជាមួយអ្នកជិតខាងបន្ទប់ជួលមានគ្នាប្រហែល១០ នាក់ រហូតដល់ម៉ោងប្រហែល២៣ និង ៣០នាទី ជនរងគ្រោះបានឈប់ផឹកហើយចូលសម្រាកក្នុងបន្ទប់ជួល ដោយពុំបានចាក់សោរបន្ទប់ទេ ពេលនោះជនជាប់ចោទក៏បានឈប់ផឹកហើយដើរទៅសម្រាកដែរ ឃើញទ្វារបន្ទប់ជនរងគ្រោះមិនចាក់សោរក៏បានចូលបន្ទប់របស់ជនរងគ្រោះ ហើយក៏បានប្រកែកគ្នាជាមួយជនរង គ្រោះនិងធ្វើសកម្មភាពរំលោភសេពសន្ថវៈរហូតបានសម្រេច រួចដើរទៅដេកបន្ទប់ជួលបាត់ ។

លុះដល់ថ្ងៃទី០៣ ខែមករា ឆ្នាំ២០២២ ម្តាយជនរងគ្រោះឃើញជនសង្ស័យនៅបន្ទប់ជួល ក៏បានរាយការណ៍ប្រាប់សមត្ថកិច្ចឱ្យចុះមកឃាត់ខ្លួនជនជាប់ចោទ ហើយជនរងគ្រោះបានដាក់ពាក្យបណ្តឹងចោទប្រកាន់ជនសង្ស័យតែម្តង ។

-បានឃើញ របាយការណ៍សំយោគលេខ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២២ របស់អធិការដ្ឋាននគរបាលខណ្ឌកំបូល ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

## <u>នាពេលសវនាការ</u>

១/. ជនជាប់ចោទឈ្មោះ បានឆ្លើយថា៖ ខ្លួនពុំទទួលយកបទចោទប្រកាន់នេះទេ ខ្លួនស្គាល់ឈ្មោះ នៅក្នុងកម្មវិធីជប់លៀង ដោយនៅក្នុងកម្មវិធីនោះគេបាននិយាយផ្សំផ្គុំខ្លួន និងឈ្មោះ ដោយខ្លួនស្ថិតនៅជាពោះម៉ាយ ចំណែកឈ្មោះ ស្ថិតនៅភាពជាស្រីមេម៉ាយ ពេលគេ

Scanned with CamScanner

ចំអែចំអន់នោះ ខ្លួនមានចិត្តស្រលាញ់ ដែលបានមកចូលរួមក្នុងកម្មវិធីជប់លៀងនោះខ្លួននិង ឈ្មោះ អង្គុយជិតគ្នាខ្លួនមើលទៅមុខ ខ្លួនសន្មត់ថានាងស្រលាញ់ខ្លួនដែរ ។

ក្នុងពេលផឹកស៊ីនោះមានការស្រវឹងឈ្មោះ បានទៅបន្ទប់មុននៅពេលចប់កម្មវិធីនោះនៅវេលាម៉ោងប្រហែល១០ និង ២០នាទី នាងក៏ឡើងទៅបន្ទប់របស់គាត់ ខ្លួនក៏ឡើងទៅតាមក្រោយអង្គុយនិយាយគ្នាលេង ខ្លួនបានអង្អែលគាត់រួចក៏សម្រាតខោអាវគាត់ ហើយគាត់ក៏ព្រមពេលនោះគាត់ស្លៀកខោខូវប៊យ តែពុំមានស្លៀកខោទ្រនាប់ទេ ហើយក៏រួមរក្ស័គ្នាទៅ ។

ក្នុងពេលនោះឈ្មោះ មានសភាពស្រវឹងខ្លួនពុំបានស្គាល់នាមត្រកូលគាត់ទេ គ្រាន់តែបានដឹងថាគាត់ឈ្មោះ ។ ឈ្មោះ ស្នាក់នៅ ចំណែកខ្លួនស្នាក់នៅ ពេលរួមរក្ស័គ្នារួចនាងបានដេញខ្លួនអោយខ្លួនមកដេកនៅបន្ទប់របស់ខ្លួនវិញ ។ ខ្លួនសូមបញ្ជាក់ថា នៅពេលកំពុងហូបចុកនោះឈ្មោះ បានសួរខ្លួនថា ពូនៅពោះម៉ាយទើបខ្លួនមានការចាប់អារម្មណ៍មកលើនាង តែនាងពុំបានប្រាប់ខ្លួនថានាងស្រលាញ់ខ្លួនឡើយ ។ ការជប់លៀងនោះនៅផ្ទះរបស់ពូ ដែលគាត់ធ្វើបន្ទប់ជួលអោយពួកកម្មកររោងចក្រស្នាក់នៅមានបួន បន្ទប់ ពេលជប់លៀងនោះអ្នកជួលបន្ទប់នោះពុំបានមកជប់លៀងទេ មានតែឈ្មោះ ម្នាក់ប៉ុណ្ណោះ ។

មុនពេលដែលខ្លួនរួមរក្ស័ជាមួយនាងនោះ ខ្លួនបានចូលទៅបន្ទប់របស់នាងដោយទ្វារបន្ទប់របស់នាងពុំបានបិទទេ នៅចំហរតិចៗ ខ្លួនក៏ចូលទៅអង្គុយជិតនាង រួចខ្លួនអង្អែលស្មារបស់នាង ហើយនាងក៏ញញឹមសើចដាក់មកខ្លួន ទើបខ្លួនចាប់អង្អែលនាង រួចដោះខោរបស់នាងតែខ្លួនពុំបានស្ពាបដោះរបស់នាងទេ ហើយក៏ពុំ បានថើបនាងដែរ ពេលរួមរក្ស័នោះពុំបានបិទទ្វារទេ នៅចំហធម្មតា ការរួមភេទនោះតែមួយភ្លែតទេ តែនាងពុំបានប្រាប់ខ្លួនអោយឈប់ទេ ខ្លួនពុំបានដោះអាវនាងទេនៅពាក់ធម្មតា ខ្លួនស្រាតតែខោខូវប៊យរបស់នាងទេការរួមរក្ស័នោះនៅលើឥដ្ឋតែក្នុងបន្ទប់នោះមានពូក លុះព្រឹកឡើងស្រាប់តែគាត់ប្តឹងសមត្ថកិច្ចអោយមកចាប់ខ្លួនទៅវិញ ។

២/. តាមអំណានចម្លើយជនរងគ្រោះឈ្មោះ ថា៖ ខ្លួនសុំរក្សាចម្លើយរបស់ខ្លួននៅសមត្ថកិច្ចទុកជាបានការដដែល ។ ខ្លួននិងឈ្មោះ ពុំដែលស្គាល់គ្នាទេ ។ នៅថ្ងៃកើតហេតុម្ចាស់ផ្ទះជួលបានរៀបចំកម្មវិធីហូបចុកនៅកន្លែងផ្ទះជួល ដោយម្ចាស់ផ្ទះគាត់បានហៅខ្លួនអោយចូលរួមដែរ ។ ការហូបចុកចាប់ផ្តើមពីម៉ោង៨ យប់ទៅ ដោយពេលហូបចុកនោះមានឈ្មោះ ចូលរួមដែរ ដោយឈ្មោះ នេះគឺម្ចាស់ផ្ទះជួលប្រាប់ខ្លួនថា ត្រូវជាក្មួយរបស់គាត់ទើបនឹងមកពីប្រទេស ។ ការហូបចុករហូតដល់ម៉ោង១១ យប់ទើបចប់បែកគ្នាទៅបន្ទប់រៀងៗខ្លួន ។ ចំណែកខ្លួនដើរមកបន្ទប់របស់ខ្លួននៅ ពេលនោះខ្លួនមានអាការៈស្រវឹងខ្លាំង ។ ពេលចូលដល់ក្នុងបន្ទប់ខ្លួនពុំដឹងថាខ្លួនឯងបានចាក់គន្លឹះទ្វារឬអត់ទេ រួចដើរចូលក្នុងបន្ទប់ទឹក ពេលចេញពីបន្ទប់ទឹកមកវិញ ខ្លួនមកអង្គុយនៅមុខកង្ហារបែរខ្នងទៅរកទ្វារ ដោយស្ថិតក្នុងស្ថានភាពស្រវឹងតែពេលនោះឈ្មោះ នេះបានចូលមកក្នុងបន្ទប់ខ្លួនមកឈរពីក្រោយខ្នងខ្លួន ខ្លួន

CS Scanned with CamScanner

បានសួរគាត់ថា ពូឯង ចូលក្នុងបន្ទប់ខ្លួនមានការអ្វី? គាត់ប្រាប់ថា គាត់សុំមកដេកជាមួយផងព្រោះពូគាត់បិតទ្វារបន្ទប់អស់ហើយ ពេលនោះខ្លួនប្រាប់ថា ខ្លួនមិនដែលស្គាល់ពូឯងទេ ហើយខ្លួនដេញគាត់ចេញតែគាត់មិនព្រមចេញ ។ ដោយឮខ្លួនដេញ ដដែលៗ ស្រាប់តែឈ្មោះ ស្ទុះមកសង្គ្រាប់ខ្លួនពីក្រោយ ហើយបោកខ្លួនផ្តួលទៅនឹងភួយធ្វើអោយ ខ្លួនវិលមុខខ្លាំងហើយឈ្មោះ បានសំរាតខោខ្លួនចេញពីជើង រំលោភខ្លួនបានសម្រេច ។ នៅពេលនោះខ្លួនពុំអាចគម្រៃ ពុំអាចរើបំរះ ឬស្រែកអោយគេជួយបានទេ ព្រោះឈ្មោះ

សង្កាត់ខ្លួនជាប់ហើយ ម្យ៉ាងទៀតខ្លួនមានអាការៈស្រវឹងខ្លាំងផង ។ ពេលគាត់រំលោភខ្លួនរួច ខ្លួនមិនហ៊ានស្រែកទេ ខ្លាចគាត់សម្លាប់ខ្លួន ហើយខ្លួនត្រឹមតែដេញគាត់ចេញពីបន្ទប់រួចហើយខ្លួនទូរស័ព្ទប្រាប់ម្តាយខ្លួន អោយបានដឹងនិង ជួយប្តឹងសមត្ថកិច្ច ។ លុះព្រឹកឡើងក៏ឃើញសមត្ថកិច្ចមកឃាត់ខ្លួនជនល្មើសតែម្តង ។

ចំពោះការអះអាងរបស់ឈ្មោះ ថា ខ្លួនរួមភេទជាមួយគាត់ដោយមានការព្រមព្រៀងនោះ ខ្លួនសូមបដិសេធទាំងស្រុង ។ នៅក្នុងរឿងនេះខ្លួនសុំទាម ទារជម្ងឺចិត្តចំនួន ៣,០០០ (បីពាន់) ដុល្លារអាមេរិក ។

៣/. សាក្សីឈ្មោះ បានឆ្លើយថា៖ ខ្លួនត្រូវជាប្អូនបង្កើតរបស់ឈ្មោះ បង ខ្លួនបានទៅរួមរក្សីគ្នាប្រហែលមួយម៉ោងជាង ពេលទំនាក់ទំនងគ្នានោះ នៅពេលកំពុងផឹកស៊ីក្នុងកម្មវិធីជាមួយគ្នា តែខ្លួនពុំដឹងគេស្រលាញ់គ្នា ឬមិនស្រលាញ់គ្នាយ៉ាងណានោះទេ ដោយនៅក្នុងកម្មវិធីនោះមានការរាំជាមួយគ្នាផង ។

អ្នកចូលរួមក្នុងកម្មវិធីនោះប្រហែលជាង ១០ (ដប់)នាក់ ផឹកស្រាបៀរអាំងឈ័រ អស់ ០៤(បួន) កេស ហើយស្រីៗមានគ្នាប្រហែល ០៥ (ប្រាំ) នាក់ អ្នកទាំង ០៥ (ប្រាំ) នាក់នោះសុទ្ធតែអ្នកពូកែផឹក បងរបស់ខ្លួន និងនារីនោះបានអង្គុយផឹកនៅជិតគ្នាៗ ខ្លួនក៏ឡើងទៅដេកមុន ពុំដឹងគេឡើងទៅនៅពេលណាទេ ពេលបងខ្លួនចូលមកបន្ទប់វិញបានប្រហែលមួយម៉ោងជាង ទើបមានការអោឡោឡើង ខ្លួនសួរបងខ្លួន គាត់ប្រាប់ថាបាន រួមរក្ស័ជាមួយនារីនោះ ដោយមានស្នេហាជាមួយគ្នា ពុំមានការខ្លាចទេ ខ្លួនក៏ទៅមើលឃើញនារីនោះយំ ខ្លួនសួរថា មានរឿងអី នារីនោះប្រាប់ថា បងខ្លួនចាប់បង្ខំគាត់ លុះមកដល់ម៉ោងប្រហែល
ស្រីមករករឿងទាំងយប់ ។

## <u>សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ</u>

-តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា ឆ្លងតាមការសួរដេញដោលនាពេលសវនាការនេះ និងបានពិនិត្យភស្តុតាងដែលមានក្នុងសំណុំរឿង ជនជាប់ចោទពិតជាបានចូលទៅចាប់ជនរងគ្រោះរំលោភសេពសន្ថវៈពិតប្រាកដមែន ។

ក្នុងនាមតំណាងអយ្យការខ្ញុំសូមរក្សាបទចោទប្រកាន់ដូចមានក្នុងដីកាសន្និដ្ឋានស្ពាពរលេខ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២២ ទុកជាបានការដដែល និងសុំអោយតុលាការផ្តន្ទាទោសជនជាប់ចោទទៅតាមច្បាប់ ។

## <u>សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ</u>

CS Scanned with CamScanner

-មេធាវីការពារសិទ្ធិអោយជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានការពារថា៖ កូនក្តីរបស់ខ្ញុំ និងជនរងគ្រោះបានស្គាល់គ្នាក្នុងកម្មវិធីជប់លៀង មានការផឹកស៊ីក្នុងពេលនោះកូនក្តីរបស់ខ្ញុំ និងជនរងគ្រោះមានភាពស្រវឹងបាត់បង់នូវស្មារតី ទើបមានការរួមរ័ក្សគ្នា នៅពេលជនរងគ្រោះដឹងខ្លួនទើបមានការប្តឹងផ្តល់គ្នាទៅវិញ ។

ក្នុងនាមខ្ញុំជាមេធាវីការពារសិទ្ធិអោយជនជាប់ចោទ ខ្ញុំសំណូមពរសុំអោយតុលាការពិចារណាសម្រេចអោយកូនក្តីរបស់ខ្ញុំបានរួចផុតពីបទចោទប្រកាន់ដោយក្តីអនុគ្រោះ ។

-ជនជាប់ចោទឈ្មោះ បានសំណូមពរដល់តុលាការជាសំដីចុងក្រោយបង្អស់ថា សូមតុលាការដោះលែងខ្លួនអោយមានសេរីភាពឡើងវិញផង ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយជនរងគ្រោះ

-ក្រោយពីបានស្តាប់ចម្លើយសាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិអោយជនជាប់ចោទ

-ក្រោយពីបានស្តាប់សំដីចុងក្រោយបង្អស់របស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាង ឯកសារនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## <u>សំអាងហេតុ</u>

## <u>អង្គហេតុនៃការចោទប្រកាន់លើឈ្មោះ</u>

១/. យល់ឃើញថា ជនជាប់ចោទឈ្មោះ ត្រូវបានចោទប្រកាន់ទៅតាមអង្គហេតុ នៃការទទួលខុសត្រូវរបស់គាត់ ដែលមានក្នុងដីកាសន្និដ្ឋានស្ថាពរលេខ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ ២០២២ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ និងដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ដូចមានចែងក្នុងមាត្រា២៣៩ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ចំពោះអំពើដែលបានកើតឡើងកាលពីថ្ងៃទី នៅចំណុចក្នុងបន្ទប់

ធានីភ្នំពេញ ។

២/. យល់ឃើញថា ជនជាប់ចោទឈ្មោះ ត្រូវបានចោទប្រកាន់ថារូបគាត់មានចេតនាក្នុងការប្រព្រឹត្តអំពើរំលោភសេពសន្ថវៈ ដែលអំពើនេះជាអំពើផ្ទុយពីច្បាប់ ដែលជនជាប់ចោទបានធ្វើសកម្មភាពឆ្លៀតឱកាសក្នុងពេលដែលជនរងគ្រោះស្ថិតក្នុងស្ថានភាពស្រវឹង ហើយស្នាក់នៅក្នុងបន្ទប់ជួលម្នាក់ឯងចូលទៅចាប់ជនរងគ្រោះរំលោភសេពសន្ថវៈ ផ្ទុយពីឆន្ទៈរបស់ជនរងគ្រោះ ដែលអំពើរបស់ជនជាប់ចោទនេះ វាបានបំពារបំពានទៅនិងកិច្ចការពារសិទ្ធិ នៃការជ្រើសរើសដៃគូររបស់ភាគីជនរងគ្រោះ បំពារបំពានទៅនិងសេចក្តីថ្លៃថ្នូររបស់មនុស្ស និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ និងបំពារបំពានទៅនិងកិច្ចការពារលើកកម្ពស់នូវ

Scanned with CamScanner

ទំនៀមទំលាប់ប្រពៃណីដ៏ល្អរបស់ជាតិ ដែលកើតចេញពីអំពើដោយផ្ទាល់របស់ជនជាប់ចោទ ហើយត្រូវបានដាក់អោយទទួលខុសត្រូវចំពោះបទឧក្រិដ្ឋ នៃបទ រំលោភសេពសន្ថវៈ ដែលបានចោទប្រកាន់ប្រឆាំងជនជាប់ចោទដោយអនុលោមតាមមាត្រា ២៣៩ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ។

## អំពីអង្គហេតុទាក់ទង និងបទ រំលោភសេពសន្ថវៈ

៣/. តុលាការពិនិត្យឃើញថា កាលពីថ្ងៃទី សមត្ថកិច្ចនគរបាល នៃអធិការដ្ឋាននគរបាលខណ្ឌ បានឃាត់ខ្លួនជនជាប់ចោទឈ្មោះ ក្នុងករណីមានការជាប់ពាក់ព័ន្ធក្នុងករណី ចាប់រំលោភសេពសន្ថវៈ លើជនរងគ្រោះនៅចំណុចក្នុងបន្ទប់

រាជធានីភ្នំពេញ ។

៤/. ទាក់ទង និងអំពើ រំលោភសេពសន្ថវៈ ដែលជាអំពើមានគោលដៅ បំពារបំពានទៅ និងកិច្ចការពារសិទ្ធិ នៃការជ្រើសរើសដៃគូររបស់ភាគីជនរងគ្រោះ បំពារបំពានទៅនិងសេចក្តីថ្លៃថ្នូររបស់មនុស្ស បំពារបំពានទៅនិងការបង្កើននូវសុខភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ និងបំពារបំពានទៅនិងកិច្ចការពារការលើកកម្ពស់នូវទំនៀមទំលាប់ប្រពៃណីដ៏ល្អរបស់ជាតិ ហើយសកម្មភាពរបស់ជនជាប់ចោទក្នុងការប្រព្រឹត្តអំពើ រំលោភសេពសន្ថវៈ វាបានចូលរួមក្នុងការបំផ្លាញសង្គមជាតិតាមរយៈសកម្មភាពរបស់ជនជាប់ចោទដូចតទៅ៖

៤-១ ជនជាប់ចោទឈ្មោះ បានឆ្លើយថា៖ ខ្លួនពុំទទួលយកបទចោទប្រកាន់នេះទេ ខ្លួនបានស្គាល់ឈ្មោះ នៅក្នុងកម្មវិធីជប់លៀង ដោយនៅក្នុងកម្មវិធីនោះ គេបាននិយាយផ្សំផ្គុំខ្លួន និងឈ្មោះ ដោយខ្លួននៅជាពោះម៉ាយ ចំណែកឈ្មោះ នៅជាមេម៉ាយ នៅពេលគេចំអែរចំអន់នោះខ្លួនមានចិត្ត ស្រលាញ់ឈ្មោះ ខ្លួនបានមើលមុខឈ្មោះ ទើបខ្លួនសន្មត់ថាឈ្មោះ ក៏មានចិត្តស្រលាញ់ខ្លួនដែរ ព្រោះឈ្មោះ បានសួរខ្លួនថា ពូនៅពោះម៉ាយ ទើបខ្លួនមានការចាប់អារម្មណ៍មកលើនាង តែនាងពុំបានប្រាប់ថា នាងស្រលាញ់ខ្លួនឡើយ ។

នៅពេលផឹកស៊ី នោះឈ្មោះ មានសភាពស្រវឹង ហើយឈ្មោះ ក៏ឡើងទៅបន្ទប់ជួលរបស់ខ្លួនមុន បន្ទប់ នៅពេលចប់កម្មវិធី នៅវេលាម៉ោងប្រហែល ១០ និង ២០នាទី ខ្លួនក៏ឡើង ទៅបន្ទប់នាងតាមក្រោយ ដោយបន្ទប់របស់នាងនៅចំហរទ្វារខ្លួនអង្គុយនិយាយគ្នា ខ្លួនបានអង្អែលនាង ហើយនាងបានញញឹមដាក់ខ្លួន រួចខ្លួនក៏សម្រាតខោអាវរបស់នាង ហើយនាងក៏ព្រម ពេលនោះនាងស្លៀកខោខូវប៊យ តែនាងពុំមានស្លៀកខោទ្រនាប់ក្នុងទេ ហើយខ្លួនបានរួមរក្សជាមួយនាងក្នុងពេល នោះទៅដោយពុំបានបិទទ្វារ បន្ទប់ទេហើយខ្លួនពុំបានស្ទាបដោះរបស់នាង និងពុំបានថើមនាងទេ ហើយក៏ពុំបានដោះអាវរបស់នាងដែរ ការរួមរក្សគ្នានោះនៅលើឥដ្ឋ តែក្នុងបន្ទប់នោះមានគ្រែព្នូក លុះព្រឹកឡើងស្រាប់តែនាងប្តឹងសមត្ថកិច្ចអោយមកចាប់ខ្លួនទៅវិញ ។

៤-២ តាមអំណានចម្លើយជនរងគ្រោះឈ្មោះ ៖ ខ្លួនសុំរក្សាចម្លើយរបស់ខ្លួននៅសមត្ថកិច្ចទុកជាបានការដដែល ។ ខ្លួននិងឈ្មោះ ពុំដែលស្គាល់គ្នាទេ ។ នៅថ្ងៃកើតហេតុម្ចាស់ផ្ទះជួល

CS Scanned with CamScanner

បានរៀបចំកម្មវិធីហូបចុកនៅកន្លែងផ្ទះជួល ដោយម្ចាស់ផ្ទះគាត់បានហៅខ្លួនអោយចូលរួមដែរ ។ ការហូបចុកចាប់ផ្តើមពីម៉ោង៨ យប់ទៅ ដោយពេលហូបចុកនោះមានឈ្មោះ ចូលរួមដែរ ដោយឈ្មោះ

នេះម្ចាស់ផ្ទះជួលប្រាប់ខ្លួនថា ត្រូវជាក្មួយរបស់គាត់ទើបនឹងមកពីប្រទេស ។ ការហូបចុករហូតដល់ម៉ោង១១ យប់ទើបចប់បែកគ្នាទៅបន្ទប់រៀងៗខ្លួន ។ ចំណែកខ្លួនដើរមកបន្ទប់របស់ខ្លួនទៅ ពេលនោះខ្លួនមានអាការៈស្រវឹងខ្លាំង ។ ពេលចូលដល់ក្នុងបន្ទប់ខ្លួនពុំដឹងថាខ្លួនឯងបានចាក់គន្លឹះទ្វារឬអត់ទេ រួចដើរចូលក្នុងបន្ទប់ទឹក ពេលចេញពីបន្ទប់ទឹកមកវិញ ខ្លួនមកអង្គុយនៅមុខកង្ហារបែរខ្នងទៅរកទ្វារ ខ្លួនស្រវឹងតែនៅពេលនោះឈ្មោះ នេះបានចូលមកក្នុងបន្ទប់ខ្លួនមកឈរពីក្រោយខ្នងខ្លួន ពេលនោះខ្លួនសួរគាត់ថា ពូឯង ចូលក្នុងបន្ទប់ខ្លួនមានការអ្វី? គាត់ប្រាប់ថា គាត់សុំមកដេកជាមួយផងព្រោះពូគាត់បិតទ្វារបន្ទប់ អស់ហើយពេលនោះខ្លួនប្រាប់ថា ខ្លួនមិនដែលស្គាល់ពូនិងទេ ហើយខ្លួនដេញគាត់ចេញតែគាត់មិនព្រមចេញ ។

ដោយឮខ្លួនដេញ ដដែលៗ ស្រាប់តែឈ្មោះ ស្ទុះមកសង្គ្រប់ខ្លួនពីក្រោយ ហើយបោកខ្លួនផ្តួលទៅនឹងភួយធ្វើអោយ ខ្លួនវិលមុខខ្លាំងហើយឈ្មោះ បានសំរាតខោខ្លួនចេញពីជើង រំលោភខ្លួនបានសម្រេច ។ នៅពេល នោះខ្លួនពុំអាចគងៃ ,រើបំរះ ឬស្រែកអោយគេជួយបានទេ ព្រោះឈ្មោះ សង្កត់ខ្លួនជាប់ហើយ ខ្លួនមានអាការៈស្រវឹងខ្លាំងផង ។ ពេលគាត់រំលោភរួច ខ្លួនមិនហ៊ានស្រែកទេ ខ្លាចគាត់សម្លាប់ខ្លួន ហើយខ្លួនត្រឹមតែដេញគាត់ចេញពីបន្ទប់រួចហើយខ្លួនទូរស័ព្ទប្រាប់ម្តាយខ្លួនអោយបានដឹងនិងជួយប្តឹងសមត្ថកិច្ច ។ ហើយ ព្រឹកឡើងក៏ឃើញសមត្ថកិច្ចមកឃាត់ខ្លួនជនល្មើសតែម្តង ។ ចំពោះការអះអាងរបស់ឈ្មោះ ថា ខ្លួនរួមភេទជាមួយគាត់ដោយមានការព្រមព្រៀងនោះ ខ្លួនសូមបដិសេធទាំងស្រុង ។ នៅក្នុងរឿងនេះខ្លួនសុំទាម ទារជម្ងឺចិត្តចំនួន ៣,០០០ (បីពាន់) ដុល្លារអាមេរិក ។

៤-៣ ឈ្មោះ សាក្សីដោះបន្ទុកបានឆ្លើយថា ខ្លួនត្រូវជាប្អូនបង្កើតរបស់ឈ្មោះ

ខ្លួនបានដឹងថាប្អូនបង្កើតរបស់ខ្លួនបានរួមរ័ក្សគ្នា ប្រហែលមួយម៉ោងជាងមុនពេលដែលមានការរួមរ័ក្សគ្នានោះមានទំនាក់ទំនងគ្នានៅពេលចូមរួមផឹកស៊ីជាមួយគ្នា តែខ្លួនពុំបានដឹងគេស្រឡាញ់គ្នា ឬមិនស្រលាញ់គ្នានោះទេ គ្រាន់តែដឹងថាបានរាំលេងជាមួយគ្នាផង ។

ចំពោះអ្នកដែលមកចូលរួមជប់លៀងនោះមានគ្នាប្រហែល ១០ (ដប់) នាក់ជាង មានស្រីៗប្រហែល ០៥ (ប្រាំ) នាក់ ជាងសុទ្ធតែជាអ្នកពូកែផឹកអស់ស្រាបៀរអាំងឈ័រ ០៤(បួន) កេស ។ ក្នុងពេលហូបចុកនោះបងរបស់ខ្លួន និងនារីនោះអង្គុយនៅជិតគ្នា ហើយខ្លួនបានឡើងទៅដេកមុន ខ្លួនពុំដឹងគេឡើងទៅដេកនៅពេលណាទេ ។ ពេលបងខ្លួនចេញពីបន្ទប់មកវិញ ទើបមានការឡោឡឡើង ខ្លួនបានសួរបងប្រុសរបស់ខ្លួន គាត់ប្រាប់ថា គាត់មានស្នេហាជាមួយនារីនោះ ហើយបានរួមរ័ក្សជាមួយគ្នា គាត់ថាពុំមានការភ័យខ្លាចនោះទេ លុះមកដល់ម៉ោង ០១ (មួយ) ជាងម្តាយខាងស្រីមករករឿងទាំងយប់ ។

ពេលបងខ្លួនចេញពីបន្ទប់ខាងស្រីមក ខ្លួនទៅមើលឃើញនារីនោះយំ ខ្លួនបានសួរនារីនោះ គាត់ថា បងខ្លួនចាប់បង្ខំគាត់រំលោភ ។

CS Scanned with CamScanner

៥/. យល់ឃើញថា តាមចម្លើយជនជាប់ចោទ ចម្លើយជនរងគ្រោះ ចម្លើយសាក្សី ដោះបន្ទុកបាន បង្ហាញអោយឃើញថា ជនជាប់ចោទឈ្មោះ និងជនរងគ្រោះឈ្មោះ ពិតជាបាន រួមរ័ក្សជាមួយគ្នាបានសម្រេចពិតប្រាកដមែន ។

៦/. យល់ឃើញថា ការឆ្លើយដោះសាររបស់ជនជាប់ចោទ ថា ខ្លួនបានរួមរ័ក្សជាមួយឈ្មោះ

ដោយមានការយល់ព្រមជាមួយគ្នានោះពុំមានភស្តុតាងដោះបន្ទុកឡើយ ដោយហេតុថា ផ្ទុយពី ចម្លើយសាក្សីដោះបន្ទុក ឈ្មោះ ដែលត្រូវជាប្អូនបង្កើតរបស់ជនជាប់ចោទដែលថាក្នុងពេល កើតហេតុនោះមានការអោឡូឡើង ហើយខ្លួនបានទៅមើលជនរងគ្រោះឈ្មោះ យំនៅពេល កើតហេតុរួច ភ្លាមខ្លួនសួរនារីនោះហើយនារីនោះឆ្លើយថា បងខ្លួនចាប់គាត់រំលោភ ហើយម្តាយខាងស្រីក៏ មករករឿងទាំងយប់ ។

ដូចនេះ ជនជាប់ចោទពិតជាបានឆ្លៀតឱកាសក្នុងពេលដែលជនរងគ្រោះឈ្មោះ ស្ថិត ក្នុងស្ថានភាពស្រវឹង ពុំអាចតបតបាន ម្យ៉ាងទៀតទ្វារបន្ទប់របស់ជនរងគ្រោះពុំបានចាក់គន្លឹះទ្វារចូលទៅប្រើ ហិង្សាចាប់សម្រាតខោខូវប៊ិយជនរងគ្រោះរួចរំលោភបានសម្រេចទើបចេញមកវិញ ។

៧/. យល់ឃើញថា អំពើរបស់ជនជាប់ចោទដែលបានឆ្មក់ឱកាសក្នុងពេលជនរងគ្រោះស្ថិតក្នុងស្ថាន ភាពស្រវឹង ប្រើហិង្សាមកលើជនរងគ្រោះដោយចាប់សម្រាតខោជនរងគ្រោះរួចបញ្ចូលលិង្គ (អង្គជាត) របស់ ខ្លួនទៅក្នុងយោនី (អង្គជាត) ជនរងគ្រោះនោះជាអំពើល្មើសព្រហ្មទណ្ឌ បទ រំលោភសេពសន្ថវៈ ។

៨/. ការលើកឡើងរបស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ក្នុងសេចក្តីសន្និដ្ឋានប្តឹង សុំអំពីអង្គហេតុ និងពិរុទ្ធភាពលើជនជាប់ចោទពីបទ រំលោភសេពសន្ថវៈ នោះមានលក្ខណៈត្រឹមត្រូវតាម ច្បាប់ ។

៩/. មានភស្តុតាង និងពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ ៣១ឆ្នាំ ជន ជាតិខ្មែរ ពីបទ **រំលោភសេពសន្ថវៈ** ប្រព្រឹត្តនៅចំណុចក្នុងបន្ទប់ រាជធានីភ្នំពេញ កាលពីថ្ងៃទី បទល្មើសព្រហ្មទណ្ឌដែលមាន ចែងឱ្យ ផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៣៩ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ។

១០/. ជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ បានប្តឹងសុំទាមទារសំណងជំងឺ ចិត្ត ពីជនជាប់ចោទចំនួន ៣,០០០ (បីពាន់) ដុល្លារអាមេរិក ។ ការទាមទារនេះ តុលាការពិចារណា សម្រេច ទៅតាមសភាពជាក់ស្តែង ។

## ហេតុដូច្នេះទើបនិច្ឆ័យសេចក្តី

១/. **ផ្តន្ទាទោស** ឈ្មោះ ភេទប្រុស អាយុ ៣១ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារ កំណត់ចំនួន ០៦ (**ប្រាំមួយ**)ឆ្នាំ ពីបទ៖ **រំលោភសេពសន្ថវៈ** ប្រព្រឹត្តនៅចំណុចក្នុងបន្ទប់ជួល

CS Scanned with CamScanner

រាជធានីភ្នំពេញ កាលពីថ្ងៃទី                                    បទល្មើស

ព្រហ្ម ទណ្ឌដែលមាន ចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៣៩ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ។

២/. **បង្គាប់ឲ្យ** ឈ្មោះ                    ភេទប្រុស អាយុ ៣១ឆ្នាំ ជនជាតិខ្មែរ បង់ជំងឺចិត្តចំនួន **៥,០០០.០០០៛ (ប្រាំមីលាន) រៀល** អោយមកឈ្មោះ                    ជាជនរងគ្រោះនិងជាដើមបណ្តឹងរដ្ឋប្បវេណី ។ ការទាមទារលើសពីនេះលើកចោល ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២២ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ                    និងកំបាំងមុខជនរងគ្រោះឈ្មោះ                    ។

-ទុកសិទ្ធិប្តឹងទាស់ នឹងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា | ហត្ថលេខា | ហត្ថលេខានិងត្រា |

---

(បានចម្លងត្រឹមត្រូវតាមច្បាប់ដើម)

ថ្ងៃអង្គារ ២រោច ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

# សាលក្រម

# សំណុំរឿងបទប្រទូស្តកេរខ្មាស

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ

លេខ :

ចុះថ្ងៃទី

**សាលក្រមព្រហ្មទណ្ឌ**

**លេខ**

**ចុះថ្ងៃទី ៤**

## តាមនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅសាលជំនុំជម្រះនៃសាលាដំបូងរាជធានីភ្នំពេញ នាថ្ងៃទី ០៣ ខែតុលា ឆ្នាំ ២០១១ ដោយមានសមាសភាពជំនុំជម្រះ ដូចតទៅ :

**ចៅក្រមជំនុំជម្រះ**

លោក ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**តំណាងអយ្យការ**

លោក ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោក ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី ១១ ខែមីនា ឆ្នាំ ២០១១ ដែលមានជនជាប់-ចោទឈ្មោះ ភេទប្រុស អាយុ ៥៣ឆ្នាំ ជាតិខ្មែរ មុខរបរ គ្រូមន្តអាគម ទីកន្លែងកំណើត ភូមិ ឃុំ ស្រុក ខេត្តកណ្ដាល ទីលំនៅបច្ចុប្បន្ន ភូមិ ឃុំ ស្រុក ខេត្តកណ្ដាល ឪពុកឈ្មោះ ម្ដាយឈ្មោះ ប្រពន្ធឈ្មោះ មានកូន ០៥( ប្រាំ) នាក់ ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ គ្មាន ។ ឃាត់ខ្លួនថ្ងៃទី ០៩ ខែមីនា ឆ្នាំ ២០១១ និងឃុំខ្លួន តាមដីកាសំរេចអោយឃុំខ្លួនបណ្ដោះអាសន្នលេខ ចុះថ្ងៃទី ១១ ខែមីនា ឆ្នាំ ២០១១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ និងដីកាបង្គាប់អោយឃុំខ្លួនលេខ ចុះថ្ងៃទី ១១ ខែមីនា ឆ្នាំ ២០១១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ។

ជាប់ចោទពីបទ : **ប្រទូស្តកេរខ្មាស (ស្ថានទំងន់ទោស)** ប្រព្រឹត្តនៅចំណុច ផ្ទះជួលគ្មានលេខ ផ្លូវ ក្រុម ភូមិទួលសង្កែ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៨ ខែមីនា ឆ្នាំ ២០១១ តាមបញ្ញត្តិមាត្រា ២៤៧ នៃក្រមព្រហ្មទណ្ឌ ។

-ជនរងគ្រោះ និងជាដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ភេទស្រី អាយុ ២២ឆ្នាំ ជាតិខ្មែរ មុខរបរ លក់ដូរ មានទីលំនៅ ផ្ទះជួលគ្មានលេខ ផ្លូវ ក្រុម ភូមិទួលសង្កែ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

-មេធាវីការពារសិទ្ធិអោយជនជាប់ចោទឈ្មោះ លោកស្រីមេធាវី ។

***អង្គហេតុនៃរឿង មានដូចតទៅ :***

កាលពីថ្ងៃទី ០៨ ខែមីនា ឆ្នាំ ២០១១ ក្រុមគ្រួសាររបស់ជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ បានរៀបចំពិធីស្រោចទឹកលើករាសី ដោយបានអញ្ជើញជនជាប់ចោទឈ្មោះ អោយមកស្រោចទឹកលើករាសីអោយ ។ លុះពេលដែលជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ស្រោចទឹកលើករាសីរួច ជនជាប់ចោទឈ្មោះ បានអោយជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ផ្លាស់សំលៀកបំពាក់ស្រោចទឹកចេញ ហើយអោយចូលទៅក្នុងបន្ទប់ដេក រួចជនជាប់ចោទឈ្មោះ ក៏ចូលតាមក្រោយ លុះពេលដែលជនជាប់ចោទឈ្មោះ ចូលទៅដល់ក្នុងបន្ទប់ដេករបស់ជនរងគ្រោះ និងជាដើម-បណ្តឹងរដ្ឋប្បវេណីឈ្មោះ ជនជាប់ចោទក៏បានយកដៃច្របាច់សុដន់ និងបឺតជញ្ជក់សុដន់ជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ដោយជនជាប់ចោទប្រើល្បិចថា បញ្ចូលមន្តអាគមន៍ ។ ក្រោយពេលដែលជនជាប់ចោទឈ្មោះ ត្រឡប់ទៅផ្ទះវិញ ជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ក៏បាននិយាយរឿងនេះប្រាប់ក្រុមគ្រួសាររបស់ខ្លួន ។ លុះដល់ថ្ងៃទី ០៩ ខែមីនា ឆ្នាំ ២០១១ ក្រុមគ្រួសាររបស់ជនរង-គ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ក៏បានហៅជនជាប់ចោទឈ្មោះ អោយមកមើលជំងឺរបស់ជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ម្តងទៀត ។ ពេលដែលជនជាប់ចោទឈ្មោះ មកដល់ ក្រុមគ្រួសាររបស់ជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ក៏អោយជនជាប់ចោទចូលមើលឈ្មោះ ដែលឈឺដេកនៅក្នុងបន្ទប់ ហើយក្រុមគ្រួសារជនរងគ្រោះចាំលបមើលពីខាងក្រៅ ឃើញឈ្មោះ លូកស្ទាបសុដន់ឈ្មោះ ហើយក៏នាំគ្នាចូលទៅចាប់ខ្លួនជនជាប់ចោទឈ្មោះ យកមកប្រគល់អោយសមត្ថកិច្ចតែម្តង ។

**-បានឃើញ** របាយការណ៍សំយោគលេខ ចុះថ្ងៃទី ១០ ខែមីនា ឆ្នាំ ២០១១ របស់អធិការ-ដ្ឋាននគរបាលខណ្ឌឫស្សីកែវ ។

**-បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ ចុះថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០១១ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

**-បានឃើញ** ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ចុះថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ ២០១១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ។

**-បានឃើញ** ដីកាសម្រេចរក្សាជនត្រូវចោទអោយនៅជាប់ឃុំបណ្តោះអាសន្នលេខ ចុះថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ ២០១១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ។

***នាពេលសវនាការ :***

-ជនជាប់ចោទឈ្មោះ បានឆ្លើយថា : ខ្លួនកំពុងនៅផ្ទះ ក្មួយស្រីរបស់ខ្លួនឈ្មោះ បានទូរ-ស័ព្ទហៅខ្លួនអោយមកមើលទីតាំងផ្ទះរកស៊ី ខ្លួនបានប្រាប់ថាផ្ទះនោះរកស៊ីមិនសូវបានទេ ដោយថ្ងៃខែឆ្នាំយើងមិនសូវល្អ ហើយគេបានអោយខ្លួនមកស្រោចទឹកលើករាសី (ស្រោចទាំងប្តីទាំងប្រពន្ធ) ។ ពេលស្រោចទឹករួច ខ្លួនចេញមកក្រៅ ដោយពុំបានចូលទៅក្នុងបន្ទប់របស់គេទេ ។ ចំពោះឈ្មោះ ខ្លួនបានស្រោចទឹកអោយដែរ

ដោយស្រោចទាំងសំលៀកបំពាក់ ហើយខ្លួនពុំបានប៉ះពាល់កេរខ្មាសរបស់ឈ្មោះ នោះទេ ។ ចំពោះចំលើយដែលខ្លួនឆ្លើយនៅសមត្ថកិច្ចនោះ ខ្លួនសុំបដិសេធ ដោយខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ។

-តាមអំណានចំលើយជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ថា : កាលពីរសៀលថ្ងៃទី ០៨ ខែមីនា ឆ្នាំ ២០១១ នៅផ្ទះខ្លួនមានកម្មវិធីស្រោចទឹករំដោះគ្រោះ លើករាសី ដោយអញ្ជើញឈ្មោះ អោយមកស្រោចទឹកអោយ ដោយអ្នកដែលស្រោចទឹកនោះមានគ្នា ០៩(ប្រាំបួន)នាក់ ស្រោចទឹកនៅផ្ទះបាយខាងក្រោយម្នាក់ម្តងៗ ពេលដែលខ្លួនស្រោចទឹកនោះ ខ្លួនស្លៀកពាក់ខោអាវឈុតដេកយប់ ។ ពេលដែលខ្លួនប្រាប់គាត់ថាឈឺក្បាល គាត់ក៏អោយខ្លួនបែរខ្នង រួចស្ទាបអង្អែលខ្នងរបស់ខ្លួន ហើយសួរខ្លួនថា មានអារម្មណ៍ទេ ខ្លួនបានឆ្លើយថា គ្មានអារម្មណ៍ទេ គាត់ក៏អោយខ្លួនបែរមុខមើលអោយចំភ្នែកគាត់ ហើយអោយខ្លួនហាមាត់ស្ទាបបីដងគាត់បានយកដៃមកទះដើមទ្រូងខ្លួនមួយដៃ គាត់អោយខ្លួនផ្លាស់សំលៀកបំពាក់ស្រោចទឹកនោះចេញ ស្លៀកពាក់ខោអាវធម្មតាឡើងវិញ ហើយក្មួយខ្លួនចូលមកស្រោចទឹកបន្តពីខ្លួន ពេលក្មួយខ្លួនស្រោចទឹករួច គាត់ក៏ចូលមកស្ទាបអង្អែលខ្លួន រួចបឺតសុដន់ខ្លួនទៀត ។ ចំពោះរឿងនេះ ខ្លួនសុំទាមទារសំណងជំងឺចិត្តចំនួន ៣.០០០(បីពាន់)ដុល្លារអាមេរិក ។

-តាមអំណានចំលើយសាក្សីឈ្មោះ ថា : កាលពីថ្ងៃទី ០៩ ខែមីនា ឆ្នាំ ២០១១ វេលាម៉ោង ១៦:០០ នាទី បងស្រីខ្លួនឈ្មោះ បានទូរស័ព្ទប្រាប់ខ្លួនថា ឈ្មោះ នៅ វៃ បានប្រព្រឹត្តមកលើរាងកាយប្អូនស្រីខ្លួនឈ្មោះ លីដូចនេះ ខ្លួនក៏មកផ្ទះ ហើយរៀបគំរោងអោយគ្រូនោះមកស្រោចទឹកមន្តម្តងទៀតដើម្បីមានភស្តុតាងជាក់ស្តែងក្នុងការឃាត់ខ្លួនប្រគល់អោយសមត្ថកិច្ច ។ លុះមកដល់ម៉ោង ១៧:៣០ នាទី ស្រាប់តែលោកគ្រូនោះបានជិះម៉ូតូឌុបមកដល់ផ្ទះខ្លួន ហើយចូលមើលប្អូនស្រីខ្លួនដែលដេកក្នុងបន្ទប់ ពេលបងប្អូនខ្លួនច្រានទ្វារចូលទៅឃើញគ្រូនោះកំពុងលូកដៃចូលក្នុងអាវប្អូនស្រីខ្លួន ហើយក៏បាននាំគ្នាឃាត់ខ្លួនគាត់យកមកប្រគល់ឱ្យនគរបាលប៉ុស្តិ៍ទួលសង្កែតែម្តង ។

-តាមអំណានចំលើយសាក្សីឈ្មោះ ថា : កាលពីថ្ងៃទី ០៣ ខែមីនា ឆ្នាំ ២០១១ វេលាម៉ោង ១៥:០០ នាទី ប្អូនជីដូនមួយខ្លួនឈ្មោះ បានមកលេងផ្ទះខ្លួន ហើយសួរខ្លួនថា លក់ដូរដាច់ទេ ខ្លួនប្រាប់ថាលក់មិនដាច់ទេ ហើយប្អូនជីដូនមួយប្រាប់ថា ឈ្មោះ ដែលជាពូជីទួតមួយជាមួយខ្លួន ពូកែធ្វើអោយការលក់ដូរដាច់ណាស់ ។ លុះមកដល់ថ្ងៃទី ០៨ ខែមីនា ឆ្នាំ ២០១១ វេលាម៉ោង ១១:៣០ នាទី ខ្លួនបានទូរស័ព្ទហៅឈ្មោះ អោយមកស្រោចទឹកដើម្បីលក់ដូរអោយដាច់ ពេលខ្លួនស្រោចទឹក គាត់បានលូកដៃស្ទាបអង្អែលខ្នងខ្លួន ហើយគាត់សួរខ្លួនថា មានអារម្មណ៍រំភើបដូចដេករួមភេទជាមួយប្តីដែរទេ ខ្លួនឆ្លើយថា មានអារម្មណ៍ដែរ ហើយគាត់អោយខ្លួនមកផ្លាស់ខោអាវ ហើយខ្លួនបានអោយប្អូនស្រីខ្លួនឈ្មោះ ចូលស្រោចទឹកម្តង ពេលប្អូនស្រីខ្លួនស្រោចទឹករួច គាត់បានអោយប្អូនស្រីខ្លួនចូលក្នុងបន្ទប់ដេកមួយសន្ទុះ ក្រោយមកគាត់ជិះម៉ូតូឌុបទៅផ្ទះវិញ ហើយប្អូនស្រីខ្លួនបាននិយាយប្រាប់ខ្លួនថា លោកគ្រូនោះបានច្របាច់សុដន់ និងយកមាត់បឺតជញ្ជក់សុដន់របស់វាលីដូចនេះ ខ្លួនបានពិភាក្សាជាមួយបងប្អូនរៀបគំរោងអោយគ្រូនោះមកស្រោចទឹកអោយប្អូនខ្លួនម្តងទៀត ដើម្បីមានភស្តុតាងជាក់ស្តែង ។ លុះមកដល់ថ្ងៃទី ០៩ ខែមីនា ឆ្នាំ ២០១១ វេលាម៉ោង ១៥:៣០ នាទី គ្រូនោះបានជិះ

ម៉ូតូឌុបមកដល់ផ្ទះខ្លួន ហើយគាត់បានចូលក្នុងបន្ទប់មើលប្អូនខ្លួនដេកក្នុងបន្ទប់ ពេលគាត់ចូលទៅមើលប្អូនស្រីយូរពេកខ្លួនបានច្រានទ្វារចូលទៅ ឃើញគ្រូនោះកំពុងលូកស្ទាបសុដន់ប្អូនស្រីខ្លួន ហើយខ្លួនក៏ចាប់គ្រូនោះយកមកប្រគល់អោយនគរបាលប៉ុស្តិ៍រដ្ឋបាលទួលសង្កែតែម្តង ។

-តាមអំណានចំលើយសាក្សីឈ្មោះ ថា : កាលពីថ្ងៃទី ០៩ ខែមីនា ឆ្នាំ ២០១១ វេលាម៉ោង ១៩:៣០ នាទី ប្រពន្ធរបស់ខ្លួនបានទូរស័ព្ទប្រាប់ខ្លួនថា កាលពីថ្ងៃទី ០៨ ខែមីនា ឆ្នាំ២០១១ វេលាម៉ោង ១១:៣០ នាទី ឈ្មោះ នៅ វៃ បានប្រព្រឹត្តមកលើរាងកាយឈ្មោះ ពេលលឺដូចនេះ ខ្លួនក៏មកផ្ទះរៀបចំគំរោងអោយគ្រូនោះមកស្រោចទឹកម្តងទៀតដើម្បីមានភស្តុតាងក្នុងការឃាត់ខ្លួនប្រគល់អោយសមត្ថកិច្ច ។ លុះមកដល់ម៉ោង ១៩:៣០ នាទី ស្រាប់តែគ្រូនោះជិះម៉ូតូឌុបមកដល់ផ្ទះ ហើយគាត់ចូលមើលប្អូនថ្លៃខ្លួនដេកក្នុងបន្ទប់ ពេលបងប្អូនខ្លួនច្រានទ្វារបន្ទប់ចូលទៅ ឃើញគ្រូនោះកំពុងលូកដៃចូលទៅក្នុងអាវប្អូនថ្លៃខ្លួន ហើយក៏ឃាត់ខ្លួនគាត់យកមកប្រគល់អោយនគរបាលប៉ុស្តិ៍រដ្ឋបាលទួលសង្កែតែម្តង ។

**-តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា** : ក្នុងរឿងនេះ ជនជាប់ចោទពិតជាបានធ្វើសកម្មភាពប្រទូស្តកេរខ្មាសលើជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ប្រាកដមែន ទោះបីជនជាប់ចោទបានឆ្លើយបដិសេធនៅពេលសវនាការនេះក៏ដោយ ក៏គ្មានភស្តុតាងដោះបន្ទុកដែរ ក្នុងនាមខ្ញុំជាតំណាងអយ្យការ ខ្ញុំនៅតែរក្សាបទចោទប្រកាន់ដដែល និងប្តឹងសុំអោយតុលាការសំរេចផ្តន្ទាទោសជនជាប់ចោទអោយបានធ្ងន់ធ្ងរបំផុត ។

**-មេធាវីការពារសិទ្ធិអោយជនជាប់ចោទ បានធ្វើសេចក្តីសន្និដ្ឋានការពារថា** : កូនក្តីរបស់ខ្លួនបានបដិសេធពុំទទួលយកការចោទប្រកាន់នោះទេ ហើយចំលើយនៅសមត្ថកិច្ចនោះ កូនក្តីរបស់ខ្លួនថាមិនបានឆ្លើយដូចនោះទេ ។ ម្យ៉ាងទៀត ក្រុមគ្រួសារនោះបានហៅអោយកូនក្តីរបស់ខ្លួនមកស្រោចទឹកអោយ ពេលកូនក្តីរបស់ខ្លួនមកដល់ ក្រុមគ្រួសារនោះបានអោយកូនក្តីរបស់ខ្លួននៅជាមួយឈ្មោះ ប្រសិនបើមានហេតុការណ៍កើតឡើងមែននោះ ឈ្មោះ ប្រាកដជាស្រែកពេលនោះហើយ ដោយផ្ទះនោះមានមនុស្សច្រើន ។ ចំណែកការឃាត់ខ្លួនកូនក្តីរបស់ខ្លួនវិញ ជាគំរោងរបស់ក្រុមគ្រួសារឈ្មោះ ដែលបានហៅកូនក្តីរបស់ខ្លួនអោយមកមើលឈ្មោះ ដែលដេកចាំនៅក្នុងបន្ទប់ ពេលកូនក្តីរបស់ខ្លួនចូលទៅក្នុងបន្ទប់នោះ ស្រាប់តែក្រុមគ្រួសារនោះចាប់កូនក្តីរបស់ខ្លួនប្រគល់អោយសមត្ថកិច្ចតែម្តង ។ ក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិអោយជនជាប់ចោទ ខ្លួនសំណូមពរសុំអោយតុលាការពិចារណា និងសំរេចអោយកូនក្តីរបស់ខ្លួនបានរួចផុតពីការចោទប្រកាន់ដោយក្តីអនុគ្រោះ ។

-ជនជាប់ចោទឈ្មោះ បានសំណូមពរដល់តុលាការជាសំដីចុងក្រោយបង្អស់ថា : សូមតុលាការជួយរកយុត្តិធម៌អោយខ្លួនផង ។

**សំអាងហេតុ**

***ក្រោយពីបាន :***

ស្តាប់ចំលើយជនជាប់ចោទ

ស្តាប់អំណានចំលើយជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណី

ស្តាប់អំណានចំលើយសាក្សីបំភ្លឺ

ស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

ស្តាប់សំដីចុងក្រោយបង្អស់របស់ជនជាប់ចោទ

ពិនិត្យ ភស្តុតាង ឯកសារនានា

***ពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ឃើញថា :***

**១**-កាលពីថ្ងៃទី ០៨ ខែមីនា ឆ្នាំ ២០១១ នៅចំណុច ផ្ទះជួលគ្មានលេខ ផ្លូវបេតុង ក្រុម ១៣ ភូមិទូលសង្កែ សង្កាត់ទូលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ពិតជាមានករណី ប្រទូស្តកេរខ្មាស(ស្ថានទំងន់ទោស) លើជនរងគ្រោះឈ្មោះ ដោយជនជាប់ចោទឈ្មោះ ប្រាកដមែន ។

**២**-នាពេលសវនាការ ជនជាប់ចោទឈ្មោះ ឆ្លើយបដិសេធថា ខ្លួនពុំបានប៉ះពាល់កេរខ្មាសរបស់ជនរងគ្រោះឈ្មោះ ទេ ។ ចំលើយនេះ គ្រាន់តែជាការឆ្លើយដោះសាររបស់ជនជាប់ចោទតែប៉ុណ្ណោះ ដោយហេតុថា ផ្អែកតាមចំលើយជនជាប់ចោទឆ្លើយនៅដំណាក់កាលសមត្ថកិច្ច, អយ្យការ, ចំលើយជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណី, ចំលើយសាក្សីបំភ្លឺ និងភស្តុតាងនានាដែលមានក្នុងសំណុំរឿង បង្ហាញអោយឃើញថា ជនជានប់ចោទពិតជាបានច្របាច់ និងបឺតជញ្ជក់សុដន់ជនរងគ្រោះឈ្មោះ ប្រាកដមែន ។

**៣**-ទង្វើ និងសកម្មភាពរបស់ជនជាប់ចោទឈ្មោះ ដែលបានប្រើអំណាចរបស់ខ្លួនជាគ្រូមន្តអាគម ហើយបានច្របាច់ និងបឺតជញ្ជក់សុដន់ជនរងគ្រោះឈ្មោះ ដោយប្រើល្បិចថាបញ្ចូលមន្តអាគមនោះជាអំពើល្មើសព្រហ្មទណ្ឌប្រទូស្តកេរ្តិ៍ខ្មាស(ស្ថានទំងន់ទោស) ។

**៤**-ការលើកឡើងរបស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ក្នុងសេចក្តីសន្និដ្ឋានប្តឹងសុំអំពីអង្គហេតុ និងពិរុទ្ធភាពលើជនជាប់ចោទ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

**៥**-មានពិរុទ្ធភាពលើឈ្មោះ ភេទប្រុស អាយុ ៥៣ឆ្នាំ ជាតិខ្មែរ ពីបទ : ប្រទូស្តកេរខ្មាស (ស្ថានទំងន់ទោស) ប្រព្រឹត្តនៅចំណុច ផ្ទះជួលគ្មានលេខ ផ្លូវបេតុង ក្រុម ១៣ ភូមិទូលសង្កែ សង្កាត់ទូលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៨ ខែមីនា ឆ្នាំ ២០១១ តាមបញ្ញត្តិមាត្រា ២៤៧ នៃក្រមព្រហ្មទណ្ឌ ។

**៦**-ការប្រព្រឹត្តអំពើល្មើសរបស់ជនជាប់ចោទ ធ្វើឡើងដោយមានចេតនា និងមានស្មារតីទទួលខុសត្រូវគ្រប់គ្រាន់ និងបានធ្វើអោយប៉ះពាល់ដល់កិត្តិយស សេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះ និងក្រុមគ្រួសាររបស់ជនរងគ្រោះ ប៉ះពាល់ដល់ប្រពៃណីដ៏ល្អរបស់ជាតិ ជាពិសេសបំពានទៅលើនីត្យានុកូលភាពសង្គមដែលត្រូវបានច្បាប់ការពារយ៉ាងម៉ឺងម៉ាត់បំផុត ។

**៧**-ជនជាប់ចោទជាមនុស្សចាស់ មានអាយុ ៥៣ឆ្នាំ ដើម្បីជាមនុស្សធម៌ គួរតប្បីតុលាការសំរេចពីស្ថានសម្រាលទោសអោយជនជាប់ចោទ ។

៨-ជនរងគ្រោះ និងជាដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ប្ដឹងទាមទារជំងឺចិត្តជាប្រាក់ចំនួន ៣.០០០ (បីពាន់) ដុល្លារអាមេរិក ពីជនជាប់ចោទឈ្មោះ ។ ចំណុចនេះ គួរតប្បីតុលាការពិចារណាសំរេចតាមស-ភាពជាក់ស្ដែង ។

## ហេតុដូច្នេះសំរេច

១-ផ្ដន្ទាទោសឈ្មោះ ភេទប្រុស អាយុ ៥៣ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ២(ពីរ) ឆ្នាំ តែទោសជាប់ពន្ធនាគារកំណត់ ១(មួយ) ឆ្នាំ គិតពីថ្ងៃឃុំខ្លួន ថ្ងៃទី ១១ ខែមីនា ឆ្នាំ ២០១១ ទោសសល់ពីនេះ ត្រូវព្យួរធម្មតា ពីបទ : **ប្រទូសកេរខ្មាស(ស្ថានទំងន់ទោស)** ប្រព្រឹត្តនៅចំណុច ផ្ទះជួលគ្មានលេខ ផ្លូវបេតុង ក្រុម ១៣ ភូមិទួលសង្កែ សង្កាត់ទួលសង្កែ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៨ ខែមីនា ឆ្នាំ ២០១១ តាមបញ្ញត្តិមាត្រា ២៤៧, ១០៨ និងមាត្រា ៩៧ នៃក្រមព្រហ្មទណ្ឌ ។

២-បង្គាប់អោយជនជាប់ចោទឈ្មោះ សងសំណងជំងឺចិត្តជាប្រាក់ចំនួន ៤.០០០.០០០(បួនលាន) រៀល អោយទៅជនរងគ្រោះ និងជាដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ នៅពេលសាលក្រមនេះ ចូលជាស្ថាពរ. ការទាមទារលើសពីនេះត្រូវច្រានចោល ។

សាលក្រមនេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី ០៣ ខែតុលា ឆ្នាំ ២០១១ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ២៨ ខែតុលា ឆ្នាំ ២០១១ ចំពោះមុខជនជាប់ចោទឈ្មោះ មេធាវីការពារសិទ្ធិជនជាប់ចោទ តែកំបាំងមុខជនរងគ្រោះ និងជាដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ។

បើកសិទ្ធិប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខា និងត្រា :

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និងត្រា

---

**បានឃើញ**
**ចៅក្រមជំនុំជម្រះ**

**(បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម)**
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែតុលា ឆ្នាំ ២០១១
**ក្រឡាបញ្ជី**